ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

**ឯកសារដើម**
**ORIGINAL/ORIGINAL**
ថ្ងៃ ខែ ឆ្នាំ (Date): 20-Jan-2012, 15:03
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការ
# សវនាការផ្ទាល់មាត់លើឯកសារនានា
# សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១២**

**ម៉ោង ០៩:០១ នាទី**

**សវនាការលើកទី១៨**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*
ចៅក្រម យ៉ា សុខន
ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍
*(Judge Jean-Marc LAVERGNE)*
ចៅក្រម យូរ ឧត្តរា
ចៅក្រម ធូ មណី (បម្រុង)

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាស្មី
លោក សេង ប៊ុនឃាង
លោក វីល្លៀម ស្មីត
*(Mr. William SMITH)*
លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*
កញ្ញា ហ្វាល់ហ្គុនី ដេបណាត
*(Ms.Falguni DEBNATH)*
លោកស្រី សារ៉ាស អេនឌ្រូ
*(Ms.Sarah ANDREWS)*

**ជនជាប់ចោទ៖**

លោក នួន ជា
លោក ខៀវ សំផន
លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក មៃខល ផេសមិន

*(Mr. Michiel PESTMAN)*

លោក អេនឌ្រូ អ៊ីនូហ្ស៊ី

*(Mr. Andrew IANUZZI)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក មៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ឡោ ជុនធី

លោក ហុង គឹមសួន

លោក វ៉ែន ពៅ

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| លោក វីល្លៀម ស្មីត | អង់គ្លេស |
| លោក អាប់ឌុលឡាក់ ថារីក | អង់គ្លេស |
| លោកស្រី ហ្វាល់ហ្គុនី ដេបណាត | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក អេនឌ្រូ អ៊ីនូហ្វ៊ី | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក ឡោ ជុនធី | ខ្មែរ |
| លោក ហុង គីមសួន | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:៣៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ កិច្ចដំណើរការនីតិវិធីសវនាការកាលពីម្សិលមិញពេលរសៀលមុននឹងបញ្ចប់ហ្នឹង គឺដល់វេទិកានៃការឆ្លើយតបរបស់សហព្រះរាជអាជ្ញា ដែលមានរយៈពេលមួយម៉ោង ហើយសហព្រះរាជអាជ្ញាជាតិបានធ្វើរួចហើយ នៅសហព្រះរាជអាជ្ញាអន្តរជាតិកន្លះម៉ោង។ ប៉ុន្តែ មុននឹងបន្ត កិច្ចដំណើរការនីតិវិធីសវនាការដោយការឆ្លើយតបរបស់សហព្រះរាជអាជ្ញាបន្ត អង្គជំនុំជម្រះសូមសួរទៅសហព្រះរាជអាជ្ញាអំពីពេលវេលាដែលអង្គជំនុំជម្រះបានមានបំណងក្នុងការសួរ-- អ៎ ស្ដាប់ចម្លើយសក្ខីកម្មសាក្សីចំនួនពីររូប គឺTCW-766 ហើយនិងTCW-542 នៅក្នុងសប្ដាហ៍ក្រោយ សំណួរសួរថាតើសហព្រះរាជអាជ្ញាត្រូវការពេលវេលាប៉ុន្មាន សម្រាប់សួរសាក្សីម្នាក់ៗ?

[០៩:០៣:២៣]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម។

ខ្ញុំស្មានថាទាក់ទងទៅនឹងTC-766 ប្រហែលជាត្រូវការពេលវេលាកន្លះថ្ងៃ ដោយយោងទៅលើមូលដ្ឋានដែលអង្គជំនុំជម្រះបញ្ជាក់ថា អង្គជំនុំជម្រះនឹងសាកសួរសាក្សីនេះមុន ហើយបន្ទាប់មក សហព្រះរាជអាជ្ញានឹងសួរទៅតាមក្រោយ ដើម្បីចៀសវាងកុំឲ្យសហព្រះរាជអាជ្ញាសួរសំណួរជាន់គ្នា។ អ៊ីចឹងដូច្នេះ ខ្ញុំគិតថាកន្លះថ្ងៃ ជាការគ្រប់គ្រាន់ហើយ ហើយទាក់ទងទៅនឹង TC-542 យើងខ្ញុំនឹងព្យាយាមទៅតាមលទ្ធភាព។ យើងខ្ញុំគិតថាប្រហែលជាបីវគ្គដែលមានរយៈពេលបួនម៉ោង។ ដូច្នេះ យើងខ្ញុំនឹងព្យាយាមសួរឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ ប៉ុន្តែ នេះក៏ទៅតាមលក្ខណៈនៃការភាពអាចបត់បែនផងដែរ។ ហើយលោកប្រធានបញ្ជាក់ពីម្សិលមិញថា ប្រហែលជាការមានប្រយោជន៍ណាស់ដែលប្រសិនណាជាសហព្រះរាជអាជ្ញាអាចផ្ដល់នូវបញ្ជីភស្តុតាងថ្មី ដើម្បីបញ្ជាក់ថាឯកសារមួយណាដែលមានប្រភពមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា។

យើងខ្ញុំជឿជាក់ថា ប្រហែល-- យើងខ្ញុំនឹងធ្វើរួចរាល់នៅថ្ងៃអង្គារសប្តាហ៍ក្រោយ។ យើងខ្ញុំមានបំណងចង់ធ្វើឲ្យបញ្ជីនេះរួចរាល់មុនថ្ងៃអង្គារនេះ ក៏ប៉ុន្តែយើងសូមបញ្ជាក់ថាធ្វើហើយនៅថ្ងៃអង្គារនេះ ទាក់ទងទៅនឹងបញ្ជីឯកសារដែលមានប្រភពចេញមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា។

[០៩:០៥:១៥]

**ប្រធានអង្គជំនុំ៖**

អរគុណសហព្រះរាជអាជ្ញា។

ជាបន្ត ខាងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការស្តាប់ចម្លើយសាក្សីពីររូបអម្បាញ់មិញនេះ តើត្រូវការពេលវេលាប៉ុន្មានដែរ ក្នុងការសួរទៅសាក្សីមួយរូបៗ?

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន។ សូមគោរព លោក លោកស្រីចៅក្រម អស់លោក លោកស្រីដែលមានវត្តមានទីនេះ។ មេធាវីនាំមុខសម្រាប់ការសួរយកចម្លើយទៅលើសាក្សី ទាំងពីររូបនេះ មេធាវីនាំមុខត្រូវការពេលវេលាសម្រាប់សាក្សីនីមួយៗ រយៈពេលពីរម៉ោង។ ដូច្នេះមានន័យថា សម្រាប់សាក្សី 542 មានរយៈពេលពីរម៉ោង និងសាក្សី 766 មានរយៈពេលពីរម៉ោង។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ចុះខាងមេធាវីការពារក្តីលោក នួន ជា យ៉ាងម៉េចដែរ?

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំធ្វើការពិភាក្សាជាមួយសហការីរបស់ខ្ញុំសម្រាប់ក្រុមមេធាវីការពារក្តី ខ្ញុំគិតថា សម្រាប់សាក្សីទីមួយ 766 គឺថាក្រុមមេធាវីការពារក្តីទាំងអស់តែម្តង ទាំងបីក្រុមតែម្តង ប្រហែលជាត្រូវការមួយថ្ងៃទៅមួយថ្ងៃកន្លះ ហើយយើងខ្ញុំនឹងចែកពេលវេលានេះ ក្នុងចំណោមមេធាវីការពារទាំងបីក្រុមនេះ។ ប៉ុន្តែតាមការស្មានគ្រួសៗទេនេះ ហើយយើងខ្ញុំ-- ហើយសម្រាប់សាក្សីមួយរូបផ្សេងទៀតនោះ ខ្ញុំប៉ាន់ប្រមាណពេលវេលាថា ត្រូវការតែកន្លះថ្ងៃទេ។ ហ្នឹងសម្រាប់ការសួររបស់យើងខ្ញុំផ្ទាល់។ ខ្ញុំមិនទាន់បានពិភាក្សាជាមួយក្រុមដទៃទៀតទេចំពោះសាក្សីរូបនេះ។

[០៩:០៧:២២]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ចុះលោកមេធាវីការពារក្តី អៀង សារី? ចំពោះសាក្សី TCW-542 តើត្រូវការ

ពេលវេលាប៉ុន្មានដែរក្នុងការសាកសួរ?

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន។ ចំពោះសាក្សី TCW-542 ក្រុមមេធាវីការពារក្តីលោក អៀង សារី ត្រូវការពេលវេលា ប្រហែលជាមួយម៉ោងទៅមួយម៉ោងកន្លះ។ ដោយឡែក សម្រាប់ TCW-766 ហ្នឹងគឺ សម្រេចតាមអ្វីដែលក្រុមមេធាវីការពារលោក នួន ជា បានអះអាងអំមិញហើយថា រវាងពីមួយថ្ងៃទៅ មួយថ្ងៃកន្លះសម្រាប់ក្រុមមេធាវីទាំងបី។ សូមអរគុណ។

[០៩:០៨:១៥]

**ប្រធានអង្គជំនុំ៖**

អរគុណ។ ចុះក្រុមមេធាវីការពារក្តីលោក ខៀវ សំផន លើ TCW-542?

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ សម្រាប់សាក្សី TCW-542 យើងត្រូវការពេលវេលាប្រហែលពី ១៥នាទីទៅមួយម៉ោង។ ហើយសម្រាប់សាក្សី TCW-766 ដូចលោក ផេសមិន បានជម្រាបជូនក្រុម ប្រឹក្សាជំនុំជម្រះអម្បាញ់មិញគឺថា យើងនឹងប្រើពេលវេលាទៅតាមការស្នើសុំនោះបាទ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ នៅក្នុងការបង្ហាញជំហរ និងការប៉ាន់ស្មាននូវរយៈពេលនៃការតាំងសំណួរចំពោះ សាក្សី ដែលយើងគ្រោងធ្វើនៅក្នុងសប្តាហ៍ក្រោយ។ ការដែលធ្វើដូច្នេះ ដើម្បីងាយស្រួលក្នុងការរៀបចំ កាលវិភាគនៃកិច្ចដំណើរការសវនាការ ឲ្យបានឆាប់រហ័ស និងមានប្រសិទ្ធភាព។

ជាកិច្ចបន្ត អង្គជំនុំជម្រះសូមផ្តល់វេទិកាទៅសហព្រះរាជអាជ្ញា ដើម្បីបន្តឡើងធ្វើការអំណះ អំណាងតបទៅនឹងការជំទាស់របស់មេធាវីការពារក្តីទាំងបីក្រុម ទៅលើឧបសម្ព័ន្ធឯកសារ A4 ដែល សូមរំឭកឡើងវិញគឺ សហព្រះរាជអាជ្ញានៅពេលវេលា៣០នាទី ទៀតតែប៉ុណ្ណោះ។ សូមអញ្ជើញ!

[០៩:១០:០០]

**លោក អាប់ឌុលឡាក់ ចារីក៖**

សូមអរគុណលោកប្រធាន។

ដោយសារតែពេលវេលាខ្លី ហើយសហការីរបស់ខ្ញុំក៏បានធ្វើការជំទាស់ទៅនឹងប្រភេទនៃឯកសារ ទាំងនេះកាលពីម្សិលមិញរួចហើយ។ ខ្ញុំធ្វើការឆ្លើយតបឲ្យបានលឿន ដោយលើកតែចំណុចសំខាន់ៗ

លើកយកតែចំណុចសំខាន់ៗ ដែលមេធាវីការពារក្តីបានជំទាស់តវ៉ា។ ហើយខ្ញុំនឹងបង្ហាញនូវឯកសារមួយចំនួនដែលមាននៅក្នុងសារណារបស់យើងខ្ញុំ ហើយអស់លោក លោកស្រីនឹងអាចឃើញនូវឯកសារទាំងអស់នេះនៅក្នុងសារណារបស់ខ្ញុំ ដោយធ្វើការពិនិត្យពិច័យឲ្យបានម៉ត់ចត់បំផុត។

[០៩:១០:៤៥]

ដូច្នេះទាក់ទងទៅនឹងការជំទាស់តវ៉ាដំបូង ដែលធ្វើឡើងដោយក្រុមមេធាវីការពារក្តី នួន ជា។ ខ្ញុំឃើញថា មានការជំទាស់សំខាន់ៗមួយចំនួន ទោះបីជាវាមិនពាក់ព័ន្ធ-- ជាពិសេសទាក់ទងទៅនឹងឯកសារទាំងអស់នេះនៅក្នុងសវនាការដំណាក់កាលទីមួយនេះ ដែលខ្ញុំយល់ឃើញថា មានការលើកឡើងខុសមួយចំនួនពីសំណាក់ក្រុមមេធាវីការពារក្តីនេះ។ ហើយសហព្រះរាជអាជ្ញាត្រូវបានស្នើសុំឲ្យបង្ហាញនូវឯកសារ-- ដាក់ចេញនូវឯកសារ-- បញ្ជីឯកសារមួយចំនួនសម្រាប់ដំណាក់ដំបូងនេះ នៅក្នុងដីកា-- ទាក់ទងទៅនឹងដីកាបំបែកដំណើរការនីតិវិធី ដែលបានសម្រេចនៅថ្ងៃទី១៩ ខែមេសា ២០១១ ដែលជា-- យើងបានដាក់តាំងពីថ្ងៃទី២២ ខែកក្កដា ២០១១ នេះទាក់ទងទៅនឹងបញ្ជីឯកសារជាភាសាអង់គ្លេស។ ហើយតាមរយៈបញ្ជីនៃឯកសារនេះ គឺធ្វើឡើងបន្ទាប់ពីការចេញនូវដីកាសម្រេចបំបែកដំណើរការនីតិវិធីកាលពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១។

[០៩:១២:០០]

នៅក្នុងសវនាការដំណាក់កាលទីមួយ គឺទាក់ទងទៅនឹងប្រភេទនៃបទល្មើសពីរជាក់លាក់ ប៉ុន្តែបទល្មើសផ្សេងទៀតក៏អាចនឹងបន្ថែមផងដែរ។ ហើយបន្ថែមទៅលើនេះទៅទៀត គឺទាក់ទងទៅនឹងសេចក្តីទៅលើសំណើសុំរបស់ ក.ស.ព សូមឲ្យពិចារណាឡើងវិញ គឺឯកសារ E124/7។ ហើយនេះ គឺសម្រេចឡើងទៅតាមសំណើសុំរបស់ ក.ស.ព ឲ្យពិចារណាឡើងវិញទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មបន្ថែមទៀត។ ហើយសម្រាប់កថាខណ្ឌនៅក្នុងឯកសារ E124/7 នេះគឺទាក់ទងទៅនឹងរចនាសម្ព័ន្ធ និងទំនាក់ទំនង ក៏ដូចជាយន្តការ ក៏ដូចជាស្ថាប័នក្រសួងនានារបស់កម្ពុជាប្រជាធិបតេយ្យ និងរចនាសម្ព័ន្ធរបស់បក្សកុម្មុយនីស្តកម្ពុជា។

[០៩:១៣:០៥]

ហើយទាក់ទងទៅនឹងប្រតិបត្តិការ ក៏ដូចជាការបង្កើតទៅនឹងរចនាសម្ព័ន្ធផ្សេងៗ គឺវាពាក់ព័ន្ធទៅសវនាការដំណាក់កាលទីមួយនេះ។ គឺថាវាពាក់ព័ន្ធទៅនឹង-- មាននៅក្នុងកថាខណ្ឌ១៥៩ ទៅដល់ ១៤២ ឯកសារទាំងអស់នេះ គឺបង្ហាញអំពីអត្ថិភាពនៃរចនាសម្ព័ន្ធ ក៏ដូចជាការប្រាស្រ័យទាក់ទងរបស់របប

កម្ពុជាប្រជាធិបតេយ្យ។ ហើយក្នុងការធានាឲ្យមានការអនុវត្តនូវផែនការឧក្រិដ្ឋរបស់នៃរបបនេះហើយ ជនជាប់ចោទត្រូវតែប្រឈមមុខទៅនឹងបទចោទទាំងអស់ ដែលមាននៅក្នុង ហើយមាននៅក្នុង ឯកសារ E131។ ដូចដែលមានបញ្ជាក់រួចមកហើយ ដែលមានការពាក់ព័ន្ធទៅនឹងសវនាការដំណាក់ដំបូងនេះ។

[០៩:១៤:១២]

ខ្ញុំព្យាយាមលើកឡើងឲ្យបានលឿន ទាក់ទងទៅនឹងឧទាហរណ៍មួយចំនួន ដែលសហការីរបស់ខ្ញុំបានលើកឡើង។ ប៉ុន្តែមុននេះ គឺខ្ញុំសូមធ្វើការបង្ហាញទៅនឹងអ្វីដែលមេធាវីការពារក្តីបានលើកឡើង។ មេធាវីការពារក្តីរបស់ នួន ជា បានបដិសេធថា បានបញ្ជាក់រួចមកហើយថា ដែលពួកគាត់នឹងដាក់ជូននូវឯកសារណាដែលមានការពាក់ព័ន្ធ គឺឯកសារ D109/3 ដែលទាក់ទងទៅនឹងឯកសារភស្តុតាងទាំងអស់ដែលបានចាត់ថ្នាក់ និងបានផ្តល់ជូន ហើយឯកសារទាំងអស់នេះគឺមាននៅក្នុងសំណុំរឿងពីរឆ្នាំបីឆ្នាំកន្លងមកហើយនេះ។ ហើយសហព្រះរាជអាជ្ញាបានធ្វើការដោយប្រយ័ត្នប្រយែងបំផុត។

ទាក់ទងទៅនឹងឧទាហរណ៍ជាក់លាក់មួយចំនួនដែលបានលើកឡើង គឺមេធាវីការពារក្តីបានយោងទៅលើឯក-- ឧទាហរណ៍ជាក់លាក់មួយចំនួន។

[០៩:១៥:៤៥]

ឧទាហរណ៍ ឯកសារយោងលេខ១៦៥ គឺជាឯកសារទាក់ទងទៅ គឺឯកសារលេខ 21.16 គឺតាមពិតឯកសារនេះ គឺជាឯកសារពាក់ព័ន្ធទៅនឹងសារទូរលេខ ដែលនៅ-- ឯកសារគឺបង្ហាញអំពីអត្ថិភាពនៃរចនាសម្ព័ន្ធដែលមានស្រាប់ ក៏ដូចជារចនាសម្ព័ន្ធដែលមានៗនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ហើយប្រសិនជាយើងពិនិត្យមើលទៅលើទំព័រដែលគាត់បានលើកឡើង គឺទំព័រ១៦៥ គឺយើងខ្ញុំសូមបញ្ជាក់ថាភាពពាក់ព័ន្ធគឺពាក់ព័ន្ធទៅនឹងប្រតិបត្តិការនៃមន្ទីរ៨៧០។ ហើយលើសពីនេះទៅទៀត សហការីរបស់ខ្ញុំបានរកឃើញថា ឯកសារនេះគឺយោងនៅក្នុងកថាខណ្ឌ៧៧ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលផ្នែកមួយនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទាក់ទងទៅនឹងដំណាក់នៃសវនាការដំបូងនេះ។

[០៩:១៧:០២]

យើងខ្ញុំមិនអាចលើកឧទាហរណ៍ទាំងអស់បាននោះទេ ប៉ុន្តែលើកតែឯកសារណាដែលមានការពាក់ព័ន្ធដូចជាបញ្ហាទាក់ទងទៅនឹងសារទូរលេខ ក៏ដូចជារចនាសម្ព័ន្ធនៃការប្រាស្រ័យទាក់ទងគ្នា ទាក់ទងទៅនឹងផែនការឧក្រិដ្ឋកម្មនេះ។ ឧទាហរណ៍ មួយទៀតគឺឯកសារ359 គឺបញ្ជីឯកសារបញ្ជាក់ហើយគឺទាក់ទងទៅនឹងរចនាសម្ព័ន្ធនៃការប្រាស្រ័យទាក់ទងគ្នា ដោយមានការពាក់ព័ន្ធទៅនឹងលោក នួន ជា

នៅក្នុងផែនការឧក្រិដ្ឋកម្មនេះ។ ឯកសារនេះ ក៏មាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ គឺកថាខណ្ឌ ៨៧៦។ ហើយចុងក្រោយ ខ្ញុំសូមបង្ហាញនូវឯកសារមួយទៀត គឺឯកសារ៣៦៥ គឺមានការពាក់ព័ន្ធទៅនឹងឯកសារដែលសហការីខ្ញុំបានលើកឡើងទាក់ទងទៅនឹងប្រតិបត្តិការនៃមន្ទីរ៨៧០ ក៏ដូចជាអត្ថិភាពនៃរចនាសម្ព័ន្ធ និងការប្រាស្រ័យទាក់ទងគ្នា។

[០៩:១៨:០៧]

ហើយនៅក្នុងសំណុំរឿង គឺថាក៏មានការបង្ហាញនូវចម្លើយសាក្សី ដែលត្រូវបានសម្ភាសន៍ដោយការិយាល័យសហចៅក្រមស៊ើបអង្កេត គឺសាក្សីTCW-604។ ដូច្នេះ ទាក់ទងទៅនឹងឯកសារទាំងអស់នេះ គឺថាមានការបញ្ជាក់បានលើសពីភាពគ្រប់គ្រាន់ហើយ ហើយដែលយើងខ្ញុំនឹងស្នើសុំឱ្យតុលាការធ្វើការពិចារណា។

ទាក់ទងទៅនឹងចម្លើយតបរបស់ក្រុមមេធាវីការពារក្តី អៀង សារី មានការបញ្ជាក់ថា មានការគឺស្របទៅនឹងការអនុវត្តក្នុងតុលាការអន្តរជាតិ។ គឺថាក្នុងចំណុចនេះ ខ្ញុំសូមលើកឡើងនូវអ្នករៀបចំនូវសារទូរលេខមួយចំនួន អ្នករៀបចំនូវលេខកូដមួយចំនួន និងការប្រាស្រ័យទាក់ទង ដែលអង្គជំនុំជម្រះបានកោះហៅនូវសាក្សីដែលត្រូវបាន កោះហៅសាក្សីរួចមកហើយ ហើយមានសារទូរលេខមួយចំនួនដែលយើងព្យាយាមស្នើសុំឱ្យកោះហៅនូវសាក្សីទាំងនេះនៅសវនាការលើកក្រោយនេះ។

[០៩:១៩:២៥]

ជាការសមស្របហើយ ដែលយើងត្រូវកោះហៅនូវអ្នករៀបចំសារទូរលេខទាំងអស់នេះ គឺយើងមាន TCW-398, 480, 307 ។ល។ សាក្សីទាំងអស់នេះ អាចជាៗអ្នករៀបចំនូវសារទូរលេខ ឬក៏អ្នកដាក់លេខកូដនៅសារទូរលេខ គឺជាកម្មាភិបាលថ្នាក់ទាប នៃស្ថាប័នរបស់កម្ពុជាប្រជាធិបតេយ្យ ដែលមានទីតាំងនៅទីក្រុងភ្នំពេញ។ ទាក់ទងទៅនឹងឯកសារដែលសហមេធាវីការពារក្តី អៀង សារី បានលើកឡើងនោះ គឺថាយើងមានសំណួរមួយចំនួនដែលត្រូវចោទសួរ តើអ្នកណាដែលមេធាវីការពារក្តីនោះបានលើកឡើងនោះ? អ្នកណាខ្លះ? ប៉ុន្តែព័ត៌មានទាំងអស់នេះ គឺថាអាចមានរួចហើយនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយទាក់ទងទៅនឹងកថាខណ្ឌ២១.៤ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ គឺលោក ហេង គឺជាអតីតលេខាធិការតំបន់១០៣ ហើយចម្លើយសារភាពរបស់គាត់គឺមាននៅក្នុងមន្ទីរស-២១ គឺមាននៅក្នុងសំណុំរឿងហើយ គឺនៅក្នុងឯកសារ D159/5.4។

ហើយលេខាធិការដែលត្រូវបានជំនួសដោយលេខាធិការរូបនេះ ក៏ត្រូវបានផ្តល់ចម្លើយរួចហើយ

មកដែរ គឺមានឯកសារ D428 និងឯកសារ D366/7.1.793។ គឺយើងមានឯកសារមួយចំនួនយោងទៅគាត់ៗជាលេខាធិការនៃស្រុកមួយនៅក្នុងភូមិភាគនិរតី។ ហើយនៅក្នុងកថាខណ្ឌ៥៩៨ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ខ្ញុំសូមលើកឡើងនូវចម្លើយរបស់ ឌុច "នួន ជា ក៏បាន-- ក៏មានការជាប់ពាក់ព័ន្ធទៅនឹងការបញ្ជាឲ្យចាប់ រស់ ញឹម ដែរ"។ ហើយឯកសារនេះ គឺថាវាមាននៅក្នុងសំណុំរឿងរួចទៅហើយ។ សហការីរបស់ខ្ញុំបានយោងទៅលើឯកសារ D199/14.2។

[០៩:២២:២០]

លោក លោកស្រីចៅក្រមជាទីគោរព ជាថ្មីម្តងទៀត ឯកសារទាំងអស់នេះ គឺយោងមានយោងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងលក្ខណៈលម្អិត។ ប្រសិនណាជាយើងមើលទៅលើកថាខណ្ឌ ១០៩៤ គឺនៅក្នុង-- គឺត្រូវបានកោះហៅកម្មាភិបាលទាំងអស់នេះ ដែលឲ្យចូលខ្លួនមកប្រទេសកម្ពុជា ហើយកម្មាភិបាលទាំងអស់នេះត្រូវបាន-- អ្នកដែលគេមកហៅវិញនេះ ត្រូវបានគេចាប់ខ្លួននិងបញ្ជូនទៅមន្ទីរស-២១។

ដូចមានពន្យល់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះហើយ គឺនៅពេលត្រលប់មកតាមទីក្រុងប៉េកាំងមកកាន់ប្រទេសកម្ពុជា អ្នកទាំងអស់នេះគឺបានជូនដំណឹងទៅក្រុមគ្រួសាររបស់គាត់។ ហើយព័ត៌មានទាក់ទងទៅនឹងបញ្ហាទាំងអស់នេះ គឺយើងមានចម្លើយសាក្សី គឺចម្លើយ D199/14។ ឯកសារទាំងអស់នេះ ដែលមេធាវីការពារក្តីបានលើកឡើង គឺឯកសារទាំងអស់នេះបង្ហាញនូវភាពគួរឲ្យជឿជាក់បាន។

ទាក់ទងទៅនឹងឧទាហរណ៍មួយចំនួន ដែលមាននៅក្នុងសំណើសុំរបស់យើងខ្ញុំគឺបង្ហាញថា តើឯកសារទាំងអស់នេះត្រូវពិនិត្យឡើងដោយរបៀបណានោះ? ដែលជាឯកសារពាក់ព័ន្ធទៅនឹងភាពពាក់ព័ន្ធ និងភាពគួរឲ្យជឿជាក់បាន។

[០៩:២៤:១៣]

ខ្ញុំនឹងសូមបង្ហាញជូននូវឯកសារមួយចំនួនតាមដែលអាចខ្ញុំធ្វើទៅបាន ដោយយោងទៅពេលវេលាដែលនៅសេសសល់នេះ ទាក់ទងទៅនឹង-- មានឯកសារ ៣៩៣ឯកសារដែលបានយកមកបង្ហាញជូននៅក្នុងសវនាការដំណាក់កាលដំបូងនេះ។

យើងខ្ញុំគិតថា ឯកសារ-- នៅក្នុងចំណោមឯកសារទាំង ៣៩៣នេះ ឯកសារ១៦៨ ត្រូវបានអង្គជំនុំជម្រះទទួលយករួចហើយ។ ហើយយើងខ្ញុំយល់ឃើញថា ឯកសារទាំងអស់នេះគឺជាឯកសារមួយ

ដែលបានដាក់ចូលទៅក្នុងសំណុំរឿង០០១ ទាក់ទងភាពគួរឲ្យជឿជាក់បាន។ ហើយឯកសារទាំងអស់នេះ ជាឯកសារដែលគួរឲ្យជឿជាក់បានជាបឋម។ ការប្រាស្រ័យទាក់ទងដូចដែលសហការីរបស់ខ្ញុំលើកឡើង កាលពីម្សិលមិញមានឯកសារចំនួនប្រាំប្រភេទ គឺសារទូរលេខរបស់កម្ពុជាប្រជាធិបតេយ្យ មានកំណត់ត្រាផ្សេងៗ ក៏ដូចជាឯកសារមួយចំនួនដែលបញ្ជាទៅថ្នាក់ក្រោមនោះ។ ហើយយើងក៏មានចម្លើយសាក្សី នៅក្នុងសំណុំរឿង យើងមានសារទូរលេខដែលចេញមកពីកម្មាភិបាលមួយចំនួនបានរៀបចំឡើងនោះ។ ហើយឯកសារទាំងអស់នេះ ប្រសិនណាជាអង្គជំនុំជម្រះត្រូវយកពិចារណាយើងខ្ញុំសូមស្នើឲ្យពិចារណាទាំងមូលតែម្តង។

[០៩:២៦:០៩]

ខ្ញុំសូមលើកឧទាហរណ៍មួយ ឯកសារចំនួន១៣គឺមានសាក្សីម្នាក់ឈ្មោះ ឡេង ហើយឯកសារខ្លះទៀតមានឯកសារជារហស្សនាមឈ្មោះ ចាន់ ដែលជាលេខាធិការតំបន់ឯករាជ្យ១០៥ ដែលបានរៀបរាប់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ហើយមានសាក្សីពីរ ដែលគឺជាសមាជិកគ្រួសារជិតដិតរបស់គាត់ គឺTC-695 និងTCW-307។ ហើយប្រសិនជាយើងពិនិត្យមើលទៅលើសារទូរលេខមួយចំនួនទៀតដែលទាក់ទងទៅនឹងព្រឹត្តិការណ៍មួយចំនួន គឺវាស៊ីសង្វាក់គ្នាទៅនឹងព្រឹត្តិការណ៍ទាំងអស់នោះ ហើយក៏វាគួរឲ្យជឿជាក់បានផងដែរ បើយើងយោងទៅចម្លើយសាក្សី។

ដូច្នេះឯកសារទាំងអស់នេះ យើងខ្ញុំសូមស្នើឲ្យអង្គជំនុំជម្រះមេត្តាពិនិត្យពិចារណាជាទាំងមូលតែម្តង ជាមួយក្រុមៗ ដើម្បីឲ្យវាមានការពាក់ព័ន្ធទៅនឹងឯកសារដទៃទៀត។ យើងបង្ហាញឯកសារឲ្យបានច្រើនទៅតាមអាចធ្វើទៅបាន ដោយយោងទៅលើពេលវេលាដែលនៅសេសសល់តិចតួច។

លោកប្រធានជាទីគោរព! ប្រសិនណាជាយើងខ្ញុំអាចបង្ហាញឯកសារនៅលើអេក្រង់ សូមបង្ហាញនៅក្នុងរយៈពេលខ្លីទេ។

[០៩:២៧:៥៩]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត សូមអញ្ជើញ! លោកនៅមានពេលវេលា១២នាទីទៀតណា។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ នេះគឺជាឧទាហរណ៍នៃសារទូរលេខដែលនៅក្នុងនេះ វាបង្ហាញឲ្យឃើញថា យើងមានថៅក្រមស៊ើបអង្កេតដែលទទួលបានឯកសារដើម ឬក៏រូបថតឯកសារដើមនេះ។

ជាការពិតមន្ត្រីជាន់ខ្ពស់របស់ ឌី.ស៊ី.ខេម បានបង្ហាញថាឯកសារនេះ វាមានទម្រង់ជាឯកសារដើមផង ដែរ។ នេះជាឯកសារជាភាសាខ្មែរ ជាការលើកឡើងរបស់មន្ត្រីនៅ ឌី.ស៊ី.ខេម គឺគាត់បានលើកឡើងនៅ ក្នុងឯកសារ D311/2 នៅក្នុងទំព័រនេះ នៅខាងក្រោមគឺមានការកោសលុប ដែលក្នុងនោះគឺជាឈ្មោះ របស់អ្នកនិពន្ធ និងអ្នករៀបចំសារទូរលេខនេះឡើង។ គឺអ្នកដែលរៀបចំនេះ គឺជាTCW-604 ដែលគាត់ នឹងមកផ្តល់សក្ខីកម្មនៅពេលក្រោយ ហើយគាត់បង្ហាញថា គាត់ជាអ្នករៀបចំនូវសារទូរលេខនេះ ដោយ ខ្លួនឯងផ្ទាល់។ ជាថ្មីម្តងទៀត នៅពេលដែលយើងមកមើលភាពពាក់ព័ន្ធនៃឯកសារមួយនេះ ខ្លឹមសារនៃ ឯកសារទាំងអស់នេះ វាគួរឲ្យយើងចាប់អារម្មណ៍ណាស់ ក៏ប៉ុន្តែឯកសារនេះ គឺវាពាក់ព័ន្ធទៅនឹងការ ស្វែងរកគិញយួន។ ដូច្នេះហើយចំពោះភាពពាក់ព័ន្ធរបស់វា វាសម្រាប់បង្កើតឲ្យយើងឃើញអំពីរចនា សម្ព័ន្ធនៃការប្រាស្រ័យទាក់ទងគ្នានៅក្នុងរបបនោះ។

[០៩:២៩:៤៨]

លោក លោកស្រីចៅក្រម ប្រសិនបើខ្ញុំអាចចូលទៅដល់ឯកសារមួយទៀត ឯកសារលេខ D175/6.13 ប្រសិនបើអនុញ្ញាត ខ្ញុំសូមបង្ហាញនូវឯកសារនេះនៅលើអេក្រង់។

**ប្រធានអង្គជំនុំ៖**

អនុញ្ញាត។

**លោក អាប់ឌុលឡាក់ ថារីក៖**

ជាថ្មីម្តងទៀត នេះគឺជាឯកសារខ្មែរ ដោយសារតែពេលវេលាវាជិតអស់ហើយខ្ញុំសូមបង្ហាញ នៅក្នុងទំព័រនេះវាជាឯកសារដើម។ គឺឯកសារ D11/2 មន្ត្រីនៅ ឌី.ស៊ី.ខេម គាត់បានលើកឡើងអំពី ឯកសារនេះ ដែលថាជាឯកសារដើម។ ឯកសារនេះ គឺជាឯកសារដែលអ្នកនិពន្ធដដែលទេដែលគាត់ សរសេរ គាត់ជាបុគ្គលនៅខាងតំបន់ភ្លៀសាន។

ចំណុចចុងក្រោយពាក់ព័ន្ធទៅនឹងឯកសារមួយទៀត ឯកសារនោះគឺមានយថាភូតដែលបាន បញ្ជាក់ដោយសាក្សីមួយរូប។ គឺឯកសារនេះបញ្ជាក់ដោយសាក្សី TCW-480 គាត់នឹងមកផ្តល់សក្ខីកម្ម នៅពេលក្រោយ និងគាត់បញ្ជាក់អំពីសំណេរជាសំណេរដៃ ដែលបានសរសេរឡើងនៅក្នុងឯកសារនេះ ហើយបានបញ្ជូនឯកសារនេះមួយច្បាប់ទៅលោក អៀង សារី។ នៅពេលនេះ គឺខ្ញុំសូមលើកឧទាហរណ៍ មួយទៀត ដែលវាជាសារទូរលេខដដែល ប្រសិនបើយើងអាចបញ្ចាំងបាននោះ គឺឯកសារៗលេខ 21.146 ប្រសិនបើអនុញ្ញាតសូមធ្វើការបញ្ចាំង។ សូមអរគុណលោកប្រធានដែលអនុញ្ញាត។

[០៩:៣១:៥២]

ឯកសារមួយនេះ-- ប្រសិនបើយើងអាចនោះសូមបញ្ចាំងៗនៅលើអេក្រង់។ សូមអរគុណ។

ជាថ្មីម្តងទៀត ខ្ញុំបង្ហាញតែឯកសារខ្មែរទេ ដោយសារតែយើងពេលវេលាមិនមានគ្រប់គ្រាន់ នេះគឺជាឯកសារពីក្រសួងពាណិជ្ជកម្មនៅក្នុងទីក្រុងភ្នំពេញដែលបានលើកឡើងជូនទៅដល់លោក ណាត និង រិន។ សមមិត្តណាត គឺវាបានបង្ហាញយ៉ាងច្បាស់នៅក្នុងភស្តុតាងនៃឯកសារ គឺជាប្រពន្ធរបស់ សុខ ហៅ វ៉ា គឺគាត់នៅហុងកុង។ ដូច្នេះឯកសារនេះ គឺវាបង្ហាញថាអ្នកទាំងអស់នេះ គឺបានបង្ហាញអំពីការគ្រប់គ្រងទៅលើក្រុមហ៊ុនមួយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះ មន្ទីរទាំងនោះ គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់លោកជនជាប់ចោទ ខៀវ សំផន។ ខ្លឹមសារនៃឯកសារនេះ គឺគួរឲ្យចាប់អារម្មណ៍ណាស់ ដូចទៅនឹងឯកសារមុនៗដែរ។ ឯកសារនេះបានបង្ហាញថា មានអ្វីកើតឡើងក្រោយពីសារទូរលេខនេះបានបញ្ជូន។ សារទូរលេខនេះ គឺបង្គាប់ឲ្យ ណាត និង ឈូក រិន ត្រឡប់មកភ្នំពេញវិញ។ ប្តី អ៊ុំង សុខ ក៏ត្រូវត្រឡប់មកវិញផងដែរ។

[០៩:៣៣:១៧]

ដូច្នេះប្រសិនបើអនុញ្ញាត ខ្ញុំសូមបង្ហាញឯកសារពីរនៅលើអេក្រង់ ឯកសារ IS3.1។ បាទសូមបញ្ចាំង ប្រសិនបើយើងសូមបញ្ចាំងនោះ គឺឯកសារចេញមកពីដីកាបញ្ជូនរឿងទៅស៊ើបសួរ 3.1។ អ៊ុំង សុខ បាទគឺ ផៅ វ៉ា ហៅ ណាត បានបង្ហាញថា លោកស្រីហ្នឹងគឺគាត់ចូលទៅក្នុងមន្ទីរស-២១ នៅថ្ងៃទី ២៩ ខែ១២ ឆ្នាំ១៩៧៨។ ដូច្នេះហើយនៅក្នុងនេះវាបង្ហាញអំពីប្តីរបស់គាត់ ហើយឯកសារនេះមាននៅក្នុងឯកសារ 3.1 ដីកាបញ្ជូនរឿងទៅស៊ើបសួរ។

បាទ គឺឯកសាររបស់លោកស្រីជាប្រពន្ធ 3.5 ទេ សូមអភ័យទោស ហើយឯកសារដែលជាប្តីនោះ 3.1។ ដូច្នេះឯកសារនេះ គឺបង្ហាញអំពីថាតើឯកសារនេះគេបញ្ចូលរួមគ្នាយ៉ាងម៉េច? រូបថត គឺមាននៅក្នុងសំណុំរឿង ដែលវាជាផ្នែកមួយនៃសំណុំរឿង 3.5។ បើសិនជាអនុញ្ញាតខ្ញុំសូមបង្ហាញជូន។ បាទ យើងខ្ញុំមាន ២នាទីចុងក្រោយ គឺសូមបង្ហាញឯកសារនេះចុងក្រោយ។

[០៩:៣៤:៤១]

នេះ គឺជាឯកសារ 3.5 យើងឃើញហើយថា ផៅ វ៉ា ហៅ ណាត ឯកសារនេះថតនៅហុងកុង ហើយរូបថតមួយទៀតខាងស្តាំ គឺរូបថត១នៅស-២១។ ចំណុចចុងក្រោយកាលៈទេសៈនៃការចាប់ខ្លួន និងការវិលត្រឡប់មកប្រទេសកម្ពុជាទៅលើបុគ្គលរូប គឺមានការពិភាក្សាគ្នា នៅក្នុង-- ដោយ ឌុច ដែល

នៅក្នុងនេះគឺយើងឃើញមានលើកឡើងនៅក្នុងឯកសារ D119។ ដូច្នេះហើយ យើងនឹងធ្វើការលើកឡើងនូវឯកសារនីមួយៗ ដែលវាមានឧទាហរណ៍ជាច្រើន ដែលសារទូរលេខ លិខិត សេចក្តីសម្រេចបង្គាប់បញ្ជា កំណត់ត្រាផ្សេងៗ រួមទាំងរបាយការណ៍ផងដែរ រួមមានព័ត៌មានស៊ីសង្វាក់គ្នាទៅនឹងឯកសារដទៃទៀត ដែលសាក្សីបានលើកឡើង។ ហើយជាការពិត ពាក់ព័ន្ធទៅនឹងសារទូរលេខ លិខិត របាយការណ៍ កម្មាភិបាលមួយចំនួនបានពន្យល់អំពីស្ថានភាព និងកាលៈទេសៈណា ដែលឯកសារទាំងអស់នោះបានរៀបចំឡើង។

ដូច្នេះហើយ វាអាចឲ្យយើងបង្ហាញជូនអង្គជំនុំជម្រះ នូវកំណត់សម្គាល់ផ្សេងៗ ដែលបង្ហាញអំពីរបបកម្ពុជាប្រជាធិបតេយ្យ និងបក្សកុម្មុយនីស្តកម្ពុជា ដែលទាំងអស់នេះជាឯកសាររបស់ពួកគេ។

ខ្ញុំគិតថាចំណុចនេះ គឺខ្ញុំដល់ទីបញ្ចប់ហើយ ខ្ញុំ ហើយខ្ញុំក៏អស់ពេលវេលាផងដែរ។ ខ្ញុំរីករាយនឹងធ្វើការបង្ហាញបន្ថែមទៀតប្រសិនបើលោក លោកស្រីចៅក្រមគិតថា សមរម្យចង់ឲ្យខ្ញុំបង្ហាញនោះ។ សូមអរគុណច្រើន។

[០៩:៣៦:១៩]

**ប្រធានអង្គជំនុំ៖**

អរគុណសហព្រះរាជអាជ្ញារងអន្តរជាតិ។ ជាកិច្ចបន្ត អង្គជំនុំជម្រះប្រគល់តួនាទីដល់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសក្នុងការធ្វើអំណះអំណាងតបទៅនឹងការជំទាស់នឹងឯកសារឧបសម្ព័ន្ធ A4 ដោយក្រុមមេធាវីការពារក្តី។

សូមអញ្ជើញ!

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន មេធាវីនាំមុខសូមប្រគល់សិទ្ធិនេះជូនទៅលោក ឡោ ជុនធី ជាមេធាវីមកពីក្រុមមេធាវីការពារផ្នែកជំនួយផ្នែកច្បាប់កម្ពុជា។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អនុញ្ញាតតាមការស្នើសុំ។ សូមអញ្ជើញ លោកមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលទទួលសិទ្ធិ។

**លោក ឡោ ជុនធី៖**

បាទ ជាបឋមខ្ញុំបាទសូមគោរពអង្គជំនុំជម្រះទាំងមូល សូមគោរពសហភាគា ហើយសូមគោរព

អ្នកដែលចូលរួមមើលនៅពេលនេះ។ ខ្ញុំបាទ ឡោ ជុនធី ជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២ នេះ ហើយឥឡូវនេះ គឺខ្ញុំសូមធ្វើការឆ្លើយតបទៅលើប្រធានបទដែលពាក់ព័ន្ធនឹងឧបសម្ព័ន្ធទី៤ ដែលបានលើកឡើងនៅក្នុងវគ្គនេះ។

ដោយយោងទៅលើឯកសារ E159 ដែលបានកំណត់ទៅដោយតុលាការ ហើយនៅក្នុងចំណុចទី៨ ដែលមានចំណុចឧបសម្ព័ន្ធ A4 ដែលនៅក្នុងនោះគឺមានឯកសារ E9/31.3 នៅក្នុងនោះមានឯកសារពាក់ព័ន្ធគឺ E109/4.4 ហើយឯកសារទាំងអស់គឺមាន ៣៩៤ ឯកសារឯណោះ។

អ៊ីចឹងខ្ញុំសូមកត់សម្គាល់នៅលើពីរចំណុច ដែលអ្វីដែលបានលើកឡើងនោះគឺ ទីមួយគឺខ្ញុំសូមលើកអំពីបរិបទទូទៅមួយ ដែលបង្ហាញអំពីថា តើសក្តានុពលនៃឯកសារដែលយើងបានប្រមូលមកនៅតុលាការនេះ ហើយមានយថាភាព មានភាពអាចជឿជាក់បាន ហើយមានភាពពាក់ព័ន្ធនឹងយ៉ាងដូចម្តេចនោះ ខ្ញុំសូមលើកនូវបីចំណុចទៀត គឺថាមានចំណុច ក គឺពាក់ព័ន្ធនឹងតថភាពនៃឯកសារ, ចំណុច ខ គឺខ្ញុំចង់លើកអំពីថា តើឯកសារហ្នឹងវាជាប្រភពមកពីណា, ហើយចំណុច គ គឺពាក់ព័ន្ធនឹងការគ្រប់គ្រងនៃឯកសារនេះ។

[០៩:៣៩:៣៩]

ចំណុច(ក) ដែលខ្ញុំចង់លើកថាតើថតភាពនៃឯកសារ បានន័យថា ឯកសារដែលយើងបានមើលឃើញនៅពេលនេះវាមានលក្ខណៈទម្រង់យ៉ាងម៉េច? អ៊ីចឹងដូចសហព្រះរាជអាជ្ញាបានលើកឡើងអម្បាញ់មិញគឺថា មានទម្រង់ជាលក្ខណៈ ថាពីលើមកមានការបញ្ជា មានអីត្រឹមត្រូវ។ ហើយចំណុចមួយទៀតយើងពិនិត្យមើលថា តើឯកសារហ្នឹងវាពាក់ព័ន្ធនឹងចំណុចគោលដៅយ៉ាងដូចម៉េច? គឺថានៅក្នុងឯកសារហ្នឹង គឺមានចង្អុលបង្ហាញនូវគោលដៅនៃគំនិតនៅក្នុងនុ៎ង ថាតើគំនិតនៃឯកសារហ្នឹង គេប្រើប្រាស់យ៉ាងដូចម៉េច?

ចំណុចមួយទៀត ដែលខ្ញុំចង់លើកឡើងដែរថា អ្វីដែលមានចំណុចដែលចែងនៅក្នុងជាទម្រង់ហើយជាគំនិត ជាគោលដៅនៅក្នុងឯកសារទាំងអស់នោះ បានបង្ហាញនូវភាព ដែលហៅថា ពីភាពជឿទុកចិត្តបាន បានន័យថា អាចប្រើប្រាស់បាន។ ហើយចំណុច ខ គឺពាក់ព័ន្ធនឹងប្រភព យើងពិនិត្យមើលលើឯកសារទាំងអស់នោះ គឺថាប្រភពនៅ-- គឺថាចេញមកពីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យតែម្តងគឺថាក្នុងរយៈពេលឆ្នាំ៧៥ដល់៧៩នេះឯង។

ហើយយើងពិនិត្យមើលចំណុចមួយទៀត ថាតើនរណាដែលជាបង្កើត និងបង្កនូវឯកសារនេះ?

បានន័យថា ជាបណ្តាញ ជាភ្នាក់ងារជាអ្នកដែលបង្កើតនូវឯកសារនេះ។ ដូចខាងសហព្រះរាជអាជ្ញាបានបញ្ជាំងអម្បាញ់មិញ ថាបានមានសាក្សីមួយចំនួនដែលបញ្ជាក់អំពីឯកសារនេះ ថាតើគាត់បង្កើតឯកសារនេះយ៉ាងម៉េច? ហើយក្នុងនោះ យើងពិនិត្យនូវចំណុចមួយទៀត ថាតើឯកសារហ្នឹងហើយវាមានលក្ខណៈយ៉ាងម៉េច? វាជារបាយការណ៍ វាជាបញ្ជា វាជាអ្វីអស់ហ្នឹង ហើយគេប្រើប្រាស់យ៉ាងម៉េច? ប្រើប្រាស់ដើម្បីក្តោបក្តាប់អំណាចរបស់កម្ពុជាប្រជាធិបតេយ្យនេះឯង។

[០៩:៤១:៥០]

សរុបមក គឺថាប្រព័ន្ធនៃការបញ្ជូនឯកសារ ជាសារទូរលេខក្តី ជាបទបញ្ជាក្តី ជារបាយការណ៍អីគឺថាជាការគ្រប់គ្រង ជាការបង្ហាញថាឱ្យឃើញថាក្នុងរបបនោះ គឺមានការគ្រប់គ្រង និងរចនាសម្ព័ន្ធច្បាស់លាស់សម្រាប់កម្ពុជាប្រជាធិបតេយ្យ។ ហើយពាក់ព័ន្ធនឹងចំណុច(គ)៦ ខ្ញុំសូមលើកឡើងថាវាមានការប្រមូលនិងការគ្រប់គ្រងឯកសារ ហើយយើងតាមអ្វីដែលជាក់ស្តែងនៅក្នុងឆ្នាំ១៩៩៥នេះ គឺមានខាងមជ្ឈមណ្ឌលឯកសារគឺ ឌី.ស៊ី.ខេម នេះឯង ដែលជាស្ថាប័នមួយ ដែលគាត់បានប្រមែប្រមូលនូវឯកសារដែលយើង-- ឯកសារខ្លះយើងមិនស្មានដល់ផង ហើយប្រជាជនកម្ពុជាយើង ដែលកើតឡើងមក គឺថាត្រដាបត្រដួសរកបាយហូបមិនបាន ហើយទៅនឹកឃើញអីប្រមែប្រមូលឯកសារ។ អ៊ីចឹងហើយ ឯកសារមួយ ចំនួនដែលសំខាន់នោះ វាបាត់ អាចបាត់។ អ៊ីចឹង បានជាមជ្ឈមណ្ឌលនេះ គាត់បានប្រមែប្រមូល។ ប្រមែប្រមូល សួរថាគាត់-- តើគាត់ ស្ថាប័នដែលគាត់ធ្វើការប្រមែប្រមូលនេះ ជាលក្ខណៈយ៉ាងម៉េច? បានលើកឡើងថា មិនឯករាជ្យ ឬលម្អៀង។ តាមពិត គាត់ជាស្ថាប័នមួយដើម្បីស្វែងរកនូវការពិត កាលនោះ បាទ ប៉ុន្តែថៃដន្យ គឺថារាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិបានបង្កើតតុលាការនេះឡើង អ៊ីចឹងវាជាប្រភពនៃឯកសារមួយ ទោះបីថាកន្លែងខ្លះវាមិនច្បាស់លាស់ កន្លែងខ្លះអាចទទួលយកបានក៏ដោយ គឺថាយើងជាប្រភពសម្រាប់ពិចារណាមកដល់ថ្ងៃនេះ។

[០៩:៤៣:៣៤]

ហើយអាចទទួលពីស្ថាប័នបណ្ណសារជាតិ ទទួលពីទួលស្លែង អាចទទួលពីបុគ្គលផ្សេងដែរ។ បុគ្គលនោះ បានន័យថាបុគ្គលគាត់ជួនកាលគាត់ជាសម័យនោះ គាត់ជាអ្នកដែលធ្វើនីរសារហ្នឹងផ្ទាល់ ហើយគាត់ឮថាមានការប្រមូលឯកសារ ក៏គាត់បានយកមកជូនឲ្យ។

ដូច្នេះ ពាក់ព័ន្ធចំណុចនេះ ខ្ញុំចង់បញ្ជាក់ថាប្រសិនបើយើងស្រាវជ្រាវរកអ្នកដែលថាមកប្រគល់មកទទួល ហើយតាំងពីសម័យនោះ វាមានការលំបាកមែនទែន។ ហើយមានការរៀបចំគ្រប់គ្រង ហើយ

និងរៀបចំទុក គឺសម្រាប់មកដល់ពេលនេះ ដែលរៀបចំទុក ទីមួយ គឺពាក់ព័ន្ធនឹងប្រវត្តិសាស្ត្រ។ ទីពីរ ពាក់ព័ន្ធនឹងការប្រព្រឹត្តទៅនៃតុលាការនេះឯង។

ខ្ញុំចូលទៅចំណុចទីពីរ គឺការតបទៅនឹងចំណុចជាក់ស្តែងដែលខាងមេធាវីការពារបានលើកឡើង។ ចំណុចមួយនោះ ខ្ញុំសូមលើកថា លោកបានយោងទៅនឹងតុលាការ អាយ.ស៊ី.ធី.វ៉ាយ ដែលក្នុងតុលាការ អាយ.ស៊ី.ធី.វ៉ាយ នោះ បានកោះអញ្ជើញជាអ្នកដែលធ្វើសារទូរលេខ ធ្វើស្អីហ្នឹង គឺថាមកបញ្ជាក់នៅតុលាការបាន។

[០៩:៤៤:៥៥]

យើងនេះ ក៏អាចកោះអញ្ជើញមកបានដែរ ប៉ុន្តែអ្វីដែលជាការសោកស្តាយនោះ គឺថារយៈពេលពីនោះ មកដល់ពេលនេះនៃតុលាការយើង វាមានការជាក់ស្តែងគឺ៣០ឆ្នាំជាងហើយ។ ខ្លះគឺបានស្លាប់បាត់នៅក្នុងសម័យ ប៉ុល ពត ហើយខ្លះរយៈពេល៣០ឆ្នាំមកចាស់បានស្លាប់ហើយ។ អ៊ីចឹងជាអ្នកដែលមានសំណាងគឺដូចខាងសហព្រះរាជអាជ្ញា បានលើកឡើងអម្បាញ់មិញ គឺថាមានអ្នកសំណាងមួយចំនួនហ្នឹង គឺនឹងមកបង្ហាញនៅក្នុងអង្គតុលាការនេះ។

[០៩:៤៥:៣០]

អ៊ីចឹងអ្វីដែលការយោងទៅតុលាការ អាយ.ស៊ី.ធី.វ៉ាយ នោះគឺថាមានចំណុចល្អហើយ ប៉ុន្តែអ្វីដែលនៅបរិបទនៅកម្ពុជាគឺ ដូចខ្ញុំបានលើកឡើងអម្បាញ់មិញគឺថា ទីមួយ អាចថា រយៈពេលយូរពេកយូរពេកគាត់ចាស់ស្លាប់។ ទីពីរ គឺគាត់ចាស់ គាត់មិនអាចផ្តល់សក្ខីកម្មបាន។ អាហ្នឹងជាចំណុចសំខាន់សម្រាប់តុលាការពិចារណា។

ចំណុចពាក់ព័ន្ធមួយទៀតថា ចម្លើយសារភាព ដែលពាក់ព័ន្ធនឹងការធ្វើទារុណកម្មវិលមិញគឺខាងសហព្រះរាជអាជ្ញាក៏បានលើកឡើងហើយ តែអ្វីដែលខ្ញុំសូមបន្ថែមនោះគឺថា ប្រធានបទនេះគឺយើងនឹងមានការជជែកគ្នានៅប្រធានបទក្រោយ។

ចំណុច(គ) ដែលលើកឡើងពាក់ព័ន្ធនឹងដើមបណ្តឹងរដ្ឋប្បវេណីដែលថា ៤០០០នាក់នោះ គឺថាតាមការពិតគឺមានចំនួនប្រាកដគឺ ៣៨៦៦នាក់។ នេះគឺ អ្វីដែលដើមបណ្តឹងរដ្ឋប្បវេណីពិតប្រាកដ ហើយខ្ញុំសូមបញ្ជាក់ថា ដើមបណ្តឹងរដ្ឋប្បវេណីដែលនឹងឡើង-- ដែលបានដាក់ស្នើសុំឲ្យតុលាការស្តាប់នូវសក្ខីកម្មនោះគឺ ប្រហែលជា១៥០នាក់។ ហើយនៅក្នុងចំណោម១៥០នាក់នេះ ក៏ដើមបណ្តឹងមួយចំនួនតូចទេ ដែលនឹងបង្ហាញខ្លួននៅក្នុងសវនាការវគ្គដំបូងនេះ។ ដូច្នេះ ខាងមេធាវីការពារកុំមានការបារម្ភ

ច្រើនពេក ព្រោះថា មានតិចតួចសម្រាប់ពិចារណាជាមួយពួកគាត់។

[០៩:៤៧:៣៣]

ចំណុចមួយទៀត ដែលខ្ញុំចង់បញ្ជាក់នោះគឺថា ពួកគាត់ដែលឡើងមកថ្លែងសក្ខីកម្មគឺ ក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមតិមួយចំនួនបានយល់ច្រឡំនោះថា គាត់ឡើងមកក្នុងនាមជាសាក្សី។ អ៊ីចឹងមិនមែនទេ គឺឡើងមកជាដើមបណ្តឹងរដ្ឋប្បវេណី។

ចំណុចសំខាន់មួយទៀត ដែលខាងមេធាវីការពារបានលើកឡើងថា ឈ្មោះកូនក្តីរបស់លោកគេដាក់ចម្លងជូន។ ថាតើគាត់បានទទួលឬទេ? នេះចំណុចនេះ! ដែលខ្ញុំចង់បញ្ជាក់នោះថា បើយើងពិនិត្យទៅលើបទដ្ឋានសម័យនោះ បទដ្ឋានសម័យនោះថាគេប្រើអី? គេប្រើនីរសារ ហើយសួរថា នីរសារ? នីរសារគាត់ជាអ្នកបញ្ជូនសំបុត្របញ្ជូនសារ ពីបុគ្គល ឬមួយពីស្ថាប័នទៅបុគ្គលនៃស្ថាប័នមួយទៀត។ អ៊ីចឹងនីរសារនេះ គឺមានលក្ខណៈសំខាន់ ហើយជាបុគ្គលដែលគេទុកចិត្តណ៎ា ដោយហេតុថា អ្នកដែលនីរសារហ្នឹងគឺមានការស្មោះត្រង់ ចំពោះអ្វីដែលជាអង្គភាពរបស់គេធ្វើការប្រគល់នូវភារកិច្ចនេះ។ ហើយនីរសារជំនាន់នោះគឺ បើនៅតាមជនបទ គឺភាគច្រើនគាត់ជិះសេះទៀត។

[០៩:៤៩:០២]

អ៊ីចឹងជាការបញ្ជូនសំបុត្រ ហើយអ្វីដែលយើងចង់បញ្ជាក់ថា ទទួល ឬមិនបានទទួល ប្រសិនបើនីរសារហ្នឹង បញ្ជូនសំបុត្រទៅមិនបានទទួល អ្នកនុ៎ងប្រហែលជាមិនអាចជានីរសារបានយូរទេ។ ដូច្នេះចំណុចនេះខ្ញុំចង់បញ្ជាក់ថា ការដែលដាក់ឈ្មោះថា ចម្លងជូន គឺមានការប្រាកដណាស់ថា គាត់នឹងបានទទួលនូវព័ត៌មាននេះ។

ចំណុចដែលចុងក្រោយ ដែលខ្ញុំចង់ធ្វើការកត់សម្គាល់ទៅលើឯកសារនោះដែរ គឺចំណុចទីមួយគឺមានឯកសារលេខ D366/7.1.338។ ខ្ញុំចង់បញ្ជាក់ថា ឡើងវិញ គឺអ្វីដែលយើងបានពិនិត្យទៅលើឯកសារនេះ គឺថាឃើញពីលក្ខណៈទម្រង់មានលំដាប់លំដោយត្រឹមត្រូវ មានការសរសេរត្រឹមត្រូវណ៎ា មានខ្លឹមសារត្រឹមត្រូវ មានការចុះកាលបរិច្ឆេទទៀត។ អ៊ីចឹង បានន័យថា វាជាលក្ខណៈមួយ បានន័យថា ចង់បញ្ជាក់ថា ខាងមេធាវីការពារបានលើកឡើងថា អ្នកដែលធ្វើហ្នឹងគាត់មានជំនាញត្រឹមណា? មានកម្រិតវប្បធម៌ត្រឹមណា? មានស្អីត្រឹមណា? អ៊ីចឹងបើយើងពិនិត្យទៅអ្វីដែលជាតថភាពជាក់ស្តែងនៃឯកសារនេះ គឺថាមើលទៅ គឺថាអ្នកហ្នឹងបើមិនចេះមិនជំនាញ មិនដឹងអីសោះ ក៏មិនអាចធ្វើឯកសារនេះបានដែរ។ ហើយប្រើពាក្យពេចន៍ដែលពាក់ព័ន្ធទៅនឹងកម្ពុជាប្រជាធិបតេយ្យទាំងអស់។

[០៩:៥១:០៦]

ហើយក៏ដូចជាឯកសារសារទូរលេខមួយ ដែលមានលេខ D108/28.1 ដែរ។ ក្នុងនោះគេដាក់បន្ទាត់ទីមួយខាងឆ្វេងហ្នឹង គឺដាក់ "លេខ៣១" ហើយក្រោមលេខ៣១ ដាក់ "២៦៥ខ្ទង់" ន៎ែ ហើយគេដាក់ថា គោរពជូន ម.៨៧០ ជាទីស្នេហា និងនឹករឭក ន៎ែ សុទ្ធតែភាសាក្នុងសម័យនោះ។ ដូច្នេះខាងក្រោមនេះមានចម្លងជូន អ៊ំ នួន, បង វ៉ាន់, បង វន, បង ខៀវ, មន្ទីរ និងឯកសារ។ អ៊ីចឹងនេះ គឺជាបែបបទមួយសម្រាប់សម័យនោះគេប្រើប្រាស់ ហើយប្រាកដណាស់ថាអ្នកទាំងអស់នោះនឹងទទួលបាន។

ហើយក៏ដូចជាឯសារមួយទៀត ដែលមានលេខ D108/2681 ដែរ ដែលខាងមេធាវីការពារបានលើកឡើងដែរ គឺថាមើលទៅបែបមិនច្បាស់។ អានេះ គឺថាការវាយដាក់ទីឡូជំនាន់នោះ ហើយវាមានការវិវត្តន៍ច្រើន មកទៀត គឺថាវាមានស្លាកស្នាមដែលមានលក្ខណៈមិនច្បាស់។ ប៉ុន្តែខាងលើយើងមើលច្បាស់ គឺថាទៅ "មន្ទីរ ស-២១ ភ្នំពេញ" ឃើញទេ ច្បាស់មែនទែន "បងជាទីគោរព"។ អ៊ីចឹងសុទ្ធតែជាភាសាដែលសម័យនោះបានធ្វើ។ ហើយបើថ្ងៃខែវិញ គឺលក្ខណៈស៊ីសង្វាក់គ្នា ខាងលើគឺថាថ្ងៃ៣១ ឧសភា ឆ្នាំ១៩៧៦ ហើយដល់ខាងក្រោមថ្ងៃដែលបានគោរពជូន ដែលធ្វើឯកសារនោះ គឺថាថ្ងៃ០១ មិថុនា ១៩៧៧។ អ៊ីចឹង បានន័យថា វាស៊ីគ្នា បានន័យថា លំដាប់លំដោយនៃឯកសារបានត្រឹមត្រូវ។

[០៩:៥៣:១២]

ដូច្នេះ ខ្ញុំបាទសូមបញ្ជាក់ជូនជារឿងជាក់ស្តែងនូវពាក់ព័ន្ធនឹងឯកសារនេះ។ ហើយខ្ញុំសូមគោរពអង្គជំនុំជម្រះ ហើយសូមមេត្តាពិចារណានៅលើឯកសារដែលយើងប្រមូលបាន ហើយយើងនឹងពិចារ-ណាទៅលើចំណុចដែលពាក់ព័ន្ធ ដែលខ្ញុំបានលើកឡើងនេះ វាជាភាពដែលជឿទុកចិត្តបាន ហើយភាពដែលមានការពាក់ព័ន្ធ។ ហើយចំណុចអស់នេះ យើងអាចយកមកជាឯកសារភស្តុតាងនៅក្នុងតុលាការនេះ។ បាទ សូមអរគុណ។

[០៩:៥៣:៥២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។

ហើយជាកិច្ចបន្ត គឺយើងធ្វើសវនាការលើជំទាស់ទៅនឹងឯកសារសម័យកម្ពុជាប្រជាធិបតេយ្យ ដែលអង្គជំនុំជម្រះសាលាដំបូងមានបំណងដាក់ចំពោះមុខខ្លួន គឺបន្តការស្តាប់ជំទាស់ពាក់ព័ន្ធនឹងឯកសារក្នុងឧបសម្ព័ន្ធ A5។ ក្រុមមេធាវីការពារក្តីនីមួយៗ មានរយៈពេល៤០នាទី នៅក្នុងការបង្ហាញពីការ

ជំទាស់របស់ខ្លួន លើកលែងតែក្រុមមេធាវីការពារក្តីទាំងបីក្រុមមានការបែងចែកពេលវេលាដែលផ្តល់ឲ្យខុសពីនេះ។

ហើយជាដំបូងនេះ អង្គជំនុំជម្រះសូមប្រគល់វេទិកាទៅមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសនៅក្នុងការបង្ហាញអំពីការជំទាស់របស់ខ្លួន ពាក់ព័ន្ធនឹងឯកសារក្នុងឧបសម្ព័ន្ធA5។

សូមអញ្ជើញ!

[០៩:៥៥:០៥]

**លោក ម៉ៃខល ផេសមិនៈ**

សូមអរគុណលោកប្រធាន ខ្ញុំនឹងលើកឡើងដោយសង្ខេប ដើម្បីចៀសវាងការលើកឡើងច្រំដែលដដែលៗ។ ឯកសារ ឌី.ស៊ី.ខេម យើងបានលើកឡើងយ៉ាងច្រើនរួចមកហើយ យើងស្វាគមន៍នូវការប្រកាសរបស់សហព្រះរាជអាជ្ញានៅព្រឹកមិញ ថាគាត់នឹងផ្តល់បញ្ជូនបញ្ជីនៃឯកសារដែលគាត់ទទួលបានពី ឌី.ស៊ី.ខេម ហើយយើងនឹងសិក្សាទៅលើឯកសារទាំងអស់នោះ។

ជាការពិតការទទួលយកឯកសារទាំងអស់នោះ ដូចដែលយើងបានលើកឡើងក្នុងអាទិត្យនេះមកហើយ គឺវាជាកម្មវត្ថុនៃការស្តាប់ចម្លើយលោក ឆាំង យុ នៅក្នុងតុលាការនេះ។ ដូច្នេះហើយមេធាវីការពារក្តី នៅពេលនោះនឹងអាចធ្វើការដេញដោលសួរឆ្លងទៅកាន់គាត់។

ចំពោះពាក់ព័ន្ធទៅនឹងភាពពាក់ព័ន្ធនៃឯកសារ សហព្រះរាជអាជ្ញាបានលើកឡើងនូវយោបល់កំណត់សម្គាល់របស់ខ្លួនរួចមកហើយពាក់ព័ន្ធទៅនឹងភាពពាក់ព័ន្ធនៃឯកសារទាំងអស់នោះ។ យើងឯកភាពអំពីវិសាលភាពនៃសវនាការតូចបឋម វាមិនកម្រិតទៅលើការជម្លៀសប្រជាជននៅក្នុងទីក្រុងភ្នំពេញ ឬក៏ការបញ្ជូនប្រជាជនពីខាងត្បូងទៅខាងជើងនោះទេ។

[០៩:៥៦:២១]

ប្រធានបទនៅក្នុងដំណាក់កាលដំបូងនេះ គឺវាពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធ រចនាសម្ព័ន្ធបញ្ហា ការប្រាស្រ័យទាក់ទងគ្នានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះហើយ យើងបង្ហាញជំហរថា យើងឯកភាពជាមួយនឹងខាងសហព្រះរាជអាជ្ញា នៅពេលដែលសាលាដំបូងធ្វើការពិនិត្យទៅលើប្រធានបទទាំងអស់នោះ ដែលជាប្រធានបទបន្ថែម វាពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធនៃបក្សនិងរដ្ឋាភិបាល។ អង្គជំនុំជម្រះគួរផ្តោតការយកចិត្តទុកដាក់ទៅលើរយៈពេលដែលពាក់ព័ន្ធ គឺរយៈពេលដែលពាក់ព័ន្ធនៃការជម្លៀសប្រជាជននៅក្នុងទីក្រុងភ្នំពេញ ហើយនិងការជម្លៀសប្រជាជន ផ្លាស់ទីលំនៅប្រជាជននៅក្នុងដំណាក់

កាលទីពីរ។

ខ្ញុំសូមលើកជាឧទាហរណ៍មួយ សហព្រះរាជអាជ្ញាបានលើកឡើងឧទាហរណ៍ៗកាលពីព្រឹកមិញ ថាតើ អៀង ធីរិទ្ធ ទទួលបានដំណឹងនៅខែកក្កដា ឆ្នាំ១៩៧៨ ដែរឬទេ? ថាតើលោកស្រី អៀង ធីរិទ្ធ ទទួលបានការជូនដំណឹងអំពីការដឹងស្មារតីនយោបាយដែរឬទេ?

[០៩:៥៧:៣២]

យើងសូមលើកឡើងថា វាពាក់ព័ន្ធនៅក្នុងសវនាការតូចដំណាក់កាលដំបូងរបស់យើង។ វាពាក់ព័ន្ធទៅនឹងសវនាការវគ្គដំបូង។ ទោះបីជាវាពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធនៃក្រសួងនៅក្នុងឆ្នាំ១៩៧៨ នោះក៏ដោយ។ វាមិនឲ្យយើងយល់ច្រឡំទៅលើអ្វីដែលយើងបានពិភាក្សានៅក្នុងសវនាការតូច វគ្គដំបូងនោះទេ។ ដូច្នេះហើយ យើងសង្កត់ធ្ងន់ថា យើងគួរតែពិភាក្សាទៅលើរចនាសម្ព័ន្ធនៃបក្ស និងរដ្ឋាភិបាល និងរយៈពេលដែលពាក់ព័ន្ធទៅនឹងការជម្លៀសប្រជាជននៅក្នុងទីក្រុងភ្នំពេញ។ ហើយនិងការជម្លៀសផ្លាស់ទីលំនៅប្រជាជនពីខាងត្បូង ពីទិសខាងត្បូងទៅខាងជើងផងដែរ។

[០៩:៥៨:១៦]

ដូច្នេះ អ្វីដែលយើងខ្លាចថានឹងកើតឡើងនោះ គឺថាសហព្រះរាជអាជ្ញា គាត់នឹងឆ្លៀតយកឱកាសនេះក្នុងការបង្ហាញភស្តុតាងដាក់បញ្ចូលនៅក្នុងសវនាការតូច វគ្គដំបូងដើម្បីធ្វើការពង្រីកវិសាលភាពនៃសវនាការវគ្គដំបូងនេះ។

វាជាឧទាហរណ៍មួយល្អ ដែលសហព្រះរាជអាជ្ញាបានលើកឡើងកាលពីព្រឹកមិញនៅពេលដែលគាត់បង្ហាញអំពីឯកសារមួយចំនួន ដែលវាពាក់ព័ន្ធទៅនឹងមន្ទីរ ស-២១។ ហើយនិងការចោទប្រកាន់ទៅលើការបោសសម្អាតបុគ្គលដែលរស់នៅក្នុងទីក្រុងហុងកុង ចំពោះមន្ទីរដែលបានបង្កើតឡើងនៅក្នុងសម័យរបបកម្ពុជាប្រជាធិបតេយ្យ។

ដូច្នេះថាតើមានការកម្ទេចមន្ទីរនេះដែរឬទេ? ហើយបុគ្គលនោះ ត្រូវបានបញ្ជូនទៅស-២១ ដែរឬទេ? ដូចដែលយើងបានដឹងហើយ ក្រោយពីការជម្លៀសទីក្រុងភ្នំពេញ យើងបានដឹងទាំងអស់គ្នា។ ហើយថាតើជនជាប់ចោទទាំងអស់នោះ គាត់បានដឹងអំពីហេតុការណ៍ទាំងអស់នេះដែរឬទេ?

យើងសូមលើកឡើងថា ចំណុចនេះគឺវាមិនពាក់ព័ន្ធនៅក្នុងសវនាការវគ្គដំបូងនោះឡើយ។ វាមិនមាននៅក្នុងរបៀបវារៈនៃសវនាការនេះទេ។ យើងនឹងពិភាក្សាអង្គហេតុនេះនៅក្នុងដំណាក់កាលក្រោយយ៉ាងលម្អិត។

ដូច្នេះហើយ ខ្ញុំសូមអញ្ជើញអង្គជំនុំជម្រះសាលាដំបូងសាជាថ្មីឲ្យពិចារណាទៅលើបញ្ជីឯកសារដែលបានផ្តល់ជូនដោយអង្គជំនុំជម្រះ ដោយយកចិត្តទុកដាក់ ហើយនិងច្រានចោលភស្តុតាងទាំងឡាយណាដែលវាមិនពាក់ព័ន្ធ ឬក៏វាមិនជាប់ទាក់ទងទៅនឹងវិសាលភាពនៃការជំនុំជម្រះសវនាការវគ្គដំបូង។

[១០:០០:០០]

ចំពោះបញ្ហាពាក់ព័ន្ធទៅនឹងឯកសារដទៃទៀត ឯកសារទាំងឡាយដែលទទួលយកបានតាមភស្តុតាងមួយក្រឡេកភ្នែក គឺឯកសារទាំងអស់នោះមិនបានផ្តល់ជូនដោយ ឌី.ស៊ី.ខេម។ ដូច្នេះ យើងខ្ញុំសូមបង្ហាញជំហររបស់យើងខ្ញុំ ដូចដែលយើងខ្ញុំបានបង្ហាញនៅដើមសប្តាហ៍នេះរួចមកហើយថាភស្តុតាងទាំងអស់នោះគួរតែទទួលយកបាន ក៏ប៉ុន្តែប្រសិនបើភស្តុតាងទាំងអស់នោះ ឯកសារទាំងអស់នោះ មានភស្តុតាងពាក់ព័ន្ធទៅនឹងតួនាទីរបស់ជនជាប់ចោទ ឬក៏បញ្ហាសំខាន់ៗនៅក្នុងឯកសារនោះ។ ឯកសារទាំងអស់នោះគួរតែដាក់នៅចំពោះមុខកូនក្តីបរស់ខ្ញុំ ដើម្បីឲ្យគាត់ផ្តល់សក្ខីកម្ម។ ហើយប្រសិនបើចាំបាច់នោះ អ្នកដែលរៀបចំឯកសារទាំងអស់នោះ គួរតែអញ្ជើញមកផ្តល់ជាចម្លើយសក្ខីកម្មនៅក្នុងសវនាការនេះផងដែរ។ សូមអរគុណច្រើន។

[១០:០០:៥៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ សូមអញ្ជើញលោកមេធាវីជាតិ!

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ សូមគោរពលោកប្រធាន! នៅក្នុងឧបសម្ព័ន្ធ៥ លេខE9/31.4 មាននិយាយតែអំពីរបាយការណ៍ពីម្នាក់ទៅម្នាក់ ពីថ្នាក់ក្រោមទៅថ្នាក់លើ ពីកងឯកភាព ឬមន្ទីរមួយទៅមន្ទីរមួយទៀត។ល។ អំពីតួលេខពីម្នាក់ទៅម្នាក់ ពីកងឯកភាពមួយទៅកងឯកភាពមួយទៀត ពីភូមិភាគមួយទៅភូមិភាគមួយទៀត។ សេចក្តីថ្លែងការណ៍របស់ហ្រ្គុង ដែលធ្វើឡើងដោយព្រះអង្គម្ចាស់ នរោត្តម សីហនុ ស្តីអំពីសមាសភាពរដ្ឋាភិបាលហ្រ្គុង នៅថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៧៤ មានការបោះពុម្ពផ្សាយរបស់ហ្គុង មានចំណងជើងថា “ព័ត៌មានកម្ពុជា” មានឯកសារលេខ D366/7.1.4-- .1.455 ពីថ្ងៃ៣ ខែឧសភា ឆ្នាំ១៩៧០ ដែលមានលេខរៀងរហូតដល់ IS18.1 ដល់ IS12.3 នៅថ្ងៃទី២៨ សីហា ឆ្នាំ១៩៧៥។ មានរបាយការណ៍សារព័ត៌មានកម្ពុជាប្រជាធិបតេយ្យលេខ D262.13 ចុះថ្ងៃទី៣ ធ្នូ ១៩៧៥ និងរបាយការណ៍មួយចំនួនទៀត ព្រមទាំងសេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ

មួយចំនួនទៀតដែរ។ បូកទាំងរបាយការណ៍សារព័ត៌មានកម្ពុជាប្រជាធិបតេយ្យច្រើនលេខនិយាយ អំពីការលុកលុយរបស់កងទ័ពវៀតណាមធ្វើដោយឈ្មោះ ត្រាន់ វ៉ាន់តៃ ជាយោធាវៀតណាមដែលកម្ពុជាប្រជាធិបតេយ្យចាប់បាន ពេលដែលវៀតណាមវាយចូលលុកលុយដល់ប្រទេសកម្ពុជា បានសារភាពប្រាប់កងទ័ពបដិវត្តន៍កម្ពុជាថ្ងៃ២៤ មករា ឆ្នាំ១៩៧៨ ឯកសារលេខ IS12.26 ។ល។

[១០:០៣:៤៥]

ចំពោះរបាយការណ៍សារទូរលេខ សេចក្តីថ្លែងការណ៍របស់ហ្សុង របស់ហ្រ្គុង ដែលធ្វើដោយព្រះអង្គម្ចាស់ នរោត្តម សីហនុ ថ្លែងការណ៍របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ និងរបាយការណ៍សារព័ត៌មានរបស់កម្ពុជាប្រជាធិបតេយ្យផងនោះ គឺសុទ្ធសឹងតែនិយាយអំពីការងារប្រចាំថ្ងៃរបស់ខ្លួន។ បើសិនជាឯកសារទាំងអស់នោះ ជាឯកសារពិតមានយថាភាពម៉ត់ចត់ ហើយដែលថតចម្លងចេញពីសំណៅដើមរបស់វា ដែលមជ្ឈមណ្ឌលឯកសារកម្ពុជា ឬពីប្រភពច្បាស់ការណ៍ណាប្រាកដជាមានមែននោះៗ កូនក្តីរបស់ខ្ញុំ នួន ជា នឹងធ្វើការឆ្លើយតបតទល់នឹងសហព្រះរាជអាជ្ញាយ៉ាងម៉ត់ចត់ យ៉ាងក្លាហានពុំមានការទើសទាល់ដូចសព្វថ្ងៃ។ ដែលបានជំទាស់និងសុំឲ្យតុលាការបង្ហាញ បញ្ជាឲ្យសហព្រះរាជអាជ្ញាបង្ហាញនូវច្បាប់ដើមមកគាត់ៗ ដើម្បីលោក នួន ជា ធ្វើការផ្ទៀងផ្ទាត់ឲ្យបានម៉ត់ចត់។ ហើយបើឯកសារនោះលោក នួន ជា ទទួលស្គាល់ថាជារបស់កម្ពុជាប្រជាធិបតេយ្យ ធ្វើឡើងកាលសម័យកាន់អំណាចមែននោះ លោក នួន ជា ពុំរារែកនូវការចោទប្រកាន់មកលើរូបលោកនោះទេ។

ហេតុនេះបានជា នួន ជា ព្រមទាំងសហមេធាវីរបស់លោក ព្រមទាំងមេធាវីការពារជនជាប់ចោទទាំងអស់ មានយោបល់ប្រហាក់ប្រហែលគ្នា ទាមទារយកឯកសារសំណៅដើមមកបង្ហាញដែលអ្វីសហព្រះរាជអាជ្ញាបានចោទប្រកាន់ ហើយខំដើរប្រមូលយកទាំងអ្វីដែលមិនត្រូវចោទប្រកាន់មកដាក់ទម្ងន់ទោសមកលើជនជាប់ចោទនោះ មិនមែនសមហេតុសមផលដែលមិនប្រកបដោយយថាភាពទាល់តែសោះ។

[១០:០៥:៥៨]

ខ្ញុំសង្កេតឃើញថា ចាប់ពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០១២ តុលាការបានចាប់ផ្តើមយកបញ្ជីឧបសម្ព័ន្ធពី១ ដល់ទី៥ មកជជែកគ្នាដើម្បីស្វែងរកការពិត ហើយផ្តល់នូវយុត្តិធម៌ និងយកជាការបាន។ នោះខ្ញុំសូមបដិសេធការចោទប្រកាន់ ដែលគ្មានភស្តុតាងជាក់លាក់យកសំណៅឯកសារដែលមិនមានយថាភាពមកសំអាងដើម្បីចោទប្រកាន់កូនក្តីខ្ញុំ។ ឧទាហរណ៍ ដូចជា ឯកសារដែលខ្ញុំបាទបានស្នើសុំ

តុលាការអនុញ្ញាតបញ្ចាំងស្លាយជូនតុលាការ និងសាធារណជនមើលកាលពីម្សិលមិញថាជាឯកសារមិនពិតប្រាកដ មិនមានភាពជាការចម្លង មានភាពជាការចម្លងសុទ្ធសាធពីសំណៅដើមនោះទេ (សូមទោស) មិនមានភាពជាការចម្លងសុទ្ធសាធពីសំណៅនាមនោះទេ។

ម្យ៉ាងវិញទៀត សហព្រះរាជអាជ្ញាក្នុងរយៈពេល៤ថ្ងៃនេះ ក៏ពុំបានបង្ហាញនូវសក្ខីកម្មច្បាស់លាស់ ថាខ្លួនបានឯកសារទាំងពាន់ៗទំព័រនេះមកពីណា? ពីកន្លែងណា? បានមកដោយរបៀបណា? ឲ្យជនត្រូវចោទយល់ច្បាស់មុននឹងចោទប្រកាន់ ហើយទទួលយកបាន។ ឯកសារទាំងពាន់ៗទំព័រដែលព្រះរាជអាជ្ញាបានទទួលស្គាល់ដោយខ្លួនឯង ហើយបោះត្រាចុះលេខដោយខ្លួនឯង នោះសម្រាប់តែដាក់បន្ទុកទោសមកលើកូនក្តីរបស់ខ្ញុំ នួន ជា និងជនត្រូវចោទឯទៀតប៉ុណ្ណោះទេ។

[១០:០៧:៤៩]

ពុំមានថ្លឹងថ្លែងរកការពិត រកយុត្តិធម៌ និងឲ្យមានប្រយោជន៍ដល់សង្គម និងសាធារណៈទាល់តែសោះ។ ដូច្នេះក្នុងនាមខ្ញុំ-- ដូច្នេះខ្ញុំក្នុងនាមជនត្រូវចោទ ខ្ញុំសុំតុលាការពិចារណា និងច្រានចោលនូវពាក្យចោទប្រកាន់មិនសមហេតុផល ដែលពុំមានយថាភាពក្នុងការចោទប្រកាន់សោះនោះ។ ចំពោះជំហររបស់មេធាវីការពារ នួន ជា នៅតែទទូចសុំឲ្យព្រះរាជអាជ្ញាបង្ហាញនូវឯកសារដើមដដែល ដើម្បីឲ្យមានយថាភាព និងយុត្តិធម៌ក្នុងតុលាការ អ.វ.ត.ក នេះ។

[១០:០៨:៣៦]

សូមបញ្ជាក់ផងដែរថាឯកសារដែលព្រះរាជអាជ្ញាមានសឹងតែទាំងអស់ ពុំមានអ្នកទទួលខុសត្រូវ គឺគ្មានហត្ថលេខា ស្នាមមេដៃ និងចុះថ្ងៃខែឆ្នាំចុះហត្ថលេខាទាល់តែសោះ។ ឯកសារទាំងអស់នេះវិលវល់ពេញទូទាំងប្រទេស ដោយពុំមានយថាភាព និងប្រាកដប្រជាទាល់តែសោះ។ តើព្រះរាជអាជ្ញាអាចយល់បានទេថា ឯកសារទាំងអស់នេះមានអ្នកដទៃ មានក្រុមជាបច្ចាមិត្តរបស់កម្ពុជាប្រជាធិបតេយ្យអាចធ្វើអ្វី ឬបង្កើតដោយចេតនាដើម្បីជាផលប្រយោជន៍របស់គេ របស់ក្រុមគេ នោះបានដែរឬទេ? នេះបើព្រះរាជអាជ្ញាពិនិត្យពិច័យឲ្យបានម៉ត់ចត់នូវឯកសារទាំងនោះ។

ចំពោះមេធាវីដើមបណ្តឹងរដ្ឋប្បវេណីមកដោះស្រាយនៅពេលថ្ងៃនេះ ចំពោះឧបសម្ព័ន្ធ៤ បានថាអ្នកដែលអាចឡើងមកធ្វើសក្ខីកម្មចំពោះតុលាការនោះ មានអ្នកស្លាប់ អ្នកខ្លះចាស់ជរាមិនអាចមកបាន ហើយអ្នកអាចមកបានក៏បានមកធ្វើសក្ខីកម្មរួចហើយដែរ។ ត្រង់ចំណុចនេះ មិនជាការពិតទេ។ ខ្ញុំយល់ស្របថា មានអ្នកអាចមកធ្វើជាសក្ខី-- ជាសាក្សី មានអ្នកខ្លះចាស់ស្លាប់នោះជាការពិត តែអ្នកដែលអាច

មកធ្វើសក្ខីកម្មនោះបាន នៅមានច្រើនណាស់។ អាយុក៏នៅធ្វើការបានៗ ឆ្លើយបាន រឿងដែលយើងបានជជែកគ្នានៅពេលនេះ។ ក្រុមមេធាវី នួន ជា បានធ្វើលិខិតស្នើសុំតាមរយៈចៅក្រមស៊ើបអង្កេតអស់ចំនួនជាងបួនឆ្នាំកន្លងទៅហើយ ដែលសហចៅក្រមស៊ើបអង្កេតបានធ្វើការកោះហៅ តែសាក្សីនោះបដិសេធមិនមក នេះជាសមត្ថកិច្ចរបស់តុលាការចំពោះសាក្សីមានផលប្រយោជន៍ទាំងនោះ។

[១០:១១:០០]

ហេតុដូចខ្ញុំបានជម្រាបតុលាការពេលនេះ ខ្ញុំសូមតុលាការច្រានចោលនូវការចោទប្រកាន់នៅឧបសម្ព័ន្ធ៥ នេះចោល។ មេធាវី នួន ជា នៅតែរក្សានូវការទទួចសុំឲ្យព្រះរាជអាជ្ញាផ្តល់នូវឯកសារដើមមានយថាភាពប្រាកដប្រជា មានតម្លៃមកបង្ហាញចំពោះតុលាការ និងចំពោះសាធារណជន ដើម្បីឲ្យលោក នួន ជា អាចតបតដោយសុទ្ធចិត្តទៅព្រះរាជអាជ្ញាវិញ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណលោកមេធាវី ហើយជាកិច្ចបន្ត អង្គជំនុំជម្រះផ្តល់វេទិកាទៅមេធាវី ក្រុមមេធាវីការពារក្តីលោក អៀង សារី។ សូមអញ្ជើញ!

[១០:១១:៥៥]

**លោក ម៉ៃខល កាណាវាស៖**

ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រមសាធារណជនទាំងអស់។ ខ្ញុំជឿជាក់ថាខ្ញុំបានកត់សម្គាល់រួចមកហើយនូវការជំទាស់របស់យើងខ្ញុំ ទៅនឹងប្រភេទនៃភស្តុតាងទាំងអស់នេះ នៅក្នុងការកត់សម្គាល់ជាទូទៅរបស់យើងខ្ញុំ។ យើងខ្ញុំបានកត់សម្គាល់ថា របាយការណ៍ជាច្រើន គឺថាមិនអាចឲ្យជឿជាក់បាននោះទេ ល្គឹកណាភាពជឿជាក់បាននេះត្រូវបានបង្ហាញឡើង។ ជាពិសេសទាក់ទងទៅនឹងចម្លើយពាក់ព័ន្ធទៅនឹងកូនក្តីរបស់យើងខ្ញុំ ក៏ដូចជាជនជាប់ចោទដទៃទៀត ហើយចម្លើយទាំងអស់នោះ ឬក៏ថាឃ្លាណាមួយដែលកូនក្តីរបស់យើងខ្ញុំអាចលើកឡើងនោះ។

យើងខ្ញុំបានកត់សម្គាល់ ឧទាហរណ៍ថា ទាក់ទងទៅនឹង អេលីហ្សាប៊ែត បេកយ័រ នៅក្នុងឆ្នាំ១៩៧៥ ព្រឹត្តិការណ៍ឆ្នាំ១៩៧៥ យើងខ្ញុំកត់សម្គាល់ថា យើងត្រូវពិនិត្យមើលទៅលើកំណត់ត្រារបស់អេលីហ្សាប៊ែត បេកយ័រ ដែលមាននៅក្នុងសំណុំរឿងរួចហើយ ហើយយើងខ្ញុំចង់ឲ្យមានចម្លើយពីរូបគាត់ដោយពិនិត្យមើលទៅលើកំណត់ត្រារបស់គាត់នៅក្នុងសំណុំរឿងនេះ ពាក់ព័ន្ធទៅនឹងព័ត៌មាននៃភស្តុតាងនីមួយៗ។

[១០:១៣:៣០]

យើងខ្ញុំយល់ថា សហព្រះរាជអាជ្ញាមានបំណងបង្ហាញជូននូវភស្តុតាងប្រភេទនេះ ដោយសារតែមូលហេតុមួយចំនួន ដូច្នេះវាអាស្រ័យទៅលើអង្គជំនុំជម្រះសម្រេចពិចារណាទៅលើភស្តុតាងនេះថាតើអាចទទួលយកភស្តុតាងនេះដោយមានកម្រិត។ ជាការពិតគឺថា វាអាស្រ័យទៅលើសហព្រះរាជអាជ្ញា ដែលត្រូវជូនដំណឹងមកដល់ភាគីទាំងអស់នូវគោលបំណងរបស់សហព្រះរាអាជ្ញាឲ្យពិតប្រាកដ។ ដូច្នេះយើងខ្ញុំសូមស្នើថា អាច ហើយនៅរសៀលនេះគឺថា យើងនឹងធ្វើការកត់សម្គាល់ទាក់ទងទៅនឹងចម្លើយតបរបស់យើងខ្ញុំ ជាពិសេស គឺទាក់ទងទៅនឹងភស្តុតាងទាំងអស់នេះតែម្តង។

[១០:១៤:២៥]

ដោយសារតែភស្តុតាងទាំងអស់នេះ វាមាននៅក្នុងសំណុំរឿង ឬក៏យោងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះ គឺមិនមានន័យថាត្រូវតែទទួលយកនោះទេ។ ហេតុដូច្នេះហើយ គឺថាហេតុអ្វីបានជាយើងធ្វើការជំទាស់ ឬក៏ជំទាស់ដោយភាគីដទៃទៀតនេះ។ ដូច្នេះយើងខ្ញុំគ្រាន់តែចង់លើកឡើងសាមញ្ញថា គឺជំហររបស់យើងខ្ញុំនោះគឺ តាមដែលអាចធ្វើទៅបាន ដោយសារតែសហព្រះរាជអាជ្ញាជាអ្នកមានបន្ទុកបង្ហាញនូវភស្តុតាងទាំងអស់។ មានន័យថា ហេតុអ្វីបានជាឯកសារទាំងអស់នេះ ឯកសារជាក់លាក់មួយចំនួននេះ ក្រៅពីឯកសារដែលមានការជាប់ពាក់ព័ន្ធ ត្រូវយកមកសំអាងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនោះ។ ហើយហេតុអ្វីក៏ជា បានជាឯកសារទាំងអស់នោះ វាមានទម្ងន់ទាក់ទងទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះនៅក្នុងសវនាការដំណាក់កាលទីមួយនេះ។

[១០:១៥:៣១]

ដូច្នេះ យើងខ្ញុំសូមស្នើដោយគោរពថា យើងខ្ញុំនឹងផ្តល់ចម្លើយរបស់យើងនៅក្នុងឧបសម្ព័ន្ធរបស់យើងខ្ញុំក្នុង-- ដែលបានលើកឡើងក្នុងរយៈពីរបីថ្ងៃកន្លងមកនេះ។ ថាហេតុអ្វីបានជាខ្ញុំជឿជាក់ថា ហេតុអ្វីក៏សហព្រះរាជអាជ្ញាលើកឡើងតែចំណុចដែលនៅក្នុងមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយត្រូវតែទទួលយកនោះ។

ដូច្នេះ ប្រសិនជាព័ត៌មានណាមួយមាន ឬក៏យោងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយដោយសារដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានដាក់ជូនមកចៅក្រម ដែលជាផ្នែកមួយនៃការពិចារណាទៅលើឯកសារដែលមានអីនោះ គឺថា មិនមែនមានន័យថា ព័ត៌មាននីមួយៗនោះ ត្រូវតែទទួលយកនោះទេ។ វាគ្រាន់តែមានន័យថា ត្រូវបានយកមកប្រើប្រាស់ពីសំណាក់អង្គជំនុំជម្រះ ឬចៅក្រមអាសនៈទាំង

អស់តែប៉ុណ្ណោះ គឺវាគ្រាន់តែជាផ្នែកមួយដីកាយកមកសាកសួរដេញដោលតែប៉ុណ្ណោះ។

[១០:១៦:៤៥]

ហេតុដូច្នេះ នៅពេលសហព្រះរាជអាជ្ញាថា វាមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះហើយ គឺថាវាអាចនឹងមានភាពឲ្យជឿជាក់បាននោះ យើងខ្ញុំសូមជំទាស់ថា មិនដូច្នោះទេ គឺត្រូវបង្ហាញនូវមូលដ្ឋានឲ្យបានច្បាស់លាស់ និងអង្គជំនុំជម្រះត្រូវពិចារណាថាតើត្រូវទទួលយកឬក៏អត់ ហើយភស្តុតាងនេះមានបន្ទុកប៉ុនណានោះ។ សូមអរគុណអង្គជំនុំជម្រះ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណលោកមេធាវី។

ជាកិច្ចបន្ត អង្គជំនុំជម្រះប្រគល់វេទិកាទៅមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសនៅក្នុងការឡើងធ្វើសេចក្តីសន្និដ្ឋាន-- ឡើងធ្វើការបង្ហាញអំពីការជំទាស់របស់ខ្លួនទៅលើឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ A5។

សូមអញ្ជើញ!

[១០:១៧:៤០]

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន សូមគោរពក្រុមប្រឹក្សាជំនុំជម្រះ អង្គសវនាការទាំងមូល។ ក្នុងឧបសម្ព័ន្ធទី៥នេះ ស្តីអំពីសារព័ត៌មានកម្ពុជាប្រជាធិបតេយ្យ និងសេចក្តីថ្លែងការណ៍ជាសាធារណៈដែលសហព្រះរាជអាជ្ញាបានលើកចំនួន៣៤៣ឯកសារ។

ក្នុងឯកសារ E158 ដែលសហព្រះរាជអាជ្ញាបានលើកមកនេះ គឺថា សហព្រះរាជអាជ្ញាបានព្យាយាមផ្តល់តម្រុយទៅលើភាពជឿជាក់ ទៅលើ-- ចំពោះឯកសារនោះចំនួន ៦០ ក្នុងចំណោមឯកសារទាំងអស់ដែលមាន ៣៤៣ នៅក្នុងឧបសម្ព័ន្ធនេះ។ ឯកសារចំនួន ៥៣ នៃឯកសារទាំងនោះបានមកពីប្រភពដែលហៅថា ការប្រមូលចងក្រងឯកសារដោយប្រទេសស៊ុយអែត *ស្វីដឌីស ខូឡិចស៊ិន* ឬសេវាផ្សព្វផ្សាយព័ត៌មានអន្តរជាតិ អេហ្វ.ប៊ី.អាយ.អេស។

ក្រៅពីនោះមានឯកសារប្រាំ ដែលជាសារព័ត៌មានទទួលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជា ឌី.ស៊ី.ខេម។ អ្វីដែលជាការទាមទារ ក៏ដូចជាការជំទាស់របស់យើងខ្ញុំ ចំពោះការផ្តល់ឯកសារនានាពាក់ព័ន្ធទៅនឹងឧបសម្ព័ន្ធនេះ មិនខុសពីអ្វីដែលយើងបានលើកក្នុងឧបសម្ព័ន្ធមុនៗទេ។ ដូច្នេះខ្ញុំបាទនឹង

មិនបង្ហាញភាពលម្អិតនៃការជំទាស់របស់យើងខ្ញុំទៀតទេ។ យើងខ្ញុំសូមរក្សានូវគោលជំហរ នៃការជំទាស់នេះដូចមាននៅក្នុងឧបសម្ព័ន្ធមុនៗដែរ។

[១០:២០:១៣]

ឧទាហរណ៍ថា ឯកសារដែលទទួលបានពីប្រទេសស៊ុយអែដ យើងឃើញថា ឯកសារទាំងនេះទើបតែទទួលបានក្នុងពេលថ្មីៗ ហើយដែលចម្ងល់ ដែលយើងទាំងអស់គ្នាឆ្ងល់នោះថា តើប្រទេសស៊ុយអែដនេះបានទទួលឯកសារទាំងនោះដោយរបៀបណា? នៅពេលណា? ពីនរណា? នេះជាចំណោទដែលយើងទាំងអស់គ្នាចង់ដឹង ហើយដែលសហព្រះរាជអាជ្ញាត្រូវតែបង្ហាញអំពីភាពជឿជាក់ទាំងអស់នោះទៅលើឯកសារនីមួយៗ ដើម្បីយើងអាចយកមកពិភាក្សាដេញដោលលម្អិតទៅលើឯកសារនីមួយៗនោះតទៅទៀត។

[១០:២១:២៤]

ដូច្នេះសរុបសេចក្តីមក ខ្ញុំបាទសូមរក្សាជំហររបស់យើងខ្ញុំដដែល។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ ដោយរយៈពេលនៃការឆ្លើយអះអាងតបរបស់ព្រះរាជអាជ្ញាមានរហូតដល់មួយម៉ោងឯណោះ។ ហើយឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកហើយដែរ បានន័យថា យើងគប្បីសម្រាកមុនពេលផ្តល់វេទិកាទៅសហព្រះរាជអាជ្ញា ដើម្បីធ្វើអំណះអំណាងតប។

ដូច្នេះ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះទៅរហូតដល់ម៉ោងដប់មួយ ខ្វះម្ភៃនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

*(សវនាការសម្រាកពីម៉ោង ១០:២២ នាទី ដល់ម៉ោង ១០:៤២ នាទី)*

[១០:៤២:៣៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ឥឡូវនេះ ដល់នាទីសហព្រះរាជអាជ្ញាដើម្បីមានឱកាសនៅក្នុងការធ្វើអំណះអំណាងតបទៅនឹងការជំទាស់របស់មេធាវីទាំងបីក្រុម ចំពោះឯកសារនៅក្នុងឧបសម្ព័ន្ធ A5។ សហព្រះរាជអាជ្ញាមានរយៈពេលមួយម៉ោងនៅក្នុងការធ្វើការអំណះ

អំណាងតបនេះ។

សូមអញ្ជើញ!

**លោក សេង ប៊ុនឃាង៖**

សូមអរគុណលោកប្រធាន។ តំណាងសហព្រះរាជអាជ្ញាដែលមានរូបខ្ញុំ ហើយនិងសហការី របស់ខ្ញុំ គឺលោកស្រី ហ្វាល់ហ្គនី ដេបណាត មានពេលវេលាមួយម៉ោង ដើម្បីឆ្លើយតបទៅនឹងការលើក ឡើងរបស់មេធាវីការពារក្តីនេះ ហើយជាចុងក្រោយ ពេលវេលាដែលនៅសេសសល់គឺលោក វីណ្ឌៀម ស្មីត គាត់នឹងលើកឡើងបន្ថែមទៀត បាទ។

[១០:៤៤:២៣]

តំណាងសហព្រះរាជអាជ្ញាសូមជម្រាបជូនអង្គសវនាការដែលថា ឯកសារដែលមាននៅក្នុង ឧបសម្ព័ន្ធ៥ របស់ការិយាល័យសហព្រះរាជអាជ្ញា គឺជាសារព័ត៌មាន និងសេចក្តីថ្លែងការណ៍ជាសាធា-រណៈនានារបស់កម្ពុជាកម្ពុជាប្រជាធិបតេយ្យ។ ឯកសារទាំងនេះ មានប្រភេទខុសគ្នាជាច្រើន ហើយ ឯកសារទាំងអស់នេះ គឺត្រូវបានដាក់ជាក្រុមៗផងដែរ។ ឯកសារនេះ មានដូចជា ការផ្សាយតាមវិទ្យុ របាយការណ៍ ឬក៏សេចក្តីថ្លែងការណ៍ផ្សេងៗ ដែលធ្វើឡើងដោយមន្ត្រីរបស់កម្ពុជាប្រជាធិបតេយ្យឬ ក៏ស្ថានទូត ឬក៏ក្រសួងនានាជាដើម។ ហើយក៏មានផងដែរនូវព្រឹត្តិបត្រសារព័ត៌មានផ្សេងដែលធ្វើឡើង ដោយស្ថានទូតរបស់កម្ពុជាប្រជាធិបតេយ្យនៅឯបរទេសផងដែរ។

[១០:៤៥:១៧]

មានរបាយការណ៍របស់សេវាផ្សព្វផ្សាយព័ត៌មានបរទេសជាច្រើនត្រូវបានដាក់បញ្ចូលនៅក្នុង ឧបសម្ព័ន្ធ៥ នេះ។ ដូចដែលលោក លោកស្រីចៅក្រមបានជ្រាបហើយ អំពីការដាក់ឯកសារស្តីពីសេវា ផ្សព្វផ្សាយព័ត៌មានបរទេស ដែលហៅកាត់ថា អេស.ប៊ី.អេស.អេស នេះ។ សេវាផ្សព្វផ្សាយព័ត៌មាន បរទេសនេះ ត្រូវបានគ្រប់គ្រងដោយទីភ្នាក់ងារស៊ើបការណ៍សម្ងាត់សហរដ្ឋអាមេរិកចាប់តាំងពីឆ្នាំ១៩៤១ ដល់ឆ្នាំ២០០៤។ ហើយទីភ្នាក់ងារសម្ងាត់នេះបានគ្រប់គ្រង បានបកប្រែ និងបានធ្វើប្រតិចារឹកទៅលើ ព័ត៌មាន និងបទអត្ថាធិប្បាយពីសុន្ទរកថានយោបាយបរទេស ពីការផ្សព្វផ្សាយព័ត៌មានតាមវិទ្យុ និង ទូរទស្សន៍ ពីទីភ្នាក់ងារផ្សព្វផ្សាយព័ត៌មានបន្ត កាសែត និងទស្សនាវដ្តីផ្សេងៗផងដែរ។

[១០:៤៦:១៥]

របាយការណ៍របស់សេវាផ្សព្វផ្សាយព័ត៌មានបរទេសនេះ គឺយើងអាចចូលមើលបានតាមប្រព័ន្ធ

អ៊ីនធឺណេត នៅតាមបណ្ដាសាកលវិទ្យាល័យជាច្រើន ជាពិសេសនៅបណ្ណាល័យរបស់សាកលវិទ្យាហារ៉ឺដ ជាដើម។ ហើយរបាយការណ៍របស់សេវាផ្សព្វផ្សាយព័ត៌មានបរទេសនេះ គឺមានចាប់ពីខែមករា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩។ លើកលែងតែរបាយការណ៍សម្រាប់ខែធ្នូ ឆ្នាំ១៩៧៧ ដែលត្រូវបានដាក់ដោយកាលវិយាល័យសហព្រះរាជអាជ្ញា ដែលមាននៅក្នុងសំណើរបស់សហព្រះរាជអាជ្ញា សូមឲ្យដាក់របាយការណ៍ស្ដីពីការផ្សព្វផ្សាយព័ត៌មានបរទេសបញ្ចូលក្នុងសំណុំរឿង ដែលបានដាក់កាលពីថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ២០០៩ រួចហើយ។ សំណើនេះត្រូវបានចុះលេខឯកសារ គឺD262។

ចំណែកឯរបាយការណ៍សម្រាប់ខែធ្នូ ឆ្នាំ១៩៧៧នោះ គឺត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿងរួចហើយដែរ គឺនៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៩។

[១០:៤៧:៣៣]

ការផ្សាយព័ត៌មានបន្ត ដែលសេវាផ្សព្វផ្សាយព័ត៌មានបរទេសបានត្រួតពិនិត្យនេះក៏ត្រូវបានត្រួតពិនិត្យដោយបណ្ដាទីភ្នាក់ងារដទៃទៀតដែរ ដែលមានដូចជា ប៊ី.ប៊ី.ស៊ី ជាដើម។ ប៊ី.ប៊ី.ស៊ី នេះបានធ្វើការកត់ត្រាព័ត៌មានពិភពលោកជាភាសាអង់គ្លេស ហើយបង្កើតបានជាសេចក្ដីសង្ខេបព័ត៌មានពិភពលោកដែលហៅកាត់ថា អេស.ដាប់ប៊ែលយូ.ប៊ី ដើម្បីធ្វើការសង្ខេបពីការផ្សាយបន្តផ្ទាល់ ផ្សាយព័ត៌មានបន្តពីស្ថានីយ៍វិទ្យុបរទេសចាប់ពីឆ្នាំ១៩៣៩ ដល់ឆ្នាំ១៩៩៧។

[១០:៤៨:១៥]

បន្ថែមពីលើរបាយការណ៍របស់សេវាផ្សព្វផ្សាយព័ត៌មានរបស់បរទេសអេស.ប៊ី.អាយ.អេស និងអេស.ដាប់ប៊ឺយូ.ប៊ី នេះ ឧបសម្ព័ន្ធ៥ ក៏បានដាក់បញ្ចូលនូវឯកសារដែលបានធ្វើឡើងដោយរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យផងដែរ។ ហើយឧបសម្ព័ន្ធ៥នេះ ក៏បានដាក់បញ្ចូលនូវឯកសារដែលបានធ្វើឡើងដោយ ហ្វុង និង ប្រ៊ុង ផងដែរ។ ឯកសារទាំងនេះរួមមាន ព្រឹត្តិបត្រសារព័ត៌មាន សេចក្ដីថ្លែងការណ៍របស់រដ្ឋាភិបាល និងព្រឹត្តិបត្ររបស់ស្ថានទូតមួយចំនួនផងដែរ។ ភស្តុតាងនៅក្នុងឧបសម្ព័ន្ធនេះ គឺមានព្រឹត្តិការណ៍សំខាន់ថ្មីៗ ដែលទើបតែកើតមានឡើងដើម្បីបង្ហាញអំពីតួនាទី ឬក៏សកម្មភាពរបស់ជនជាប់ចោទ មុនពេលកម្ពុជាប្រជាធិបតេយ្យ ឬក៏អំឡុងពេល ឬក៏ពេលបន្ទាប់មកទៀត។ ហើយថែមទាំងមានព័ត៌មានលម្អិតផ្សេងៗ ដើម្បីគាំទ្រទៅនឹងភស្តុតាងផ្សេងៗទៀតផងដែរ។

[១០:៤៩:២៣]

ហើយជាបន្តនេះ ខ្ញុំសូមលើកឧទាហរណ៍អំពីភាពជឿជាក់ចំពោះឯកសារ ដែលទាក់ទងនឹង

សេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេសនៃកម្ពុជាប្រជាធិបតេយ្យ ដែលក្រុមមេធាវីការពារក្តីបានជំទាស់ដែរនោះ។ ឧទាហរណ៍ នេះគឺស្ថិតនៅលេខរៀងទី៣០ ដែលមានលេខឯកសារ គឺ IS19.38 និងលេខរៀងទី១៣៥ គឺឯកសារ D108/43/9 នៃឧបសម្ព័ន្ធ៥ របស់ការិយាល័យសហព្រះរាជអាជ្ញា។ ហើយឯកសារទាំងពីរនេះគឺជាឧទាហរណ៍យ៉ាងច្បាស់ ដើម្បីបញ្ជាក់អំពីភាពដែលអាចជឿជាក់បាននៃឯកសារ។ ព្រោះថាសេចក្តីថ្លែងការណ៍ ដែលបានធ្វើឡើងដោយក្រសួងការបរទេសនៃកម្ពុជាប្រជាធិបតេយ្យ គឺវាដូចគ្នាទៅនឹងរបាយការណ៍ព័ត៌មានដែលបានធ្វើឡើងដោយប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិ ដូចជា ប៊ី.ប៊ី.ស៊ី, អេស.ដាប់ប៊ែលយូ.ប៊ី ជាដើម។

[១០:៥០:៣០]

ឯកសារដែលមានលេខរៀងទី១៣០ នៃឧបសម្ព័ន្ធប្រាំរបស់ការិយាល័យសហព្រះរាជអាជ្ញានេះ គឺជាសេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេសនៃកម្ពុជាប្រជាធិបតេយ្យ ដែលជាឯកសារផ្សព្វផ្សាយដោយរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ ដែលបានសម្រេចកាត់ផ្តាច់ការទាក់ទងផ្លូវទូតជាបណ្តោះអាសន្នជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម ព្រមទាំងកំណត់ពេលវេលាដល់អ្នកការទូត និងបុគ្គលិកស្ថានទូតទាំងអស់របស់វៀតណាម ត្រូវចាកចេញពីប្រទេសកម្ពុជាផងដែរ។

[១០:៥១:០៨]

ហើយខ្ញុំសូមដកស្រង់តែខ្លឹមសារនៃសេចក្តីសម្រេចនៅក្នុងសេចក្តីថ្លែងការណ៍នេះ ដែលមានដូចតទៅ។ ក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យ ដោយមានការអនុញ្ញាតពីរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ សូមធ្វើសេចក្តីថ្លែងការណ៍ដូចតទៅនេះ៖

“ទីមួយ រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យសម្រេចកាត់ផ្តាច់ការទំនាក់ទំនងផ្លូវទូតជាបណ្តោះអាសន្នជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម ចាប់ពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ នេះតទៅ។ រង់ចាំការដកកងទ័ពឈ្លានពានរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម ចេញពីទឹកដីជាទីសក្ការៈនៃកម្ពុជាប្រជាធិបតេយ្យ និងការវិលមកវិញនូវសភាពការណ៍ដែលនាំឲ្យមានបរិយាកាសមិត្តភាពរវាងប្រទេសទាំងពីរឡើងវិញ។ ទីពីរ គឺអ្នកការទូត និងបុគ្គលិកស្ថានទូតនៃសាធារណរដ្ឋសង្គមនិយមវៀតណាមប្រចាំកម្ពុជាប្រជាធិបតេយ្យ ត្រូវចាកចេញពីកម្ពុជាប្រជាធិបតេយ្យឲ្យបានមុន ថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៨ ដែលជាកាលបរិច្ឆេទចុងក្រោយ”។ នេះគឺសេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេសនៃកម្ពុជា

ប្រជាធិបតេយ្យ។

[១០:៥២:៣៩]

ហើយចំណែកឯកសារលេខរៀងទី៣៥ នៃឧបសម្ព័ន្ធប្រាំរបស់ការិយាល័យសហព្រះរាជអាជ្ញានេះ មួយទៀតគឺការដកស្រង់ព័ត៌មានរបស់ប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិ ពោលគឺសេចក្ដីសង្ខេបព័ត៌មានរបស់ពិភពលោក ដែលហៅកាត់ថា ប៊ី.ប៊ី.ស៊ី, អេស.ដាប់ប៊ែលយូ.ប៊ី កាលពីថ្ងៃទី០៣ ខែមករា ឆ្នាំ១៩៧៨ ដែលបានដកស្រង់នូវសេចក្ដីថ្លែងការណ៍របស់ក្រសួងការបរទេសនៃកម្ពុជាប្រជាធិបតេយ្យ ដែលបានធ្វើឡើងកាលពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ នេះ។

[១០:៥៣:១៥]

ហើយបើយើងពិនិត្យទៅលើខ្លឹមសារនៃការដកស្រង់របស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានអន្តរជាតិនេះ គឺ វាដូចគ្នាទៅនឹងអ្វីដែលមាននៅក្នុងសេចក្ដីថ្លែងការណ៍របស់ក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យអ៊ីចឹងដែរ។ ហើយតទៅនេះ ខ្ញុំសូមដកស្រង់ខ្លឹមសារត្រង់សេចក្ដីសម្រេចរបស់ក្រសួងការបរទេស ដែលអេស.ដាប់ប៊ែលយូ.ប៊ី បានដកស្រង់ ហើយមានដូចតទៅ៖

“ក្រសួងការបរទេសនៃកម្ពុជាប្រជាធិបតេយ្យ សូមធ្វើសេចក្ដីថ្លែងការណ៍ដូចតទៅនេះ៖ ទីមួយរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យសម្រេចកាត់ផ្ដាច់ទំនាក់ទំនងការទូតទាំងស្រុងជាបណ្ដោះអាសន្នជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម ចាប់ពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ រហូតដល់កងទ័ពឈ្លានពានទឹកដីរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម ដកចេញពីទឹកដីដ៏ពិសិទ្ធរបស់កម្ពុជាប្រជាធិបតេយ្យរហូតដល់ទំនាក់ទំនងរវាងប្រទេសទាំងពីរស្ថិតក្នុងបរិយាកាសមិត្តភាពដូចដើមវិញ។ ទីពីរ គឺអ្នកការទូត និងបុគ្គលិកស្ថានទូតនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលមានការទទួលស្គាល់ពីកម្ពុជាប្រជាធិប-តេយ្យ ត្រូវតែចាកចេញពីកម្ពុជាប្រជាធិបតេយ្យនៅមុន ថ្ងៃ០៧ ខែមករា ឆ្នាំ១៩៧៨ ជាកំហិត”។ អ៊ីចឹងយើងឃើញថា ឯកសារទាំងពីរនេះ គឺវាមានភាពស៊ីសង្វាក់គ្នា ដែលអាចបញ្ជាក់ឲ្យបានអំពីភាពជឿជាក់នៃឯកសារ។

ដូច្នេះនៅក្នុងឧទាហរណ៍ដ៏សាមញ្ញ ដែលបានលើកអម្បាញ់មិញនេះ គឺជាការបញ្ជាក់ថា មិនមានហេតុផលអ្វីដែលតម្រូវឲ្យអង្គជំនុំជម្រះកោះអញ្ជើញអ្នកសរសេរអត្ថបទ ឬក៏អ្នករាយការណ៍ព័ត៌មាននោះមកធ្វើសក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនោះទេ។

ហើយជាបន្តទៅទៀតនេះ គឺសូមអនុញ្ញាតឲ្យសហការីអន្តរជាតិរបស់ខ្ញុំនឹងលើកឡើងបន្ថែមត

ទៅទៀត។ សូមអរគុណ។

[១០:៥៥:២៤]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោកស្រី ហ្វាល់ហ្គុនី ដេបណាត៖**

សូមអរគុណលោកប្រធាន ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម សហការី ក៏ដូចជាសាធារណជនទាំងអស់។ ឯកសារដែលទាក់ទងទៅនឹងឯកសារចំនួន៣៤៥ ឯកសារនេះ គឺទាក់ទងទៅនឹងសេវាផ្សព្វផ្សាយព័ត៌មានអន្តរជាតិ គឺថារបាយការណ៍ចំនួន៥០ បានដាក់ទៅក្នុងសំណុំរឿងហើយដែលសហចៅក្រមស៊ើបអង្កេតបានដាក់ទៅក្នុងសំណុំរឿងរួចទៅហើយ។ ហើយសេចក្តីផ្សព្វផ្សាយនេះគឺថា វាមានទម្រង់របស់វានៅផ្នែកខាងលើគឺមានការលបរិច្ឆេទ ពាក្យថា "ប្រទេសកម្ពុជា" ហើយបន្ទាប់មកមានលេខរៀង។ របាយការណ៍ខ្លះមានតារាងរៀបរាប់អំពីមាតិកានៃរបាយការណ៍ ហើយដែលរៀបរាប់ថាប្រទេសនេះគឺថា-- ហើយមានលិខិតមួយទៀតគឺថា រៀបរាប់អំពីប្រទេសនោះគឺថា សេវាផ្សព្វផ្សាយព័ត៌មានអន្តរជាតិនេះ គឺមានផ្តល់នូវការផ្សព្វផ្សាយជាប្រចាំថ្ងៃ ចេញពីកន្លែងផ្សព្វផ្សាយជាច្រើន។ ពួកគេផ្សព្វផ្សាយ តាមដានការផ្សព្វផ្សាយចេញពីហាណូយ, ប៉េកាំង, អាល់ហ្សេរី, ហុងកុង ហើយសេវាផ្សព្វផ្សាយនេះ ក៏ផ្សព្វផ្សាយចេញពីប្រទេសកម្ពុជាដែរ។ តាមរយៈការបកប្រែ និងប្រតិចារឹកនេះគឺបានដាក់ចេញនូវកាលបរិច្ឆេទនៅទីតាំងពិតប្រាកដនៅពេលវេលាមួយពិតប្រាកដ។ ហើយក៏បានផ្តល់នូវ-- ថាតើអ្វីកើតឡើងនៅប្រទេសកម្ពុជានៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៧៥?

[១០:៥៧:៣៦]

មុននឹងខ្ញុំផ្តល់នេះ ខ្ញុំសូមផ្តល់នូវលេខ ERN នៃឯកសារទាំងនេះជាមុនសិន។ ខ្ញុំយោងទៅលើឯកសារ D108/43/1, ERN ជាភាសាខ្មែរ 00242308, ជាអង់គ្លេស 003-- ហើយជាភាសាបារាំង 00281432។ ឥឡូវនេះ យើងខ្ញុំសូមលើកឡើងអ្វីដែលបានកើតឡើងនៅថ្ងៃទី២៦ កុម្ភៈ ១៩៧៥ នៅក្នុងទីក្រុងភ្នំពេញ។

ខៀវ សំផន បានចូលរួមនៅក្នុងសន្និបាតនៅថ្ងៃទី២៤-២៥ ខែកុម្ភៈ ឆ្នាំ១៩៧៥ ដែលសន្និបាតទាក់ទងទៅនឹងតំបន់រំដោះ នៅក្រោមអធិបតីភាពរបស់ ខៀវ សំផន ដែលជារដ្ឋមន្ត្រីក្រសួងការពារជាតិ ហើយនិងជាប្រធានកងទ័ពរំដោះជាតិកម្ពុជា។ ហើយសន្និបាតនៃមហាជោគជ័យនេះគឺថា ពាក់ព័ន្ធទៅ

នឹងបញ្ហានយោបាយ សេដ្ឋកិច្ច ដែលជាការរីកចម្រើនមួយរបស់ប្រជាជាតិកម្ពុជាគួរឲ្យពេញចិត្តជាទីបំផុត ហើយនិងចលនាតស៊ូរបស់ប្រជាជនកម្ពុជា។ ហើយភាគខ្លាំងគ្រប់ទីកន្លែងទាំងអស់គឺត្រូវបានដួលរលំ ភ្នំពេញត្រូវបានឡោមព័ទ្ធរួចទៅហើយ។ ហើយបញ្ហាសេដ្ឋកិច្ច នយោបាយ ទាំងអស់នោះគឺថាមានការរីកចម្រើន ដោយយោងទៅលើកាលៈទេសៈនៃមហាសន្និបាតមហាជោគជ័យនេះក្នុងរយៈពេលពីរថ្ងៃ ដោយមានការប្រកាសនូវបញ្ហាសំខាន់ៗមួយចំនួនដូចខាងក្រោមនេះ៖

[១០:៥៨:៤៨]

"១) ទាក់ទងទៅនឹងជនក្បត់ទាំងប្រាំពីរនាក់នៅក្នុងភ្នំពេញគឺ យើងសម្រេច*(ឮមិនច្បាស់)* គឺជនក្បត់ លន់ នល់, សិរិមតៈ, សឺង ង៉ុកថាញ់, ចេង ហេង, អ៊ិន តាំ, ឡុង បូរ៉េត ហើយនិង ហ្វេណង់ដេស ដែលជាអ្នកដឹកនាំជនក្បត់ដែលបង្កើតឲ្យមានរដ្ឋប្រហារមួយ។ ពួកគេគឺជាបរិវាររបស់ចក្រពត្តិ អាមេរិក ដែលបង្កើតភ្លើងសង្គ្រាមនៅក្នុងប្រទេសកម្ពុជា ធ្វើឲ្យបង្កឲ្យមានមហន្តរាយដ៏ធំធេងហើយ បានធ្វើឲ្យព្រះសង្ឃជាច្រើនសុគត ក្នុងនោះរួមទាំងបុរសស្ត្រីនិងកុមារផងដែរ។ ក្នុងនាមរណសិរ្សរួបរួមជាតិកម្ពុជា រដ្ឋាភិបាលកម្ពុជា និងកម្លាំងប្រដាប់អាវុធរំដោះជាតិកម្ពុជា សមាជជាតិបានប្រកាសថា វាជាការចាំបាច់ដាច់ខាតត្រូវសម្លាប់ជនក្បត់ទាំងប្រាំពីរនាក់នេះ ចំពោះអំពើក្បត់ជាតិរបស់ពួកវា ដែលប្រឆាំងនឹងប្រជាជាតិ និងអំពើហ្វាស៊ីស ពុករលួយ ឧក្រិដ្ឋដែលមិនធ្លាប់មាននៅក្នុងប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា"។

[១១:០១:០១]

ទំព័រទី៤ នៃឯកសារនេះ សម្រាប់សមាជជាតិលើកទី២ ប្រធាននៃសមាជជាតិនេះគឺបានលើកឡើងអំពីឈ្មោះ ខៀវ សំផន លេខERN គឺ ខ្ញុំសូមដកស្រង់ជាភាសាខ្មែរ 00242314, 00166775 និង00281435។ ការផ្សព្វផ្សាយនេះ គឺថាអាចរកឃើញនៅក្នុងប្រព័ន្ធសេវាផ្សព្វផ្សាយបរទេសជាច្រើន ហើយបន្ទាប់ពីការដួលរលំនៃទីក្រុងភ្នំពេញ ជនក្បត់ទាំងប្រាំពីរនេះគឺថា ដែលស្ថិតនៅទីក្រុងភ្នំពេញ ត្រូវបានប្រហារជីវិតចោល ហើយត្រូវបានរាយការណ៍នៅក្នុងរបាយការណ៍ជាច្រើនរួមទាំងមាននៅក្នុងរបាយការណ៍អង្គការលើកលែងទោសអន្តរជាតិផងដែរ នៅថ្ងៃទី២៦ កុម្ភៈ ១៩៧៦ ដែលថា អៀង សារី បាននិយាយអំពីជោគវាសនារបស់មនុស្សទាំងប្រាំពីរនាក់នេះ។

[១១:០២:០៨]

របាយការណ៍ពីអង្គការលើកលែងទោសអន្តរជាតិ គឺ D84/-- ERNជាភាសាខ្មែរ 00597825

អង់គ្លេស 000443, ជាភាសាបារាំង 00607934។ របាយការណ៍នោះបានលើកឡើងថា របាយការណ៍ពីខាងដើមគឺពាក់ព័ន្ធទៅនឹងមេដឹកនាំប្រាំពីរនាក់នៃរបប លន់ នល់ ដែលត្រូវចាត់ទុកថាតែពួកក្បត់ហើយត្រូវផ្តន្ទាទោសប្រហារជីវិតនៅក្នុងសមាជជាតិនៅក្នុងឆ្នាំ១៩៧៥។ បួននាក់ក្នុងចំណោមប្រាំពីរនេះ បានភៀសខ្លួនចេញពីទីក្រុងភ្នំពេញមុននឹងថ្ងៃរំដោះទីក្រុងភ្នំពេញនៅក្នុងខែវិច្ឆិកា ១៩៧៥ ឧបនាយករដ្ឋមន្ត្រី អៀង សារី បាននិយាយថា មេដឹកនាំបីនាក់នៅក្នុងចំណោមមេដឹកនាំទាំងនេះ ត្រូវបានប្រហារជីវិតមាន ឡុង បូរ៉េត, សិរិមតៈ។

[១១:០៣:៤៣]

ផ្នែកទីពីរនៃឧបសម្ព័ន្ធទី៥នេះ គឺមានឯកសារចំនួន៦០ គឺយើងយកបានចេញមកពីវិទ្យុ ប៊ី.ប៊ី.ស៊ី មិនមែនដកស្រង់តែ អេស.ប៊ី.អាយ.អេស ទេគឺយកមកពី ប៊ី.ប៊ី.ស៊ី ជារបាយការណ៍ដែលសង្ខេបអំពីការផ្សព្វផ្សាយដែលគ្របដណ្តប់ទៅលើព័ត៌មានប្រហាក់ប្រហែលគ្នានេះ ទាំងនៅក្នុងសេវាផ្សព្វផ្សាយព័ត៌មានអន្តរជាតិ ដែលមាននៅក្នុងឧបសម្ព័ន្ធ៥នេះ។ ឯកសារទាំងនេះក៏បានផ្តល់នូវឲ្យមានជំនឿជឿជាក់មួយនៅក្នុងរយៈពេល៣៥ឆ្នាំកន្លងមកនេះ ដែលត្រូវយកមកបង្ហាញអះអាងនៅក្នុងអន្តរជាតិ ហើយសេចក្តីសង្ខេបរបាយការណ៍ដែលមាននេះ គឺពាក់ព័ន្ធទៅនឹងអង្គហេតុលម្អិតនៅក្នុងចំណោមរបាយការណ៍ទាំងនេះ។ ហើយក៏បានប្រាប់ថា តើមេដឹកនាំទាំងនោះជាអ្នកណា? ដើរតួនាទីធ្វើអ្វីខ្លះ? បាននិយាយអ្វីខ្លះ? ហើយនិងនិយាយនៅពេលណា? ហើយនៅក្នុងឯកសារទាំង៦០នេះ ជាងមួយភាគបី គឺបានដាក់ចូលទៅក្នុងសំណុំរឿង០០១។ សេចក្តីសង្ខេបនេះមានទម្រង់ដូចខាងក្រោមនេះ គឺថាឯកសារនេះដាក់ថា “ប៊ី” នៅផ្នែកខាងលើ ហើយជួនកាលក៏មានចំណងជើងពេញតែម្តង ហើយមានរៀបរាប់សាច់រឿងនៅកណ្តាល និងកាលបរិច្ឆេទនៅផ្នែកខាងលើ។

[១១:០៥:២២]

ខ្ញុំសូមបង្ហាញជូននូវអង្គជំនុំជម្រះនៅឯកសារមួយ ឯកសារ D56/4.084 ជារបាយការណ៍ខ្មែរមានលេខ ERN ជាភាសាខ្មែរ 00725158 ជាអង់គ្លេស 00008087 និងជាអង់គ្លេស 00741908។ សេចក្តីផ្សព្វផ្សាយនេះ គឺនិយាយដូចខាងក្រោម ប្រធាននៃសាធារណរដ្ឋប្រជាមានិតកម្ពុជាបានចាកចេញពីទីក្រុងវ៉ាហ្គូ នៅថ្ងៃទី២៦ កុម្ភៈ ពីប្រទេសកម្ពុជា។ ខ្ញុំសូមដកស្រង់កថាខណ្ឌ៖ “ក្រុមប្រតិភូរបស់គាត់បានមកដល់ទីក្រុងភ្នំពេញរួមមានទាំង ខៀវ សំផន ប្រធាន-- ជាគណៈប្រធានរដ្ឋ, នួន ជា ប្រធាន នៃតំណាងសភានៃប្រជាធិបតេយ្យ, អៀង សារី ឧបនាយករដ្ឋមន្ត្រីការបរទេស និង សុន សេន ជា

ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកការពារជាតិ។ ទស្សនកិច្ចនេះ ខៀវ សំផន បានស្វាគមន៍ប្រតិភូនៅក្នុងតំណាងឲ្យប្រធាននៃគណៈប្រធានរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យ។ គាត់ក៏បានលើកឡើងនូវការព្រួយបារម្ភមួយចំនួនរបស់របបនេះ។ ថ្ងៃបន្ទាប់មកនៅថ្ងៃទី២៧ ខែវិច្ឆិកា នូ អ៊ុន បានទៅទស្សនកិច្ចសៀមរាបដែលអមដំណើរដោយ អៀង សារី។ ពួកគេត្រូវបានទទួលស្វាគមន៍នៅអាកាសយានដ្ឋានសៀមរាបដោយ ខៀវ សំផន។ សេវាផ្សព្វផ្សាយក្នុងស្រុក គឺត្រូវបានផ្សព្វផ្សាយដោយ អេហ្វ.ប៊ី.អាយ.អេស ដែលអាចរកបាននូវឯកសារ D26/2.4.26 ជា ERN អង់គ្លេស 00168603។ ឯកសារ D26/2.06 (សូមកែប្រែ) D26/2.26។

[១១:០៧:៤៨]

របាយការណ៍របស់គាត់នេះ គឺបានលើកឡើងនូវឆ្នាំ១៩៧៧ ថា នូ អ៊ុន ដំណើរទស្សនកិច្ចរបស់ នូ អ៊ុម ទៅកាន់សៀមរាប គឺសេវាផ្សព្វផ្សាយទីក្រុងភ្នំពេញទៅ ជី.អឹម.ជី នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៧៧។ ប្រធានាធិបតី យូនីវីន ដែលតំណាងប្រតិភូមកពីប្រទេសភូមា ទៅអមដំណើរដោយឧបនាយករដ្ឋមន្ត្រី អៀង សារី ហើយក៏បានធ្វើដំណើរទៅកាន់សៀមរាប ទីក្រុងអង្គរ។ ប្រធានាធិបតី នូ អ៊ុន ត្រូវបានទទួលស្វាគមន៍យ៉ាងកក់ក្ដៅនៅអាកាសយានដ្ឋានសៀមរាប ដោយមានចំណងមិត្តភាព និងមានការបង្ហូតទង់នៃប្រទេសទាំងពីរ ហើយមានវត្តមាន ខៀវ សំផន, សុន សេន និងវត្តមាន កង ចាប ក៏ដូចជាកម្មាភិបាលមកពីភូមិភាគឧត្តរជាច្រើនរូបទៀត។

[១១:០៨:៥០]

ឯកសារទីបីនេះ ក៏និយាយអំពីដំណើរទស្សនកិច្ចនេះផងដែរ គឺអាចរកបាននៅក្នុងឯកសារ D133.2 លោក ហ្វ្រង់ស្វ័រ ប៊ីហ្សូ បាននិយាយអំពីដំណើរទស្សនកិច្ចនេះនៅក្នុងសន្និបាតមួយនៅក្នុងទីក្រុង អូស្លូ នៅក្នុងឆ្នាំ១៩៧៨។ លេខ ERN បារាំង 0023637 អង់គ្លេស 00610802។ ការបកប្រែភាសាទាំងនៅក្នុង ERN ទាំងពីរនេះ គឺមិនទាន់រួចរាល់ជាភាសាខ្មែរនៅឡើយទេ។

ដូច្នេះយើងខ្ញុំជឿជាក់ថា អង្គជំនុំជម្រះបានស្ដាប់គ្រប់គ្រាន់សម្រាប់ឯកសារនេះ លោកសហការីរបស់ខ្ញុំ លោក វីណ្ឌៀម ស្មីត នឹងឡើងបន្ថែមនៅពេលសេសសល់នេះ។ សូមអរគុណអង្គជំនុំជម្រះ។

**លោក វីណ្ឌៀម ស្មីត៖**

ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម សហការី ក៏ដូចជាសាធារណជនទាំងអស់។ សហការីរបស់ខ្ញុំបានលើកទៅឯកសារជាក់លាក់មួយចំនួន ដោយបង្ហាញជាថ្មីម្ដងទៀតទាក់ ទង ទៅនឹង

ភាពគួរឲ្យជឿជាក់បាននៃឯកសារទាំងអស់នេះ ដោយមានការចោទសួរគ្នា។ ដោយសារតែវា មានភាពស៊ីសង្វាក់គ្នាជារួមផ្ទៃក្នុងតែម្តង។ ឥឡូវនេះ ខ្ញុំសូមលើកឡើងនូវការជំទាស់ ដែលលើកឡើង ដោយមេធាវីការពារក្តីជាជាក់លាក់ក៏ដូចជាក្នុងលក្ខណៈមួយទូទៅដែលពួកគាត់បានលើកឡើង។ មានបញ្ហាដែលមេធាវីការពារក្តីក្រុម នួន ជា ក្រុមមេធាវីការពារក្តី អៀង សារី ដែលលើកឡើងថា សហព្រះរាជអាជ្ញាមិនបានបង្ហាញនូវភាពពាក់ព័ន្ធនៃឯកសារទាំងនោះទេ។

[១១:១១:០១]

នៅថ្ងៃទី១៩ កុម្ភៈ ២០១១ យើងបានដាក់ជូនឧបសម្ព័ន្ធចំនួន២០ ដែលរៀបរាប់អំពីឯកសារដែលមានដាក់ជាតារាងដោយលើកឡើងនូវឯកសារផ្សេងៗដែលដាក់ជូននៅក្នុងដីកាបញ្ជូនទៅជំនុំជម្រះ។ នៅក្នុងតារាងទាំងអស់នេះ គឺមានឯកសារពាក់ព័ន្ធទៅនឹងលេខកថាខណ្ឌ និងលេខទំព័រ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ហើយពាក់ព័ន្ធទៅនឹងបញ្ហាដែលអង្គជំនុំជម្រះបានលើកឡើងថា ពាក់ព័ន្ធទៅនឹងសវនាការដំណាក់កាលទីមួយនេះ។ បញ្ហាទីមួយ គឺពាក់ព័ន្ធទៅនឹងប្រវត្តសាវតារ រចនាសម្ព័ន្ធ ការប្រាស្រ័យទាក់ទង និងការប្រាស្រ័យទាក់ទងផ្នែកយោធា ក៏ដូចជាអង្គហេតុទាក់ទងទៅនឹងសហឧក្រិដ្ឋកម្មរួម និងការពាក់ព័ន្ធនូវការអនុវត្តគោលនយោបាយនេះ។

[១១:១២:០០]

យើងខ្ញុំបានកត់សម្គាល់ឃើញថា នៅក្នុងដីកាបំបែកដំណើរការនីតិវិធីនេះគឺមិនបានច្រានចោលនូវលទ្ធភាពដែលពាក់ព័ន្ធទៅនឹងបទចោទ ដែលត្រូវយកមកសម្រេចនៅក្នុងដំណាក់កាលទីមួយនេះទេ។ ទាក់ទងទៅនឹងឯកសារដែលលើកឡើងដោយក្រុមមេធាវីការពារក្តី នួន ជា ពួកគាត់បានយោងទៅលើឯកសារនៅ ស-២១ ឯកសារមកពីក្រសួងការបរទេស របៀបនៃការប្រាស្រ័យទាក់ទងរបស់បក្សកុម្មុយនីស្តកម្ពុជាទៅនឹងមន្ទីរសន្តិសុខនីមួយៗក៏ដូចជាផ្នែកផ្សេងៗទៀតដែរ គឺថាវាបានបង្ហាញថាតើអង្គការចាត់តាំងនេះដំណើរការទៅដោយរបៀបណានោះ? ហើយពាក់ព័ន្ធទៅនឹងឯកសារដែលយើងយោងទៅលើមន្ទីរសន្តិសុខដទៃទៀតនោះ គឺវាពាក់ព័ន្ធទៅនឹងគោលនយោបាយទូទៅរបស់បក្សកុម្មុយនីស្តកម្ពុជាដែលជាកម្មវត្ថុនៃសវនាការដំណាក់កាលទីមួយនេះ។

[១១:១៣:០៦]

ហើយការជំទាស់ក៏បានលើកឡើងនូវឯកសារ ប្រសិនបើជាឯកាសារលើកឡើងអំពីរចនាសម្ព័ន្ធនេះបន្ទាប់ពីការជម្លៀសប្រជាជននោះ គឺថាមេធាវីការពារក្តីបានលើកឡើងថា មិនពាក់ព័ន្ធនោះទេ។

យើងខ្ញុំបានពិនិត្យមើលទៅលើរចនាសម្ព័ន្ធពាក់ព័ន្ធទៅនឹងបទល្មើសជាក់លាក់មួយចំនួន ដើម្បីសម្រេចថា តើការ-- រចនាសម្ព័ន្ធនៃការទាក់ទងនេះវាពាក់ព័ន្ធអ្វីដែរទៅនឹងការជម្លៀសប្រជាជននេះ? ហេតុដូច្នេះ ឯងបានជាយើងខ្ញុំ បានដាក់ជូននូវឯកសារនេះ។ ជាពិសេស ពាក់ព័ន្ធទៅនឹងមេធាវីការពារក្ដីរបស់ក្រុម អៀង សារី ដែលបានលើកឡើងនូវឯកសារទាំងនេះ គឺសំណួរថាតើភាពពាក់ព័ន្ធនៃឯកសារនេះគឺអ្វីដែល យើងខ្ញុំបានដាក់ជូននោះ? រយៈពេលជាមួយឆ្នាំកន្លងនេះមកហើយ។ ដូច្នេះអាស្រ័យទៅលើមេធាវីការពារ ក្ដីដែលត្រូវលើកឡើង ហេតុអ្វីបានជាឯកសាររបស់យើងខ្ញុំមានការពាក់ព័ន្ធ? ហើយហេតុអ្វីបានជាមិន គួរឱ្យជឿជាក់បាននៅក្នុងឯកសារមួយក្រឡេកភ្នែកនេះ?

[១១:១៥:២០]

ជាពិសេសឯកសារនៅក្នុងឧបសម្ព័ន្ធ៥ ហើយក៏ដូចជាឯកសារពីឧបសម្ព័ន្ធ១ ដល់៥ នោះផង ដែរ។ ឯកសារទាំងអស់នេះ គឺជាឯកសារមួយដែលពាក់ព័ន្ធទៅនឹងស្ថានភាពទាំងអស់នេះ យើងខ្ញុំយល់ ថាវាមានការពាក់ព័ន្ធ ប៉ុន្តែវាអាស្រ័យទៅលើមេធាវីការពារក្ដីដែលត្រូវលើកអំណះអំណាងថា ហេតុអ្វី បានវាមិនមានការពាក់ព័ន្ធនោះ?

ជំហររបស់សហព្រះរាជអាជ្ញា គឺថាឯកសារនេះគួរឱ្យជឿជាក់បានមួយក្រឡេកភ្នែក ហើយ យើងបានដាក់ចូលនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ សម្រាប់ការជំនុំជម្រះដំណាក់កាលទីមួយនេះ។ ទាក់ទងទៅនឹងភាពគួរឱ្យជឿជាក់បានដែលក្រុមមេធាវីការពារក្ដី ដែលទាមទារឱ្យមានការបង្ហាញឯកសារ ដើមនោះ យើងបានលើកឡើងថា ឯកសារដើមនេះគឺមិនបានបង្ហាញទេ ហើយមិនបានដាក់ជូននោះទេ។ អង្គជំនុំជម្រះបានសម្រេចទៅលើបញ្ហានេះ ថាឯកសារដើមគឺមិនចាំបាច់តម្រូវឱ្យមាននៅក្នុងអង្គជំនុំជម្រះ នោះទេ ហើយសេចក្ដីសម្រេចនេះមិនមានតែសម្រាប់សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង នៅទីនេះទេ ក៏ប៉ុន្តែជាការអនុវត្តទូទៅនៅកម្រិតតុលាការអន្តរជាតិមួយចំនួន ថាបើសិនណាជាឯកសារ ដើមត្រូវឱ្យមានការបង្ហាញនោះ គឺតែក្នុងករណីពិសេស ហើយបើមានការទាមទារបែបនោះ ដំណើរការ រឿងក្ដីនៃសំណុំរឿងនេះនឹងមិនមានទីបញ្ចប់នោះទេ។ហើយក្រុមមេធាវីការពារក្ដីចង់ឱ្យបង្ហាញនូវឯកសារ ដើមទាំងអស់នោះ គឺមិនមែនជាការពិចារណារបស់អង្គជំនុំជម្រះទេ។ អង្គជំនុំជម្រះគ្រាន់តែសុំឱ្យមាន បង្ហាញនូវស្ទូចនាករមួយតែប៉ុណ្ណោះ ដែលបង្ហាញថាឯកសារនេះគឺមានភាពគួរឱ្យជឿជាក់បានតែប៉ុណ្ណោះ។

[១១:១៦:០៩]

ក្រុមមេធាវីការពារក្ដី នួន ជា នៅថ្ងៃនេះ ជាពិសេសទាក់ទងទៅនឹងឧបសម្ព័ន្ធ៥ ជាពិសេស

ដោយការលើកឡើងដោយមេធាវីជាតិ ហាក់ដូចជាមានការពង្រីកឲ្យមានការបង្ហាញឯកសារនៅក្នុងឧបសម្ព័ន្ធ១ ដល់៥។ ថាតើហេតុអ្វីបានជាយើងមិនអាចដឹងថា ឯកសារទាំងអស់នេះ មិនមានឯកសារដើម តាំងពីឧបសម្ព័ន្ធ១ ដល់៥ នោះ។ បើនៅក្នុងពេលនេះ គឺមិនមានមូលដ្ឋានអង្គហេតុណាដែលគាត់លើកឡើងដើម្បីឲ្យអង្គជំនុំជម្រះមានវិមតិសង្ស័យថាឯកសារទាំងនេះ វាយ៉ាងណានោះទេ។ ហើយដោយសារតែឯកសារទាំងអស់នេះទាក់ទងទៅនឹងជនជាប់ចោទ ដែលថាគាត់អាច-- អាហ្នឹងដោយសារគាត់ជាមេដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាចន្លោះពីឆ្នាំ៧៥ ដល់៧៩។

[១១:១៧:០៣]

សេចក្តីថ្លែងការណ៍របស់ជនជាប់ចោទ គិតថាមេធាវីការពារក្តីអាចលើកគឺថា សេចក្តីថ្លែងការណ៍របស់កូនក្តីរបស់ខ្ញុំនេះ គឺមិនត្រឹមត្រូវទេ ជាសេចក្តីថ្លែងការណ៍មិនពិតទេ ក្លែងក្លាយទេ មិនអ្នកណាអាចនិយាយដូច្នេះបានទេ។ ទាក់ទងទៅនឹងការផ្សព្វផ្សាយរបស់បក្សកុម្មុយនីស្តកម្ពុជា មិនមានមេធាវីការពារក្តីមួយលើកឡើងថា ការផ្សព្វផ្សាយនេះ ជាសេចក្តីផ្សព្វផ្សាយមិនពិតនោះ។ ជនជាប់ចោទគាត់អាចដឹង ហើយប៉ុន្តែមិនមានជនជាប់ចោទបានលើកនេះ ជាពិសេសទាក់ទងទៅនឹងការប្រាស្រ័យទាក់ទងកំណត់ហេតុអង្គប្រជុំ ក៏ដូចជាសេចក្តីថ្លែងការណ៍នៅក្នុងរបបនោះផងដែរ។

ដូចដែលយើងខ្ញុំបានដាក់ជូនតាំងពីដើមមកនោះ គឺថាលក្ខខណ្ឌនេះគឺជាលក្ខខណ្ឌមួយសម្រាប់តែការដាក់ឯកសារដែលគួរឲ្យជឿបានក្នុងមួយក្រឡេកភ្នែកតែប៉ុណ្ណោះ ហើយមិនមានជនជាប់ចោទណាម្នាក់បង្ហាញថា ឯកសារទាំងនេះមិនមានការពាក់ព័ន្ធនោះទេ។ ហើយទីពីរ ទាក់ទងទៅនឹងភាពគួរឲ្យជឿជាក់បាននោះ យើងខ្ញុំគិតថា វាជាការសមស្របដែលគួរឲ្យលើកឡើងថា ការស្តាប់ទៅលើការបង្ហាញរបស់ព្រះរាជអាជ្ញានៅក្នុងសប្តាហ៍នេះគឺថា ជាផ្ទៃក្នុងនោះ គឺឯកសារទាំងនេះ វាស៊ីសង្វាក់គ្នាទាំងអស់។ ស្ទើរតែឯកសារគ្រប់ប្រភេទទាំងអស់មានការស៊ីសង្វាក់គ្នា ជាឯកសារមួយដែលអាចមានយថាភាព ហើយបើយើងប្រៀបធៀបទៅនឹងឯកសារដទៃៗទៀត។ ឯកសារដទៃៗទៀតនោះ ក៏និយាយរឿងតែមួយ។ និយាយពីគោលនយោបាយតែមួយ និយាយម្តងហើយម្តងទៀត អំពីតួនាទី និងមុខងាររបស់ជនជាប់ចោទ។ វាពិបាកនឹងស្វែងរកឲ្យឃើញថា ឯកសារណាមួយមិនស៊ីសង្វាក់គ្នាណាស់ បើយើងប្រៀបធៀបទៅនឹងទម្រង់នៃឯកសារទាំងអស់នេះ។

[១១:១៨:៥៤]

សហព្រះរាជអាជ្ញាសុំស្នើឲ្យអង្គជំនុំជម្រះពិនិត្យមើលឲ្យបានទូលំទូលាយទៅលើបរិបទនៃឯកសារ

នេះ ជាជាងគ្រាន់តែលើកយកឯកសារតែមួយយកមកជំទាស់តវ៉ានោះ។ ពីព្រោះនៅក្រោមយុត្តិសាស្ត្រអន្តរជាតិវាច្បាស់ហើយថា ដើម្បីបង្ហាញអំពីខ្សែសង្វាក់នៃការទទួលខុសត្រូវនៃការបញ្ហានោះ គឺមិនតម្រូវឱ្យធ្វើបែបនេះទេ ប៉ុន្តែនៅក្នុងករណីមួយចំនួន ប្រហែលជារសៀលនេះ ប្រហែលជាយើងបានឮពីក្រុមមេធាវីការពារក្តី អៀង សារី ដែលគាត់បានធ្វើការនៅ អាយ.ស៊ី.ធី.វ៉ាយ នោះ តើគេធ្វើដោយរបៀប? ហើយករណីជាច្រើន សាក្សីនឹងចូលខ្លួនមកបង្ហាញអំពីខ្សែសង្វាក់នៃការបញ្ជានៃឯកសារជាក់លាក់មួយចំនួន ប៉ុន្តែមិនចាំបាច់បង្ហាញគ្រប់ឯកសារទាំងអស់នោះទេ។

[១១:១៩:៤១]

ហើយជាពិសេស តាមសំណើរបស់សហព្រះរាជអាជ្ញា គឺថាយើងនឹងស្នើសុំឱ្យតំណាងណាម្នាក់ពីមជ្ឈមណ្ឌលកម្ពុជាចូលខ្លួនមកបង្ហាញជូនតុលាការ ថាតើប្រតិបត្តិការនៃសារទូរលេខគេធ្វើដោយរបៀបណា? ហើយតើៗទង់បដិវត្តនោះ វាត្រូវចេញផ្សព្វផ្សាយដោយរបៀបណា?

នេះគឺជាឆន្ទានុសិទ្ធិរបស់តុលាការដែលត្រូវកោះហៅសាក្សីដើម្បីបង្ហាញ ហើយប៉ុន្តែអង្គហេតុទាំងអស់នេះបានដាក់ជូនអង្គជំនុំជម្រះរួចមកហើយ។ ហើយទាក់ទងទៅនឹងភាពគួរឱ្យទុកចិត្តបាននេះ សូម្បីតែទាក់ទងទៅនឹងផ្នែកតូចតាចណាមួយនៃឯកសារដែលបានកែប្រែក៏ដោយ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ប្រសិនណាបើមិនមានការបង្ហាញនៃការខ្សែសង្វាក់ មិនមានការបង្ហាញអំពីការរក្សាទុកនូវឯកសារនេះ ពីកន្លែងមួយទៅកន្លែងមួយ ហើយតែគេរកឃើញនៅកន្លែងណានោះទេ។ ឧទាហរណ៍ថាមិនអាចអ្នកណាម្នាក់អាចបង្ហាញអំពីការរក្សាឯកសារទាំងនេះបាននោះទេ ក៏វាអាស្រ័យនៅលើអង្គជំនុំជម្រះ ថាតើវាមានភាពគួរឱ្យជឿជាក់បានក្នុងកម្រិតអប្បបរមាដែរឬទេ?

[១១:២០:៥៧]

តុលាការអន្តរជាតិ ខ្ញុំជឿជាក់ថាតុលាការជាតិផងដែរ គឺគេនឹងពិនិត្យមើលទៅលើចរិតលក្ខណៈផ្ទៃក្នុងនៃឯកសារនេះ ក៏ជាចរិតលក្ខណៈផ្ទៃក្រៅនៃឯកសារនេះ ថាតើចរិតលក្ខណៈខាងក្នុង និងខាងក្រៅនៃឯកសារនេះ វាមានទំនាក់ទំនងគ្នាដោយរបៀបណា? ហើយនៅពេលធ្វើសេចក្តីសន្និដ្ឋាននេះ គឺយើងខ្ញុំសូមលើកឡើងថា ការបង្ហាញជូនជាសង្ខេបនៅក្នុងសប្តាហ៍នេះ គឺអង្គជំនុំជម្រះនឹងអាចរកបាននូវភាពគួរឱ្យជឿជាក់បានក្នុងកម្រិតអប្បបរមាហើយ។

យើងខ្ញុំគ្រាន់តែសួរថាឯកសារប៉ុន្មានដែលអង្គជំនុំជម្រះបានទទួល និងភាគីដទៃទៀតបានដាក់ជូននោះ?

[១១:២១:៤៦]

សូមអភ័យទោស ខ្ញុំស្មានថាមានបញ្ហាអី ខ្ញុំនៅឆ្ងល់ដែរ ថាតើមានឯកសារប៉ុន្មាននៅក្នុងសំណុំរឿងនេះ ជាពិសេសនៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា ដែលអង្គជំនុំជម្រះបានទទួលយក និងមេធាវីការពារក្តីបានទទួលយក ឬក៏ដើមបណ្តឹងរដ្ឋប្បវេណីបានទទួលយក។ គេបានលើកឡើងថាឯកសារទាំងអស់នេះ ហាក់ដូចជាក្លែងក្លាយ។ វាមិនជាឯកសារពិតប្រាកដនោះទេ។ វាហាក់ដូចជាមិនស៊ីសង្វាក់ទៅលើប្រភេទនៃឯកសារផ្សេងទៀត។

យើងខ្ញុំសន្និដ្ឋានថាជាពិសេស ជាជំហររបស់ខាងសហព្រះសហព្រះរាជអាជ្ញា ដែលថាឯកសារទាំងឡាយដែលយើងបានដាក់ គឺវាមានភាពស៊ីសង្វាក់គ្នាទៅនឹងភស្តុតាងទាំងមូល ហើយយើងខ្ញុំសូមលើកឡើងថា ទោះបីជាយើងបានស្តាប់ឮនៅក្នុងសប្តាហ៍នេះថា ជាពិសេសក្រុម នួន ជា ថាយើងចង់ឲ្យបុគ្គលនេះមកផ្តល់សក្ខីកម្ម ដែលថាឯកសារមិនអាចទទួលយកបានទេ លើកលែងតែលោក ឆាំង យុ មកផ្តល់ចម្លើយ។ នេះមិនមែនជាលក្ខខណ្ឌច្បាប់នោះឡើយ។

[១១:២២:៤៧]

ដូច្នេះហើយវាមិនមែនជាការត្រូវទាមទារឲ្យលោក ឆាំង យុ មកចូលក្នុងតុលាការនោះទេ។ វាមិនមែនជាលក្ខខណ្ឌច្បាប់នោះឡើយ។ ដូចដែលអង្គជំនុំជម្រះបានដឹងរួចមកហើយ យើងបានដាក់ហើយថាលោក យុ ឆាំង ជាសាក្សី ដែលអាចមកផ្តល់យថាភាពអំពីឯកសារប្រសិនបើចាំបាច់។ ក៏ប៉ុន្តែយើងខ្ញុំចាប់អារម្មណ៍ថា ប្រសិនបើវាមានចាំបាច់ក្នុងការបង្ហាញដាច់ខាតនោះ យើងអាចធ្វើដូច្នេះបាន។

ដូច្នេះប្រសិនបើយើងពិនិត្យមើល យើងត្រូវតែបង្ហាញនាំអ្នកសរសេរឯកសារគ្រប់បែបយ៉ាងនោះ ហើយយើងត្រូវរកឃើញថាតើនរណាគេ តើឯកសារនេះរៀបចំដោយរបៀបណានោះ យើងនឹងធ្វើការងារច្រើនណាស់បើតាមផ្លូវច្បាប់។

[១១:២៣:៣៥]

ដូច្នេះ វាហាក់ដូចជាមិនឲ្យអង្គជំនុំជម្រះគិតពិចារណាអំពីការវាយតម្លៃទៅលើឯកសារនៅចំពោះមុខអង្គជំនុំជម្រះ។ ដូច្នេះហើយ វាបង្ហាញយ៉ាងច្បាស់ថា សហព្រះរាជអាជ្ញា យើងសូមលើកឡើងអំពីការលើកឡើងរបស់មេធាវីលោក នួន ជា។ ការលើកឡើងនោះ យើងខ្ញុំយល់ឃើញថា សហព្រះរាជអាជ្ញា គាត់លើកឡើងថាសហព្រះរាជអាជ្ញាមិនចង់បង្ហាញការពិត ហើយចង់ឲ្យអង្គជំនុំជម្រះយល់ច្រឡំតាមរយៈឯកសារទាំងអស់នេះ។ នេះមិនមែនជាករណីដូច្នេះទេ។ យើងមានកាតព្វកិច្ចក្រមសីលធម៌

របស់យើង។ មានកាតព្វកិច្ចធ្វើយ៉ាងណាឲ្យភស្តុតាងដែលដាក់នៅចំពោះមុខអង្គជំនុំជម្រះនេះ អាចជឿជាក់បាន ឲ្យបានពិតប្រាកដ និងមានភាពពាក់ព័ន្ធ ដើម្បីឲ្យអង្គជំនុំជម្រះអាចរកការពិតបាន។

ដូច្នេះការសម្រេចចុងក្រោយ ជាកាតព្វកិច្ចរបស់អង្គជំនុំជម្រះ។ ក៏ប៉ុន្តែយើងក៏មានកាតព្វកិច្ចក្នុងការបង្ហាញនូវឯកសារទាំងអស់នេះ។

[១១:២៤:៣៥]

សហព្រះរាជអាជ្ញា គឺប្រសិនបើមិនអនុញ្ញាតឲ្យដាក់ឯកសារដូចដែលលោកមេធាវី នួន ជា ដែលថាឯកសារជាឯកសារថតចម្លងនោះ យើងមិនអាចចប់នៅក្នុងសវនា-- យើងមិនអាចឈានទៅដល់ទីបញ្ចប់នៃសវនាការនេះបានទេ។

ដោយពិចារណាទៅលើដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះ គឺអង្គជំនុំជម្រះជាអ្នកធ្វើការសម្រេច។ យើងជាសហព្រះរាជអាជ្ញាត្រូវការដាក់ឯកសារ ដែលយើងត្រូវបង្ហាញជាសាធារណៈ។ យើងហាក់ដូចជាមានលក្ខណៈចម្លែកនៅពេលដែលយើងឮ ឃើញស្តាប់ឮថា ជនជាប់ចោទគឺគាត់ធ្វើសេចក្តីសម្រេចបាន ប្រសិនបើគាត់មានឯកសារដើមនៅចំពោះមុខ។ លោក នួន ជា គាត់មានតួនាទីទីពីរ ធំបំផុតនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា។ ដូច្នេះហើយគឺគាត់ប្រាកដជាស្គាល់ឯកសារទាំងអស់នេះហើយ ក៏ប៉ុន្តែគាត់លើកឡើងថា គាត់មិនអាចទទួលយកឯកសារនេះបាននេះទេ ដរាបណាគាត់មិនឃើញឯកសារពណ៌។ នេះមិនមែនជាលក្ខខណ្ឌច្បាប់ដែលយើងគិតអំពីការទទួលយកបាននោះឡើយនៃឯកសារ។

[១១:២៥:៤៤]

សហព្រះរាជអាជ្ញារួមទាំងតុលាការ ត្រូវតែធ្វើយ៉ាងណាទទួលយកការបញ្ជាក់ពីខាងជនជាប់ចោទ។ អង្គជំនុំជម្រះអាចធ្វើការសួរអំពីការធ្វើអត្ថាធិប្បាយរបស់ជនជាប់ចោទទៅលើឯកសារទាំងអស់នេះ ក៏ប៉ុន្តែវាមិនមែនជាលក្ខខណ្ឌដែលជនជាប់ចោទត្រូវសម្រេចថា តើឯកសារទាំងអស់នោះមានយថាភាព ឬក៏អត់នោះទេ។ គាត់គ្រាន់តែមានសិទ្ធិក្នុងការផ្តល់ភស្តុតាងតែប៉ុណ្ណោះ។ ដូច្នេះ យើងខ្ញុំស្នើសុំថា សុំឲ្យធ្វើការទាត់ចោល ដែលថាយើងត្រូវតែបង្ហាញឯកសារទាំងអស់ទៅកាន់លោក នួន ជា ថាតើវាទុកចិត្ត ឬក៏មិនអាចទុកចិត្តបាននោះ មុនពេលដែលមានការចេញសេចក្តីសម្រេចពីអង្គជំនុំជម្រះ។

[១១:២៦:៣៥]

យើងខ្ញុំយល់ឃើញថានេះមិនមែនជាលក្ខខណ្ឌដែលទាមទារឲ្យធ្វើដូច្នោះនោះទេ វានឹងចំណាយពេលរហូតមិនចេះចប់ឡើយ។ ដូច្នេះហើយខ្ញុំសូមឆ្លើយតបទៅក្រុមមេធាវី នួន ជា ថាឲ្យមេធាវី នួន ជា

និយាយជាមួយនឹងកូនក្ដីរបស់ខ្លួន ដែលថាពួកគាត់យល់អំពីឯកសារដែលសហព្រះរាជអាជ្ញាដាក់នៅចំពោះមុខអង្គជំនុំជម្រះតាំងពីខែមេសា ឆ្នាំ២០១១។ ដូច្នេះ ការដែលថាមិនអាចមកក្នុងតុលាការ ហើយលើកឡើងថាកូនក្ដីរបស់ខ្លួនមិនអាចឆ្លើយបានទេ ដោយសារមិនមានឯកសារដើមនោះ។ គឺវាជាលទ្ធភាពមួយដែលថាមេធាវីការពារក្ដីគួរតែធ្វើការពិភាក្សាជាមួយនឹងកូនក្ដីរបស់ខ្លួន។ ហើយវាមិនមែនថា អង្គជំនុំជម្រះត្រូវតែធ្វើការបើកសវនាការទៅលើជនជាប់ចោទម្នាក់ម្ដងៗ ដើម្បីឲ្យសម្រេចទៅលើឯកសារទាំងអស់ដែលថាអាចទទួលយកបាននោះទេ។

[១១:២៧:៣៨]

លោក លោកស្រីចៅក្រមជាទីគោរព លក្ខខណ្ឌនេះបានកំណត់យ៉ាងច្បាស់នៅក្នុងច្បាប់។ លើកលែងតែក្រុមលោកមេធាវី ខៀវ សំផន ក្រៅពីនេះក្រុមមេធាវីការពារក្ដីដទៃៗទៀតនោះ ចំពោះលក្ខខណ្ឌនៃការទទួលយកឯកសារយើងត្រូវគោរពទៅតាមវិធាន៨៧(៣) ដែលវាជាលក្ខខណ្ឌនៃការទទួលយកជាបឋម។

កាលពីម្សិលមិញមេធាវីការពារក្ដី ខៀវ សំផន បានលើកឡើងថា ការលើកឡើងទទួលយកឯកសារត្រូវតែបង្ហាញដោយខាងសហព្រះរាជអាជ្ញាឲ្យហួសពីគ្រប់វិមតិសង្ស័យទាំងអស់។

លោក លោកស្រីចៅក្រមជាទីគោរព នេះមិនមែនជាការលើកឡើងត្រឹមត្រូវទេ មិនមែនជាច្បាប់កំណត់ដាច់ខាតដូច្នេះនោះទេ។ ច្បាប់មានថែងហេតុផលរបស់វា វាក៏មិនមែនថាពាក់ព័ន្ធទៅដល់សហព្រះរាជអាជ្ញាគ្រប់ទាំងអស់ ដែលថាត្រូវបង្ហាញអំពីភាពទុកចិត្តបានឲ្យហួសពីវិមតិសង្ស័យនោះទេ។ ការដែលឲ្យយើងតម្រូវឲ្យយើងធ្វើ គឺយើងត្រូវបង្ហាញជាបឋមអំពីភាពជឿជាក់របស់ឯកសារ។ យើងគ្រាន់តែបង្ហាញឲ្យតុលាការឃើញនៅក្នុងពេលចាំបាច់។

[១១:២៨:៤៨]

ពាក្យថា “ជាបឋម” នេះគឺតាមលក្ខណៈក្រឡេកមួយភ្លែតដំបូង។ ដូច្នេះ អ្វីដែលលើកឡើងដោយមេធាវីការពារក្ដីនោះមិនមានខ្លឹមសារត្រឹមត្រូវនោះទេ ដែលថាឯកសារដែលយើងបានដាក់នោះ មិនអាចទទួលយកបានជាបឋម។ វាមិនមានខ្លឹមសារមូលដ្ឋានឡើយ ប្រសិនជាលើកឡើងដូច្នោះ។ មេធាវីការពារក្ដីនៅតែទាមទារឲ្យបំពេញលក្ខខណ្ឌបន្ថែម ហើយនិងបន្ថែមទៀត។ ដូច្នេះខ្ញុំសូមលើកឡើងថា លក្ខខណ្ឌតម្រូវតាមផ្លូវច្បាប់នោះ គឺលក្ខខណ្ឌកម្រិតអប្បបរមាតែប៉ុណ្ណោះ។

ដូច្នេះ ខ្ញុំសូមស្នើសុំឲ្យខាងមេធាវីការពារក្ដីធ្វើការពិនិត្យទៅលើឯកសារតាមតម្រុយនៃការទទួល

យកបាន និងភាពជឿជាក់បាន។ មេធាវីការពារក្ដីត្រូវតែពិនិត្យមើល ថាតើឯកសារទាំងអស់នោះស៊ីសង្វាក់គ្នាទៅនឹងឯកសារដទៃទៀតដោយរបៀបណា? សហព្រះរាជអាជ្ញាបានធ្វើការងារនេះ ហើយបានលើកជាឧទាហរណ៍រួចមកហើយ។ វាមិនមែនថា តាមអ្វីថាដូចដែលកូនក្ដីរបស់គាត់លើកឡើងនោះទេ។ គាត់ត្រូវតែពិនិត្យអំពីតម្រុយនៃភាពទុកចិត្តបាននៃឯកសារ។ មេធាវីលោក អៀង សារី នៅពេលដែលលើកឡើងថា សហព្រះរាជអាជ្ញាមិនបានផ្ដល់ជាការបញ្ជាក់នូវឯកសារ ប៉ុន្តែផ្ដល់ជាភស្តុតាងតែប៉ុណ្ណោះ វាមិនត្រឹមត្រូវនោះទេ។ សហព្រះរាជអាជ្ញា គឺបានបង្ហាញអំពីភាពស៊ីសង្វាក់គ្នានៃឯកសារជាបឋម។

កំណត់សញ្ញាសម្គាល់ ឡូហ្គោ និងភាសាដែលបានប្រើប្រាស់ទាំងអស់នោះ គឺវាភ្ជាប់គ្នា និងស៊ីសង្វាក់គ្នាទៅនឹងឯកសារដែលមាននៅក្នុងសំណុំរឿង។ យើងមិនមែនមកផ្ដល់ភស្តុតាងនៅក្នុងដំណាក់កាលនេះទេ វាគ្រាន់តែជាការគូសបញ្ជាក់ថា តើភស្តុតាងឯកសារទាំងអស់នោះ មានភាពស៊ីសង្វាក់គ្នាយ៉ាងម៉េច។ ជាការពិត ហេតុផលដែលយើងបានលើកការជំទាស់ដូចដែលថាសហព្រះរាជអាជ្ញាកំពុងតែផ្ដល់ជាភស្តុតាងនោះ អ្វីដែលយើងបានបង្ហាញនេះគឺជាសញ្ញាបញ្ជាក់ និងតម្រុយបញ្ជាក់នៃភាពទុកចិត្តបាននៃឯកសារ។

[១១:៣០:៥៥]

មេធាវីការពារក្ដីហាក់ដូចជាមិនចង់ឲ្យមានករណីនេះកើតឡើង។ មេធាវី អៀង សារី មិនចង់ឃើញស្ថានភាពបែបនេះ មិនចង់ធ្វើវិភាគទៅលើភស្តុតាង និងឯកសារដែលវាបង្ហាញជាតម្រុយនៃភាពទុកចិត្តបាននៃឯកសារ។ ដូច្នេះចំណុចនេះមានន័យថាយើងអាចទទួលយកឯកសារបាន វាជាការត្រឹមត្រូវនៅពេលដែលយើង នៅពេលមេធាវី អៀង សារី បានលើកឡើងបង្ហាញអំពីយុត្តិសាស្ត្ររបស់តុលាការដែលថាពួកគាត់បានដាក់ទឡ្ហីករណ៍របស់ខ្លួនចំនួនពីរ។ ចំណុចទីមួយ គាត់លើកឡើងថាភាពទុកចិត្តបាននៃឯកសារ គឺមិនបានបង្ហាញឲ្យយើងឃើញ។ ក៏ប៉ុន្តែគាត់បានលើកឡើងម្ខាងទៀតថា ប្រសិនបើអង្គជំនុំជម្រះជឿជាក់ថាតម្រុយនៃការទុកចិត្តបាន និងភាពជឿជាក់បាន បានបង្ហាញនោះ យើងគួរតែផ្ដល់ទម្ងន់តិចតួចបានហើយ។ ជំហរដែលបានលើកឡើងដោយក្រុមមេធាវីការពារក្ដីដូច្នេះ គឺជាជំហរដែលគេបានលើកឡើងនៅក្នុងតុលាការអន្តរជាតិ។ ក៏ប៉ុន្តែលក្ខខណ្ឌអប្បបរមានៃការទទួលយកឯកសារ វាមានកម្រិតទាប ប៉ុន្តែវាមាន។

[១១:៣២:០៦]

ជាបឋម គឺថាយើងត្រូវពិនិត្យអំពីភាពទុកចិត្តឲ្យបាននៃឯកសារ ហើយបន្ទាប់មកយើងអាចសន្និត

ថា វាជាលក្ខខណ្ឌមួយនៃការទទួលយកបាននៃឯកសារ។ ដូច្នេះហើយបញ្ហានេះ យើងត្រូវពិចារណា។ នៅពេលដែលយើងមើលតុលាការកំពូល នៅតុលាការរវ៉ាន់ដា បានលើកឡើងអំពីបញ្ហានេះគឺតុលាការនោះបានបង្ហាញអំពីលក្ខខណ្ឌអប្បបរមា។ ជាការពិត លក្ខខណ្ឌអតិបរមានៃការទទួលយកនៃឯកសារនោះក៏គេមានចែងផងដែរ។

[១១:៣២:៤២]

ខ្ញុំសូមឲ្យលោក លោកស្រីចៅក្រម ធ្វើការពិនិត្យមើលឯកសារ *លូចាំងហ្កា* នៅក្នុងកថាខណ្ឌ៦៦ ដែលក្នុងនោះគេបានបែងចែកអំពីតម្លៃនៃភស្តុតាង និងភាពទទួលយកបាននៃឯកសារ។ លក្ខខណ្ឌដែលទទួលយកបានចំពោះឯកសារនោះ វាមានលក្ខណ:ខ្ពស់ វាត្រូវតែបង្ហាញនូវភស្តុតាងដែលវាពាក់ព័ន្ធទៅនឹងតម្រុយនៃភាពទុកចិត្តបាន ដើម្បីចៀសវាងនូវការបាត់តម្លៃនៃភស្តុតាង។ នៅក្នុងការយល់ឃើញរបស់តុលាការកំពូល យើងមិនអាចបកស្រាយថា ការបង្ហាញអំពីភាពទុកចិត្តបាន វាចាំបាច់ដែលទាមទារនៅក្នុងការទទួលយកភស្តុតាងនោះឡើយ។ ការបង្ហាញនៃភាពទុកចិត្តបាន ដោយផ្អែកទៅលើតម្រុយនៃទុកចិត្តបាននៃឯកសារ គឺជាលក្ខខណ្ឌមួយគ្រប់គ្រាន់រួចទៅហើយ។

[១១:៣៣:៤១]

ដូច្នេះ លោក លោកស្រីចៅក្រមគួរតែពិចារណា ពិនិត្យទៅលើគ្រប់ភស្តុតាងទាំងអស់។ ជាពិសេសនៅក្នុងករណី ដែលអង្គជំនុំជម្រះមិនអាចមើលឃើញទៅលើសំណុំឯកសារទាំងអស់ដែលមាន។ វាមានលក្ខណ:ពិបាកក្នុងការសម្រេចថា តើជនជាប់ចោទទាំងអស់នោះ មានតួនាទីយ៉ាងម៉េចនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ប្រសិនបើយើងមិនមើលឯកសារទាំងអស់? ហើយយើងក៏មិនអាចដឹងថាតើគាត់មានតួនាទីយ៉ាងម៉េចនៅក្នុងសហឧក្រិដ្ឋកម្មរួម? ហើយរចនាសម្ព័ន្ធមានតួនាទីយ៉ាងម៉េចនៅក្នុងរចនាសម្ព័ន្ធនៃការទំនាក់ទំនង?

ដូច្នេះ នៅពេលដែលក្រុម នួន ជា បានលើកឡើងថា ប្រសិនបើឯកសារទាំងអស់នេះពាក់ព័ន្ធទៅនឹងការជម្លៀសដោយបង្ខំនោះ គឺវាមិនមែនជាបញ្ហាពាក់ព័ន្ធនោះទេ។ បញ្ហាពាក់ព័ន្ធនោះគឺថាតើឯកសារទាំងអស់នេះមានជាប់ពាក់ព័ន្ធដែរឬទេ? ហើយមេដឹកនាំទាំងអស់នោះមានជាប់ពាក់ព័ន្ធយ៉ាងម៉េចទៅនឹងការប្រព្រឹត្តបទល្មើស? មេធាវីបានលើកឡើងថា ពួកគាត់ទាំងអស់បានធ្វើការជម្លៀសទៅ-- ធ្វើការជម្លៀសប្រជាជន ក៏ប៉ុន្តែតាមរយ:កូនចៅរបស់គាត់។ ដូច្នេះហើយនៅពេលនេះ យើងមិនមែននិយាយអំពីការជម្លៀសដោយបង្ខំនោះទេ។ យើងគ្រាន់តែបង្ហាញថាតើជនជាប់ចោទពាក់ព័ន្ធយ៉ាងម៉េចទៅនឹង

ការជម្លៀសទាំងអស់នោះ បទល្មើសទាំងអស់។ ដូច្នេះហើយលោក លោកស្រីចៅក្រមមានភស្តុតាងជារួម និងជាច្រើនក្នុងការពិចារណាមើល។

[១១:៣៥:១៧]

ការដែលលើកឡើងតែឯកសារមួយតែប៉ុណ្ណោះថា លោក អៀង សារី ឬក៏ខៀវ សំផន មិនមានអានុភាព មិនមានឥទ្ធិពលទេនៅក្នុងរបបនោះវាមិនគ្រប់គ្រាន់នោះទេ។ យើងត្រូវតែបង្ហាញឲ្យឯកសារឲ្យបានច្រើន ដើម្បីបង្ហាញឲ្យហួសពីវិមតិសង្ស័យ។ សំណុំឯកសារយ៉ាងច្រើន គឺបានចង្អុលបង្ហាញដូចគ្នា ដែលថាជនជាប់ចោទនីមួយៗមានតួនាទីខ្ពស់ ជនជាប់ចោទនីមួយ គឺគាត់បានប្រាស្រ័យទាក់ទងគ្នាអំពីគោលនយោបាយឧក្រិដ្ឋ ជនជាប់ចោទនីមួយៗបានពិនិត្យមើលរចនាសម្ព័ន្ធ និងប្រព័ន្ធទំនាក់ទំនងដែលអនុញ្ញាតឲ្យកូនចៅរបស់ខ្លួនប្រព្រឹត្តនូវបទល្មើស។

[១១:៣៦:០១]

ការបង្ហាញឲ្យហួសពីវិមតិសង្ស័យ គឺជាទិដ្ឋភាពមួយ គឺជាទិដ្ឋភាពសំខាន់ដែលសហព្រះរាជអាជ្ញាត្រូវតែមានតួនាទីខ្ពស់ យើងមិនមែនមកតែតុលាការនេះផ្តល់ត្រឹមតែភស្តុតាងនោះទេ។ យើងត្រូវតែបង្ហាញរឿងក្តីនេះឲ្យហួសពីវិមតិសង្ស័យ អ្វីដែលយើងសូមលើកឡើង គឺយើងត្រូវតែស្តាប់រឿងក្តីនេះ ប្រសិនបើយើងមិនដាក់ភស្តុតាងនោះទេ វាហាក់ដូចជាបង្កើតបញ្ហាឲ្យយើងយ៉ាងខ្លាំង។ ដូច្នេះ ភស្តុតាងវានឹងមិនគ្រប់គ្រាន់នោះឡើយ។ យើងក៏នឹងស្តាប់មេធាវីការពារក្តីផងដែរ ប្រសិនបើយើងមិនមានឯកសារយើងមិនអាចមានលទ្ធភាពពិនិត្យពិចារណានោះឡើយ។ ដូច្នេះហើយ អង្គជំនុំជម្រះត្រូវធ្វើការសម្រេចនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនដែលត្រូវការពិនិត្យភស្តុតាង និងឯកសារទាំងអស់នោះ។

[១១:៣៦:៥៦]

លោក លោកស្រីចៅក្រមជាទីគោរព នៅដើមសប្តាហ៍នេះ យើងបានលើកឡើងអំពីចំណុចនានាជាពិសេសចំពោះសារៈសំខាន់នៃភស្តុតាងជាឯកសារ។ ភស្តុតាងជាឯកសារ គឺជាឯកសារដែលបានបង្កើតឡើងក្នុងសម័យនោះ ជាពិសេសវាជាឯកសារសំខាន់ទោះបីជានៅក្នុងតុលាការណាក៏ដោយ ឯកសារទាំងអស់នោះវាបង្ហាញអំពីការចេតនារបស់ជនជាប់ចោទ វាបង្ហាញអំពីរចនាសម្ព័ន្ធការងាររបស់អង្គការ វាបង្ហាញអំពីអង្គហេតុដែលបានកើតឡើងនៅតាមមូលដ្ឋាន។ ដូច្នេះ វាមិនអាចរលត់បាត់បង់នោះទេ ពីពេលមួយទៅពេលមួយ។ ចំពោះការចងចាំរបស់មនុស្សទាំងឡាយ វាអាចល្អ ប៉ុន្តែមនុស្សមួយចំនួនទៀតមិនអាចចងចាំល្អនោះទេ។ ដូច្នេះហើយវាមិនអាចផ្តល់សក្ខីកម្មឲ្យយើងបានគ្រប់គ្រាន់នោះទេ មានកត្តា

ជាច្រើនដែលយើងកើតមានឡើងចំពោះបញ្ហាទាំងអស់នេះ។

[១១:៣៧:៥៤]

លោក លោកស្រីចៅក្រមបានដឹងរួចមកហើយ មេធាវីបានលើកឡើងរួចមកហើយ ពេលខ្លះទៅវាពិបាកចំពោះមនុស្ស ការគិតពិចារណារបស់មនុស្ស ហើយនិងការចងចាំរបស់មនុស្ស។ ដូច្នេះចំពោះឯកសារវាមិនបានបាត់បង់ដូចនឹងការចងចាំរបស់មនុស្សនោះឡើយ។

ពាក់ព័ន្ធទៅនឹងវិធីសាស្ត្រវិញ មេធាវីលោក អៀង សារី បានលើកឡើងរួចមកហើយ ថាតើយើងអាចរកម្កុលយ៉ាងម៉េច? យើងអាចយល់ឃើញថាភស្តុតាងនីមួយៗនោះសំខាន់យ៉ាងម៉េច ប្រសិនបើយើងប្រៀបធៀបទៅលើឯកសារដែលបានដាក់ជូនដោយសហព្រះរាជអាជ្ញា? គាត់លើកឡើងថា តើវាសំខាន់យ៉ាងម៉េច ហើយវាមិនសំខាន់យ៉ាងម៉េចចំពោះឯកសារទាំងអស់នោះ?

ឧបសម្ព័ន្ធទាំង២០ ដែលមាននៅក្នុងសំណុំរឿងរបស់សហព្រះរាជអាជ្ញា គឺយើងដើម្បីបង្ហាញបទល្មើសនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ សហព្រះរាជអាជ្ញាលើកឡើងថា វាមិនមែនមានឯកសារតែមួយនោះទេ នៅក្នុងបញ្ជីនោះ បញ្ជីទាំងអស់នោះប្រៀបបានទៅនឹងម្កុលគ្រប់បែបយ៉ាងទាំងអស់ ដែលវាចង្អុលបញ្ជាក់អំពីពិរុទ្ធភាពរបស់ជនជាប់ចោទ។ ម្កុលទាំងអស់នោះ មិនមែនថាវារញ៉េរញ៉ៃនោះទេ យើងបានដាក់នៅក្នុងទូនីមួយៗតាមប្រព័ន្ធអេឡិចត្រូនិច ដាក់តាមប្រភេទនៃការរៀបរាប់ តាមកាលបរិច្ឆេទ តាមអ្នកនិពន្ធ ហើយឯកសារទាំងអស់នោះបានចង្អុលបញ្ជាក់អំពីការចោទប្រកាន់ទៅតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ វាមិនមានអ្វីដែលថាមិនច្បាស់លាស់នៅក្នុងរឿងក្តីនេះទេ វាមិនមែនថាច្រើនពេកសម្រាប់យើងនោះទេ ឯកសារមានរួចមកហើយ យើងបានដាក់តាមលំដាប់លំដោយភាពពាក់ព័ន្ធក៏នៅក្នុងហ្នឹង ភាពទុកចិត្តបាន។ ក៏អាចមើលបានដែរ ប្រសិនបើយើងមើលទៅលើឯកសារទាំងអស់នៅក្នុងនោះ។

[១១:៣៩:៥២]

ចំណុចចុងក្រោយខ្ញុំសូមលើកឡើងអំពីកាតព្វកិច្ច និងភារកិច្ចនៅក្នុងសវនាការនេះ។ ដូចដែលយើងយល់ច្បាស់ទាំងអស់គ្នារួចមកហើយ ដែលថាអង្គជំនុំជម្រះត្រូវតែមានកាតព្វកិច្ចស្វែងរកការពិតទៅតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ វាជាកាតព្វកិច្ចជាសាធារណៈ ដើម្បីផ្តល់ជូនទៅដល់ជនរងគ្រោះ ហើយក៏ជាកាតព្វកិច្ចមួយផ្តល់ជាការពិតទៅដល់ជនជាប់ចោទផងដែរ។ ដូច្នេះយើងត្រូវតែស្តាប់សំឡេង និងស្តាប់សក្ខីកម្មទាំងអស់។ យើងមិនមែនថា មិនត្រូវពិនិត្យមើលភស្តុតាងដោយសារយើងមិនមាន

ឯកសារដើម មិនមានអ្នកនិពន្ធនោះទេ។ គ្រប់ឯកសារទាំងអស់នោះ គឺវាមាន ហើយមិនមែនថាការលើកឡើងដូច្នេះវាបានបំពេញទៅតាមលក្ខខណ្ឌច្បាប់នោះឡើយ។

[១១:៤០:៤១]

ចំណុចទីពីរ កាតព្វកិច្ចមួយទៀត ខ្ញុំសូមផ្តោតចំណុចសំខាន់គឺ កាតព្វកិច្ចសម្រាប់ជនជាប់ចោទ។ បានន័យថា គឺយើងធ្វើយ៉ាងណាបង្ហាញការចោទប្រកាន់ឲ្យហួសពីវិមតិសង្ស័យដែលបានដាក់បន្ទុកទៅលើកជនជាប់ចោទ។ ប្រសិនបើយើងមិនអាចបង្ហាញនោះទេ នឹងមានការកាត់ឲ្យជាប់ពិរុទ្ធភាព ឬក៏មិនអាចរយកឃើញពីពិរុទ្ធភាពនោះទេ។ ដូច្នេះ វាជាកាតព្វកិច្ចសម្រាប់ជនរងគ្រោះដែលត្រូវយើងពិនិត្យមើលគ្រប់ឯកសារ និងកាតព្វកិច្ចសម្រាប់ជនជាប់ចោទផងដែរ។ មេធាវីខាងការពារក្តី នួន ជា និងលោក អៀង សារី ត្រូវតែបង្ហាញឲ្យថា គាត់មិនជាប់ពាក់ព័ន្ធទៅនឹងផែនការឧក្រិដ្ឋ សហឧក្រិដ្ឋកម្មរួម។

[១១:៤១:២៧]

ដូច្នេះយើង-- ពួកគេត្រូវតែមានសិទ្ធិតវ៉ាចំពោះការទទួលយកឯកសារ។ អ្វីដែលយើងបានដាក់ជូនអង្គជំនុំជម្រះតាមរយៈសហចៅក្រមស៊ើបអង្កេត គឺជាសំណុំ និងទម្រង់នៃឯកសារ។ សំណុំនៃឯកសារដែលវាពាក់ព័ន្ធទៅនឹងអង្គហេតុនានា។ យើងខ្ញុំសូមលើកឡើងថា លើកលែងតែយើងអាចបង្ហាញឯកសារទាំងអស់នេះបាន មួលទាំងអស់នេះបាន។ បើមិនដូច្នោះទេ គឺយើងមិនអាចបំពេញកាតព្វកិច្ចរបស់យើងក្នុងការបង្ហាញឲ្យហួសវិមតិសង្ស័យនោះទេ។ ហើយសាលក្រមដែលអង្គជំនុំជម្រះ ដែលបានសម្រេច និងរកឃើញក៏មិនអាចត្រឹមត្រូវនោះដែរ ដោយសារតែមិនមានភស្តុតាងពីខាងសហព្រះរាជអាជ្ញា។

ហើយលោក លោកស្រីចៅក្រម បានបង្ហាញរួចមកហើយនៅក្នុងអនុស្សរណៈរបស់ខ្លួន ដែលថាការសន្មតនោះគឺថា យើងទទួលយកភស្តុតាងដាក់នៅចំពោះមុខ ហើយយើងនឹងគោរពទៅតាមការអនុវត្តរបស់តុលាការអន្តរជាតិ លើកលែងតែយើងមានវិមតិសង្ស័យទៅលើឯកសារនីមួយៗនៅក្នុងសំណុំរឿង។ លក្ខខណ្ឌទាំងឡាយគឺយើងត្រូវតែបំពេញ។

[១១:៤២:៣៦]

ដូច្នេះ ថាតើសារទូរលេខ និងឯកសារមកពី ឌី.ស៊ី.ខេម ឬក៏មក ចេញពីរោងពុម្ពនោះគឺយ៉ាងម៉េចដែរ? យើងខ្ញុំស្នើសុំឲ្យអង្គជំនុំជម្រះទទួលយកឧបសម្ព័ន្ធទាំងប្រាំ ទាំងអស់នោះ ហើយដោយគោរពនិងរង់ចាំទៅមើលភស្តុតាងដទៃទៀត ដែលថាតើមានភស្តុតាងណាមួយដែលវាជំទាស់ដែរឬទេ? លើកលែងតែមានភស្តុតាងផ្ទុយដូច្នេះ គឺឯកសារទាំងអស់នៅតែដាក់នៅចំពោះមុខ និងទទួលយកបានដដែល

ហើយក្រោយមកអង្គជំនុំជម្រះជាអ្នកសម្រេចថាតើមានទម្ងន់ឬមិនមានទម្ងន់? យើងខ្ញុំស្នើសុំឲ្យអង្គជំនុំជម្រះច្រានចោលនូវការជំទាស់របស់មេធាវីការពារក្ដីទាំងអស់ ហើយសូមឲ្យអង្គជំនុំជម្រះទទួលយកនូវឯកសារដែលមាននៅក្នុងគ្រប់ឧបសម្ព័ន្ធទាំងប្រាំ។ សូមអរគុណ។

[១១:៤៣:២៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំបាទសូមការបញ្ជាក់ពីសហព្រះរាជអាជ្ញាបរទេសដែលលោកបានលើកបង្ហាញនៅចុងក្រោយនេះថា មេធាវីត្រូវតែបង្ហាញថាជនជាប់ចោទ គឺមានលោក នួន ជា ឬក៏ អៀង សារី ថាខ្លួននឹងមិនជាប់ពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មរួម។ ខ្ញុំចង់សួរបញ្ជាក់ថា តើលោកមានបានមានប្រសាសន៍បែបនេះមែនទេ? ពីព្រោះអានេះខ្ញុំបានស្ដាប់ឮជាភាសាខ្មែរ ដែលបកប្រែកមក។ អ៊ីចឹងសូមលោកជួយបញ្ជាក់បាទ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អាចបញ្ជាក់បានទេ លោក វីលៀម ស្មីត?

[១១:៤៤:៣៥]

**លោក វីល្លៀម ស្មីត៖**

ខ្ញុំមិនយល់នូវអ្វី-- ខ្ញុំមិនទទួលបានទាំងអស់នូវអ្វីដែលលោកបានលើកឡើងនោះទេ? ខ្ញុំមិនលើកឡើងថាជនជាប់ចោទ ត្រូវតែបង្ហាញឲ្យឃើញថាគាត់មិនមែនចូលរួមនៅក្នុងផែនការឧក្រិដ្ឋនោះទេ។ ប្រហែលជាមានបញ្ហាពាក់ព័ន្ធទៅនឹងការបកប្រែ។

**ប្រធានអង្គជំនុំ៖**

ហើយបញ្ហានេះ បើករណីមិនច្បាស់យ៉ាងម៉េចនោះ គឺសូមមេធាវីលោក ខៀវ សំផន ពិនិត្យនូវប្រតិចារឹកឡើងវិញ ហើយអាចផ្ទៀងផ្ទាត់ទាំងភាសាអង់គ្លេស និងភាសាខ្មែរ ហើយក្នុងករណីភាសាអង់គ្លេសជាភាសាដើម ដែលបានលើកឡើងដោយសហព្រះរាជអាជ្ញារងអន្តរជាតិ។ នេះជាមូលដ្ឋានសំខាន់ ហើយនៅក្នុងការផ្ទៀងផ្ទាត់រវាងប្រតិចារឹកជាភាសាអង់គ្លេស ហើយនិងភាសាខ្មែរ។

ជាកិច្ចបន្តនេះ អង្គជំនុំជម្រះសូមប្រគល់វេទិកាទៅសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្ប-

វេណី ហើយដើម្បីមានឱកាសក្នុងការអះអាងតបទៅនឹងការជំទាស់ទៅនឹងឯកសារក្នុងឧបសម្ព័ន្ធ A5 ដោយក្រោមមេធាវីការពារក្តី។ ហើយអង្គជំនុំជម្រះសូមជម្រាបថា សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេល៣០នាទី ក្នុងការធ្វើអំណះអំណាងតបនេះ។

សូមអញ្ជើញ!

[១១:៤៦:០៣]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន យើងចង់ឲ្យលោកមេធាវី ហុង គឹមសួន ឡើងនិយាយបន្ទាប់មកខ្ញុំនិយាយបន្តពីគាត់។

**ប្រធានអង្គជំនុំ៖**

អនុញ្ញាតលោក ហុង គឹមសួន ជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទទួលសិទ្ធិ។

សូមអញ្ជើញ!

**លោក ហុង គឹមសួន៖**

បាទ, ហុង គឹមសួន ជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ សូមគោរពលោកប្រធាន និងអង្គសវនាការជាទីគោរព។ នៅក្នុងសេចក្តីថ្លែងការណ៍របស់ខ្ញុំបាទទាក់ទងជាមួយនឹងការជំទាស់ទៅលើឯកសារឧបសម្ព័ន្ធ A5 នេះ ខ្ញុំបាទសូមធ្វើការគាំទ្រទាំងស្រុងទៅលើអំណះអំណាងរបស់សហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ។ ដោយហេតុថា នៅក្នុងអង្គសវនាការនេះ លោកមេធាវីការពារក្តី លោកសហព្រះរាជអាជ្ញា និងលោកមេធាវីដើមបណ្តឹងរដ្ឋប្បវេណីដែលបានលើកឡើងតាំងពីដំណាក់កាលនៃឯកសារឧបសម្ព័ន្ធ១ រហូតមកដល់ឯកសារឧបសម្ព័ន្ធ A5 នេះ គឺមានលក្ខណៈជំទាស់នឹងការគាំទ្រប្រហាក់ប្រហែលគ្នារួចមកហើយ។ អ៊ីចឹងនៅក្នុងនេះ ខ្ញុំបាទសូមលើកឡើងតែអំពីអំណះអំណាងដែលទាក់ទងជាមួយនឹងឯកសារឧបសម្ព័ន្ធទី៥ តែប៉ុណ្ណោះ។

[១១:៤៧:២៦]

អម្បាញ់មិញ ខ្ញុំបាន ពីព្រឹកមិញនេះមុនពេលសម្រាកខ្ញុំបានស្តាប់ឮមេធាវីការពារក្តីលោក នួន ជា បានលើកឡើងដដែល ទាក់ទងជាមួយ ប្រហាក់ប្រហែល ខ្ញុំបាទមិនប្រើពាក្យថាដដែលទេ ប្រហាក់ប្រហែលគ្នាជាមួយនឹងការជំទាស់ទៅនឹងឯកសារក្នុងឧបសម្ព័ន្ធ១, ២, ៣, ៤ ដោយលោកនៅតែទាមទារថា បើគ្មានឯកសារដើមយកមកបង្ហាញកូនក្តីរបស់លោក ឬដូចលោកនួន ជាទាមទារទេនោះ គាត់នៅ

រក្សាជំហរច្រានចោលដដែល។

ក្នុងនេះលោកបានលើកឡើងអំពីការផ្សព្វផ្សាយ ឬការបោះពុម្ពផ្សាយជាឯកសាររបស់រដ្ឋាភិបាល ហ្វុង ឬ ហ្រ្គុង។ ហើយជាចុងក្រោយលោកបានលើកឡើងអំពីថា ឯកសារដែលលោកមិនចាត់ទុកថាជាបានការនោះ ពីព្រោះមិនមានឯកសារដើម ហើយដែលគ្មានការចុះហត្ថលេខា ឬស្នាមមេដៃទៅទៀត។

ក្នុងបរិបទនេះ ខ្ញុំបាទសូមជម្រាបជូនអង្គសវនាការជ្រាបថា ក្នុងសម័យរបបកម្ពុជាប្រជាធិបតេយ្យ ឯកសារភាពច្រើនដែលតុលាការនេះបានទទួលតាមរយៈសហចៅក្រមស៊ើបអង្កេត គឺខ្ញុំបាទកម្រឃើញមានស្នាមមេដៃរបស់ជនជាប់ចោទ។ និយាយរួមមិនឃើញតែម្តង។

[១១:៤៨:៤៧]

ហើយបើសិនជាមានឈ្មោះ ក៏ប្រើពាក្យដូចជា ប៉ុល ពត ប្រើលេខាបក្ស, អនុលេខាបក្ស លោក នួន ជា ឬដាក់សមមិត្តលេខាបក្ស សមមិត្តអនុលេខាបក្សជាដើម។ អ៊ីចឹងជាសំណួររបស់ខ្ញុំ ឬក៏ជាចម្ងល់របស់ខ្ញុំបាទ គឺសួរថា តើអ្វីទៅដែលហៅថាភាពដើម ឬយថាភាព នៃឯកសារដើមនោះ? តើរាល់តុលាការទាំងអស់ ទាំងតុលាការជាតិ និងតុលាការអន្តរជាតិទាល់តែយកឯកសារដើមដែលមានទំហំរាប់ពាន់ រាប់ម៉ឺន រាប់សែនទំព័រយកមកបង្ហាញនាពេលសវនាការនេះ ទើបថាយកជាបានការឬ?

[១១:៤៩:៣៣]

មួយទៀតខ្ញុំបាទសង្កេតឃើញថា ការជំទាស់របស់លោកមេធាវីការពារក្តី លោកបដិសេធទូទៅភាគច្រើន លោកលើកឧទាហរណ៍មកវិញនូវឯកសារដែលមិនច្បាស់ ឬបង្ហាញលើស្លាយនោះមើលមិនច្បាស់។ អ៊ីចឹងខ្ញុំបាទចង់បានមកថា តើឯកសារប្រភេទណា ជាឯកសារលេខប៉ុន្មានដែលមិនស៊ីសង្វាក់គ្នា? ដូច្នេះនៅក្នុងប្រធានបទនៃការជំទាស់ទៅលើឯកសារឧបសម្ព័ន្ធទី៥ នេះ ខ្ញុំបាទនៅតែយល់ឃើញថា បើយើងនិយាយអំពីឯកសារដើម ទោះបីជារូបថតក៏ដោយ ទោះបីជាសំណេរលើក្រដាសក៏ដោយ ទោះបីជាថតជារូបភាព១ ភាពយន្តវីដេអូក៏ដោយ តើនោះជាការពិត ឬក៏ឯកសារដើមដែរទេ? គឺវាចម្លងទាំងអស់។ អ៊ីចឹងឯកសារចម្លងដែលដាក់ចូលមកក្នុងតុលាការនេះ តាមរយៈភាគីទាំងឡាយ មានភាគីសហព្រះរាជអាជ្ញា ភាគីមេធាវីការពារជនជាប់ចោទ និងភាគីដើមបណ្តឹងរដ្ឋប្បវេណី។

សួរថាតុលាការដែលទទួលយកនោះ ចាត់ទុកជាផ្លូវការទាំងអស់ទេ? អ៊ីចឹង វាត្រូវការមានការសំអាងបន្ថែមទៀត បើសិនជាឯកសារនោះ ខាងមេធាវីការពារក្តីយល់ថាជាឯកសារ វាមិនផ្លូវការ ឬដែលលោកមេធាវីការពារក្តីរបស់លោក នួន ជា មានប្រសាសន៍ថាក្រែងលោកជាឯកសាររបស់បច្ចាមិត្ត។

អ៊ីចឹងពាក្យក្រែង ឬប្រហែលក៏ស្ថិតនៅក្នុងពាក្យសង្ស័យខ្លួនឯងនៅឡើយទេ។

[១១:៥១:១០]

មួយទៀត ខ្ញុំបានស្ដាប់ឮមេធាវី ម៉ៃខល កាណាវាស ដែលជាមេធាវីការពារក្ដីរបស់លោក អៀង សារី លោកក៏បានថ្លែងថា ការយកឯកសារទាំងអស់មកបង្ហាញ គឺមានបំណងឲ្យខាងអង្គជំនុំជម្រះជឿ ដើម្បីដាក់បន្ទុកទៅលើជនជាប់ចោទ ដែលស្ថិតនៅក្នុងការចោទប្រកាន់នេះ។

អ៊ីចឹងក្នុងជំហាររបស់លោកក៏នៅតែទាមទារថា ដើម្បីឲ្យមានភាពជឿជាក់ ថាមានទម្ងន់ទាក់ទង ទៅនឹងដីការបញ្ជូនរឿងទៅជំនុំជម្រះ គឺលោកនៅរក្សាការជំទាស់ដដែល។

អ៊ីចឹងសរុបសេចក្ដីមក លោកមេធាវីការពារក្ដីឲ្យលោក ខៀវ សំផន ក៏លោកបានលើកឡើងដែរ ថា ឯកសារដូចមាននៅក្នុងប្រធានបទទាក់ទងនឹងឯកសារ A5 នេះ ជាងបីរយឯកសារនេះ ក៏លោកនៅ តែរក្សាជំហារបដិសេធអំពីយថាភាពនៃឯកសារដដែល ដោយលោកទាមទារយកឯកសារដើម ដូចមេធាវី ការពារក្ដីមុនៗដដែល។

[១១:៥២:០៧]

អ៊ីចឹងតទៅនេះ ខ្ញុំបាទសូមជម្រាបថា អ្វីដែលខ្ញុំបាទចង់លើកឡើងគឺទាក់ទងជាមួយនឹងឯកសារ ដែលបោះពុម្ពផ្សាយ ឬឯកសារដែលបង្កើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនេះ វាមានច្រើន ណាស់ មិនថាតែរបបកម្ពុជាប្រជាធិបតេយ្យមួយទេ របបដឹកនាំប្រទេសណាក៏មានឯកសារជាលាយ លក្ខណ៍អក្សរ ឯកសាររក្សាទុកជារូបភាព ជាវីដេអូ ជារូបថត និងការចម្លងទុកដោយប្រទេសនានាលើ ពិភពលោក ដែលគេចាប់អារម្មណ៍អំពីទង្វើ ឬការផ្សព្វផ្សាយរបស់ប្រទេសនីមួយៗនោះ។

អ៊ីចឹង ដូចលោកសហព្រះរាជអាជ្ញាបានលើកឡើងអម្បាញ់មិញអ៊ីចឹង។ ការផ្សព្វផ្សាយតាមប៉ុស្តិ៍ វិទ្យុជាតិរបស់ជាតិរបបកម្ពុជាប្រជាធិបតេយ្យមិនមានតែនៅក្នុងប្រទេសនៃទ្វីបអាស៊ីនោះទេ។ អ៊ីចឹងដូច លោកបានលើកឡើងថា សារព័ត៌មាន ប៊ី.ប៊ី.ស៊ី សារព័ត៌មាននៅសហរដ្ឋអាមេរិក ឬនៅប្រទេសអូស្ត្រាលី ឬនៅប្រទេសណាផ្សេងៗទៀតដែលគេកត់ត្រាទុក ឬក៏គេបានថតចម្លងទុកនោះ ក៏ចាត់ទុកជាឯកសារ ភស្តុតាងមួយសម្រាប់ឲ្យតុលាការពិនិត្យ និងពិចារណានៅពេលលោកចេញសាលក្រម ឬសាលដីកាចុង ក្រោយដែរ។ ថាតើភាពស៊ីសង្វាក់គ្នានៃការផ្សព្វផ្សាយនោះ ជាមួយនឹងការចម្លងឯកសារយកមកដាក់ ចូលនោះវាស៊ីសង្វាក់គ្នាដែរឬទេ?

[១១:៥៣:៣១]

ខ្ញុំបាទសូមជម្រាបទៅអង្គជំនុំជម្រះបន្តទៀតថា នៅក្នុងឯកសារដែលបោះពុម្ពផ្សាយ នៅក្នុងរបប កម្ពុជាប្រជាធិបតេយ្យ បានផ្សព្វផ្សាយផ្សេង និងអនុវត្តផ្សេង។ អ៊ីចឹងត្រង់ចំណុចនេះហើយ ដែលនាំ ឲ្យខាងជនជាប់ចោទមានការព្រួយបារម្ភ។ ព្រោះថាលោកទាមទារឲ្យសហព្រះរាជអាជ្ញាបង្ហាញភាព ជាក់លាក់ ឬភាពយថាភាពនៃឯកសារឲ្យច្បាស់លាស់ ឲ្យលើសពីវិមតិសង្ស័យ។ ខ្ញុំបាទសួរថា មាន ចម្ងល់ថា តើពាក្យថា “វិមតិសង្ស័យ ឬលើសពីវិមតិសង្ស័យ” នោះ វាមានកម្រិតប៉ុនណា?

ដូច្នេះ រាល់ឯកសារដែលកូពី ឬថតចម្លងចូលក្នុងប្រព័ន្ធអេឡិចត្រូនិច នៃអង្គសវនាការអង្គជំនុំ ជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះ លោកប្រធានបានជម្រាប និងបានប្រកាសជាផ្លូវការរួចហើយ ដូចលោក នួន ជា បានទាមទារនៅក្នុងសប្តាហ៍មុន រាល់ពេលគឺលោកទាមទារឲ្យបង្ហាញពីឯកសារដើម សិន ហើយពេលខ្លះ គាត់បដិសេធថា ការសម្ភាសរបស់គាត់ ខ្ញុំលើកឧទាហរណ៍ដែលតែងតែនិយាយ មកហើយជាមួយនឹងលោក ខឹម ងុន ដែលគាត់តែងតែបដិសេធទាំងការហៅឈ្មោះមិនច្បាស់លាស់ទៅ ទៀតនោះ។

គាត់មិនមែនបដិសេធទាំងស្រុងទេ ក៏ប៉ុន្តែ គាត់គ្រាន់តែនិយាយថាជាការនិយាយលេង ឬនិយាយ មិនទាន់យកជាការពិត។ ហើយគាត់រហូតដល់ចោទថា ខឹម ងុន ជាភ្នាក់ងាររបស់សម្តេចនាយក ហ៊ុន សែន ទៅទៀត។ អ៊ីចឹងទាំងអស់នេះ តើអ្នកណាអ្នកវាយតម្លៃថា អ្វីជាការនិយាយ អ្វីជាការកត់ត្រាទុក គឺជាការបានការ ឬជាឯកសារយថាភាពនោះ?

[១១:៥៥:១៥]

ខ្ញុំបាទ សូមជម្រាបជូនអង្គសវនាការជ្រាបថា ភាពអាចទទួលយកបាន ឬយថាភាពនៃឯកសារ ឧបសម្ព័ន្ធ៥ ឬក៏ឯកសារ E9/31.5 នៅក្នុងសំណុំរឿងនេះ បើសិនជាមេធាវីការពារក្តីទាំងអស់ លោក ទាមទារយកឯកសារដើមទាំងអស់ មិនមែនទាក់ទងតែឯកសារ A5 នេះមួយទេ។ គឺឯកសារដែលលោក ប្រធានតែងតែមានប្រសាសន៍ថា មានប្រហែលជាជាងមួយលានទំព័រឯណោះនោះ។ ដូច្នេះ តើពេល វេលា ឬដំណើរការសវនាការនេះតទៅមុខទៀតនោះ ត្រូវប្រើពេលប៉ុន្មានឆ្នាំទៀត។ អ៊ីចឹង ខ្ញុំបាទក៏បាន ច្បាស់លាស់ផងដែរថា តើឯកសារឈ្មោះ ឬឯកសារលេខប៉ុន្មានដែលមេធាវីការពារក្តីលោកជំទាស់ថា មិនអាចយកជាការបាន?

ដូច្នេះ មកដល់នៅពេលនេះ ខ្ញុំបាទនៅតែមិនទាន់ទទួលបានជាក់លាក់នៅឡើយថា ការជំទាស់ ទៅលើឯកសារ A1 រហូត A5 ដែលខាងសហព្រះរាជអាជ្ញាបានដាក់ជូននោះ មិនទាន់មានការពិតចំនួន

ប៉ុន្មានពិតប្រាកដនោះទេ ដើម្បីឲ្យយើងខ្ញុំទាំងអស់គ្នាក៏បានសិក្សា និងធ្វើការវិភាគជូនជាយោបល់ ឬធ្វើសេចក្ដីថ្លែងការណ៍ជូនទៅអង្គសវនាការផងដែរ។

[១១:៥៦:២៦]

ក្នុងនេះ ខ្ញុំបាទសូមជម្រាបជូនផងដែរថា ដោយសារមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីមុនក៏លោកលើកឡើង ហើយលោកសហព្រះរាជអាជ្ញាក៏បានលើកឡើងច្រើនហើយដែរ ទាក់ទងជាមួយនឹងយថាភាពនៃឯកសារនេះ។ ខ្ញុំបាទនៅតែសូមជម្រាបជូនលោកប្រធាន និងអង្គសវនាការជ្រាបថា បើនិយាយពីការវាយតម្លៃទៅលើភស្តុតាង វិធាននៃភស្តុតាង ក្នុងមាត្រា៣២១ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជណាចក្រកម្ពុជា ហើយដែលស្មើគ្នាជាមួយនឹងវិធាន៨៧ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក នេះ បានចែងថា មាត្រា៣២១ ស្ដីពីការវាយតម្លៃលើភស្តុតាងដោយតុលាការបានចែងថា "លើកលែងបទប្បញ្ញត្តិផ្ទុយពីនេះ ភស្តុតាងក្នុងរឿងព្រហ្មទណ្ឌអាចជូនបានដោយសេរី តុលាការថ្លឹងថ្លែងដោយឥស្សរចិត្ត អំពីតម្លៃភស្តុតាងដែលគេដាក់ជូនមកខ្លួនពិនិត្យ ដោយផ្អែកលើជំនឿស្មោះត្រង់ពិតប្រាកដរបស់ខ្លួន" តុលាការសំអាងនៅក្នុងសេចក្ដីសម្រេចរបស់ខ្លួនតែទៅលើភស្តុតាងដែលមាននៅក្នុងសំណុំរឿង ឬដែលត្រូវគេយកមកបង្ហាញនៅពេលសវនាការប៉ុណ្ណោះ។

[១១:៥៧:៣២]

អ៊ីចឹងមាត្រា៣៣២ ស្ដីពីការបង្ហាញវត្ថុតាង ប្រធានសវនាការអាចបង្គាប់ឲ្យជនណាម្នាក់បង្ហាញវត្ថុតាងបាន។ អ៊ីចឹងខ្ញុំបាទបានស្ដាប់ឮមកប៉ុន្មានសប្ដាហ៍នេះ គឺខាងលោកមេធាវីការពារក្ដីលោកទាមទារឲ្យប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជា ឬហៅកាត់ថា ឌី.ស៊ី.ខេម មកឆ្លើយបំភ្លឺ។ ហើយខ្ញុំបាទក៏បានស្ដាប់បានថា លោកប្រធាននឹងកោះហៅអ្នកតំណាងមកធ្វើសក្ខីកម្មនៅសប្ដាហ៍ក្រោយ។ អ៊ីចឹងទាំងអស់នោះ ខ្ញុំបាទនៅតែយល់ឃើញថា ការលើកឡើងរបស់លោកមេធាវីការពារក្ដីទាំងអស់ទាមទារតែម្នាក់គឺខ្ញុំជឿជាក់ថាមិនមែនតែមួយទេ ហើយបើលោកនៅតែជឿជាក់ថា រាល់ឯកសារ ឬក៏សាក្សីឲ្យតែទាក់ទិនដូចជាការបោះពុម្ពផ្សាយរបស់រដ្ឋាភិបាល ហ្វុង ឬហ្រ្គុង នោះ អ៊ីចឹងតើមានសាក្សី ឬមនុស្សប៉ុន្មាននាក់ទៀតដែលត្រូវមកបំភ្លឺរាល់ឯកសារនោះ។ អ៊ីចឹងខ្ញុំបាទសង្ឃឹមថា លោកប្រធានដែលបានជម្រាបជូនពីថ្ងៃមុនៗថា នៅថ្ងៃចន្ទ ខាងមុខនេះនឹងមានការបំភ្លឺ មិនអាចនឹងបំភ្លឺរាល់ឯកសារនោះទេ។ ហើយអ្វីដែលខ្ញុំបាទចង់លើកឡើងពេលនេះ គឺខ្ញុំបាទនៅតែរក្សាគោលជំហរដដែលថា ឯកសារទាំងឡាយដែលដាក់ជូនទៅក្នុងសំណុំរឿងរួចមកហើយនេះ មិនមែនមានន័យថា សុទ្ធតែឯកសារបានការទាំងអស់នោះទេ។

ហើយក៏មិនមែនមានន័យថា ឯកសារដែលបានដាក់ជូនហើយនេះ សុទ្ធតែឯកសារមិនបានការនោះដែរ។

[១១:៥៩:០៣]

ដូច្នេះ ខ្ញុំបាទសូមការកត់សម្គាល់ខ្លីៗនេះដោយជំហររបស់ខ្ញុំបាទនៅគាំទ្រការលើកឡើង និងការដាក់ជូនរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងឯកសារ A5 នេះនៅដដែល។ ហើយសូមឲ្យលោកប្រធាន និងអង្គសវនាការទទួលយកទៅពិចារណា យកជាបានការមុននឹងចេញសាលក្រមនៅចុងក្រោយ។

ហើយបន្តទៅនេះ សូមអញ្ជើញលោកស្រី អេលីហ្សាបេត បន្ត។ សូមអរគុណ។

[១១:៥៩:២៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រមជាទៅគោរព!

បើយើងនិយាយអំពីឧបសម្ព័ន្ធ៥ ហើយលោកសហព្រះរាជអាជ្ញាបានពន្យល់អម្បាញ់មិញនេះថា ឯកសារនៅក្នុងឧបសម្ព័ន្ធទី៥ នោះទាក់ទងទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យរបប ហ្រ្គុង ឬហ្គុង ឬក៏ជាឯកសារដែលជាថាជាសេចក្ដីថ្លែងការណ៍ជាសាធារណៈ ដែលបញ្ជាក់អំពីព្រឹត្តិការណ៍ដែលកើតមាននៅសម័យនោះ។ អម្បាញ់មិញនេះ ភាគីការពារក្ដីរបស់លោក អៀង សារី ដែលបានលើកការជំទាស់លើឧបសម្ព័ន្ធទី៥នេះ ថាពាក់ព័ន្ធទៅនឹងឯកសារសារព័ត៌មាន ឧទាហរណ៍ដូចជាឯកសាររបស់ម៉ាដាម អេលីហ្សាប៊ែត បេកយ័រ។ ខ្ញុំគិតថាការជំទាស់នេះ វាមានលក្ខណៈទូលំទូលាយណាស់ ហើយដូចដែលថាការជំទាស់ពីបួនថ្ងៃមកហើយអ៊ីចឹងដូចគ្នា។ ដូច្នេះ ឯកសារនៅក្នុងឧបសម្ព័ន្ធទី៥នេះ មិនអាចៗវិភាគឡើងដោយថាជាការជំទាស់ដូចឯកសារសារព័ត៌មានខាងក្រៅផ្សេងទៀត ឬក៏ថាសរសេរបីបួនខែ ឬក៏បីបួនឆ្នាំក្រោយមកនោះទេ ក្រោយរបបខ្មែរក្រហមនោះ។ ហើយអង្គជំនុំជម្រះបានរំឭកជាច្រើនដងមកហើយ ថាមិនជាការសមស្របទេក្នុងការធ្វើទំនាស់ដដែលៗនោះ។

[១២:០១:០៧]

ដោយស្មោះត្រង់ ខ្ញុំគិតថាភាគីការពារក្ដី ប្រហែលជាថារំលោភលើលទ្ធភាពដែលថាខ្លួនឯងហ្នឹងចេះតែមករករឿងហ្នឹងមកនិយាយដដែលៗ។ ខ្ញុំគិតថា ដោយយើងពិនិត្យទៅលើឧបសម្ព័ន្ធទី៥នេះ ខ្ញុំគិតថាវាជាលើកទីប្រាំមួយហើយ ដែលច្បាស់លាស់តែម្ដងថាប្រាំមួយដងហើយ ដែលយើងឮការជំទាស់

ដែលថាលក្ខណៈទូទៅ។ ខ្ញុំរំឭកថា ដូចថាខាងព្រះរាជអាជ្ញាក៏បានលើកឡើង សហភាតាខ្ញុំក៏បានលើកឡើងដែរ។ អ៊ីចឹងដោយយើងជ្រើសរើសរបៀបជំទាស់បែបនេះ ដែលថាដែលចចេស ឬក៏ថាដែលងងឹតងងុលនោះ ខ្ញុំគិតថាភាគីការពារក្ដីអាច គឺថាប្រឈមមុខនឹងវិធានផ្ទៃក្នុង ឬក៏ថាវិធានមួយចំនួន។ ឧទាហរណ៍គឺទៅនឹងឯកសារ E3 គឺថាជាន់ឈ្លីទៅដល់ក្រមព្រហ្មទណ្ឌកម្ពុជាផងដែរ ហើយគឺថាហាក់ដូចជាធ្វើអ៊ីចឹង ដូចសប្បាយនៅក្នុងចិត្តអ៊ីចឹងឯង។ ហើយរំលោភ ជាន់ឈ្លីទៅនឹងយុត្តិសាស្ត្រអន្តរជាតិ ហើយដែលថាព្យាយាមលើកឡើងនូវវគ្គមួយចំនួនដែលថាវាជួយដល់ខ្លួន ហើយជាន់ឈ្លីទៅដល់យុត្តិ-សាស្ត្រអន្តរជាតិ ដោយលើកឡើងថាភាគីការពារក្ដីមិន ដែលចែងថាភាគីការពារក្ដីនោះមិនមានសិទ្ធិអ៊ីដាច់ខាតនោះទេ។ ហើយក្នុងការទទួលបាននូវឯកសារដើម ឬក៏ឯកសារចម្លងដាច់ខាតនោះ។ អ៊ីចឹង គឺថាជាន់ឈ្លីទៅដល់យុត្តិសាស្ត្រទាំងអស់នេះទាក់ទងនឹងឧបសម្ព័ន្ធទី១ ហ្នឹង។

[១២:០៣:០៦]

អ៊ីចឹងរំលោភទៅដល់ឆន្ទានុសិទ្ធិអង្គជំនុំជម្រះផងដែរ។ ដូច្នេះកាលណាយើងជាៗចៅក្រមនោះ អ៊ីចឹងយើងមានកាតព្វកិច្ចក្នុងគិតទៅដល់ចៅក្រមស៊ើបអង្កេតផងដែរ។ ភាគីការពារក្ដីហ្នឹង ក៏ជាន់ឈ្លីទៅដល់សិទ្ធិរបស់សហព្រះរាជអាជ្ញា ហើយជាដដែលៗ ដែលបង្ហាញពីជម្រើសនៃការបញ្ជូលឯកសារនៅក្នុងសំណុំរឿងនោះវារាប់ខែរាប់ឆ្នាំមកហើយ ហើយដោយខ្លួនបានអនុវត្តដល់លក្ខខណ្ឌទទួលបាននៃឯកសារតាមយុត្តិសាស្ត្រអន្តរជាតិជាដើម។

**ប្រធានអង្គជំនុំ៖**

មានការអីទៀតលោកមេធាវី?

[១២:០៤:០០]

**លោក សុន អរុណ៖**

ខ្ញុំសុំជំទាស់នូវពាក្យសម្ដីរបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ប្រើពាក្យថា "មេធាវីការពារងងឹតងងុល" ព្រមទាំង "ជាន់ឈ្លី"។ មិនមានជាន់ឈ្លីអីទៅលើព្រះរាជអាជ្ញា ឬក៏ទៅលើដើមបណ្ដឹងរដ្ឋប្បវេណីមិនមានទេ។ ទាំងអស់នេះ ជាយុត្តិសាស្ត្រការពាររបស់បក្ស របស់ក្រុមម្ខាងៗទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញបន្តទៀតណា! ហើយបញ្ហាទំនងជាការប្រើពាក្យក្នុងការបកប្រែ ព្រោះការសួរទៅជាភាសាដទៃទៀតហ្នឹង ដូចជាមិនមានទម្ងន់នៃពាក្យអ៊ីចឹងទេ។ បញ្ហាងងឹតងងុល អានេះជាបញ្ហាធ្ងន់

មែន ប្រសិនបើជាប្រើពាក្យនេះជាភាសាខ្មែរ ប៉ុន្តែសួរខាងភាសាផ្សេងទៀតហ្នឹង យើងដូចជាមិនមានទម្ងន់ធ្ងន់ដូចការប្រើពាក្យខ្មែរទេ។ អ៊ីចឹងអាចមកពីការបកប្រែ។ ប៉ុន្តែទោះបីជាយ៉ាងណា គឺសុំមេធាវីប្រយ័ត្នប្រយែងក្នុងការប្រើពាក្យ ធ្វើម៉េចឲ្យបានសមរម្យ ចៀសវាងប៉ះពាល់ក្នុងការប្រើពាក្យប្រមាថ ឬក៏ប៉ះ ពាល់ទៅលើភាគីម្ខាងទៀត នេះអង្គជំនុំជម្រះរំឭកច្រើនដងហើយ។ សូមបន្ត។

[១២:០៥:២៥]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធានខ្ញុំមិនបានប្រើពាក្យអស់សង្ឃឹមនោះទេ។ អ៊ីចឹងខ្ញុំមិនបានប្រើពាក្យដល់ថ្នាក់ហ្នឹងទេ ខ្ញុំគិតថាប្រហែលជាមានបញ្ហាបកប្រែ។ ខ្ញុំបានប្រើពាក្យ "ចចេស ងងើល" ហើយខ្ញុំបាននិយាយពាក្យនុំងមែន ខ្ញុំមិនបានប្រើពាក្យមើលងាយមើលថោកនោះទេ។

ឥឡូវខ្ញុំបន្តការកត់សម្គាល់ខ្ញុំទៀត។ ដោយជ្រើសរើសយកគោលជំហរជំទាស់ដោយចចេស អ៊ីចឹងភាគីការពារក្តី គឺថាជាន់ឈ្លីទៅលើ-- គឺថាបួនថ្ងៃមកហើយទៅលើការបរិយាយរបស់ភាគី របស់សហព្រះរាជអាជ្ញាទៅលើឧបសម្ព័ន្ធទាំងអស់នេះ ហើយគឺថាមិនឲ្យតម្លៃទៅលើកំណត់ហេតុរបស់សហចៅក្រមស៊ើបអង្កេត ហើយដោយពិនិត្យលើសក្ខីកម្មទាំងអស់នេះឡើងវិញទាំងអស់ ហាក់ដូចជាថា កំណត់ហេតុរបស់សហចៅក្រមស៊ើបអង្កេតពុំមានអ៊ីចឹង គឺថាហាក់ដូចជាពុំមានតម្លៃ ឬក៏ភស្តុតាងទាំងអស់នេះគ្មានតម្លៃ ហាក់ដូចជាភស្តុតាងទាំងអស់នេះមិនត្រូវបានកំណត់ថាមានតម្លៃដោយដីកា១ដំណោះស្រាយអ៊ីចឹង។

[១២:០៦:៥១]

ឧទាហរណ៍ដូចជាពាក្យសម្តីរបស់ ឆាំង យុ នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៩ D504/3។ មិនមានការសុំឲ្យមានប្រឈមមុខគ្នាជជែកដេញដោលគ្នា ទាក់ទងទៅនឹងលោក ឆាំង យុ ហើយនិងភាគីផ្សេងទៀត។ មិនមានការសុំឲ្យមានការប្រឈមមុខគ្នាដោយដាក់លក្ខខណ្ឌទៅដល់ចៅក្រមស៊ើបអង្កេត អ៊ីចឹងភាគីការពារក្តីក៏បានធ្វើឲ្យយើងខាតពេលវេលាច្រើននៅក្នុងការលើកជំទាស់ទាំងអស់នេះ។

ខ្ញុំលើកឧទាហរណ៍តែមួយទេ ដើម្បីបង្ហាញថា បញ្ហាដែលបានលើកឡើងហ្នឹងដដែល១ ត្រូវបានពិភាក្សា ឬក៏ធ្វើការសម្រេចរួចហើយ។ អ៊ីចឹងបានន័យថា ប្រសិនជាភាគីការពារក្តីចង់លើកយកបញ្ហាដដែលនេះមកលើកឡើងទៀត ត្រូវបង្ហាញសំអាងហេតុផ្សេងទៀត។ ឧទាហរណ៍ សាលដីកាចុះថ្ងៃទី៣០ ឆ្នាំ២០១០ គឺ D លេខឯកសារដែលទាក់ទងទៅនឹងឯកសារដែលចេញមកពីមជ្ឈមណ្ឌលឯកសារកម្ពុជានៅក្នុងកថាខណ្ឌទី២៥ អង្គជំនុំជម្រះ-- អង្គបុរេជំនុំជម្រះបានបញ្ជាក់យ៉ាងដូច្នេះ។

នៅក្នុងដំណាក់កាលដំបូង សហចៅក្រមស៊ើបអង្កេតដែលមានសិទ្ធិអំណាចក្នុងការសម្រេចលើភាពគួរឲ្យជឿជាក់លើឯកសារ ហើយបន្ទាប់មកទៀត អង្គបុរេជំនុំជម្រះវិញកទៅដល់ភាគីការពារក្តីថា នៅក្នុងដំណាក់កាលស៊ើបអង្កេត ចៅក្រមស៊ើបអង្កេតត្រូវតែទទួលកាតព្វកិច្ច-- មិនមានកាតព្វកិច្ចក្នុងការផ្តល់សេចក្តីបញ្ជាក់ជាក់លាក់ ឬក៏បំភ្លឺណាមួយទាក់ទងទៅនឹងការប្រមូលឯកសារភស្តុតាង ធាតុផ្សំភស្តុតាងទោះបីថា-- សូម្បីប្រាប់ថាប្រភពមកពីណានោះក៏ដោយ។ អ្វីដែលខ្ញុំចង់និយាយនោះ គឺថាយើងមិនអាចធ្វើដូចខាងភាគីការពារក្តីទេ ដោយថាចោទជាបញ្ហានូវតែរឿងដដែលៗដោយមិនគិតអំពីចម្លើយដែលគេបានផ្តល់ជូនទៅហើយ ហើយមិនព្រមស្វែងរកដោះស្រាយឲ្យលើសពីនោះៗទេ។

[១២:០៩:៣៧]

អ៊ីចឹងដើម្បីបញ្ចប់ ខ្ញុំគិតថាការនិយាយដដែលៗ ការជំទាស់ដដែលៗលើឯកសារ E3 ទៅដល់ឧបសម្ព័ន្ធទី៥ នោះ គឺមានផលប្រយោជន៍ពីរ គឺថាភាគីខាងការពារក្តីនោះ គឺថាត្រូវបានបង្ខំឲ្យទៅដល់-- ដោយខ្លួនឯងនោះគឺថា បង្ខំខ្លួនឯងថាជំទាស់យកតែខាងបាន ដូចដែលខាងសហព្រះរាជអាជ្ញាបានលើកឡើងអម្បាញ់មិញដែរគឺថា ពាក្យមេធាវី ខៀវ សំផន កាលពីព្រឹកមិញហ្នឹងបាននិយាយថា ហេតុអីក៏មិនគិតថា ឯកសារទាំងអស់សុទ្ធតែជា អាចថានឹងជាឯកសារក្លែងក្លាយ? នេះគឺថា ដូចគ្មានគួរឲ្យអស់សំណើចណាស់ ហើយផលប្រយោជន៍របស់ពួកគាត់មួយទៀតនោះ ខាងភាគីក្តីដែលថា និយាយដដែលៗនោះគឺថា តាមរយៈការនិយាយដដែលនេះ គឺថាខាងការពារក្តីជឿជាក់ថា យើងនឹងមិនពិភាក្សាពីភាពទទួលយកបាននៃឯកសារ ហើយនិងយើងអាចច្រឡំទៅនិយាយអំពីតម្លៃភស្តុតាង។ អ៊ីចឹងគឺថា បន្តិចម្តងៗគឺថា ភាគីការពារក្តីសុំឲ្យអង្គជំនុំជម្រះ គិតអំពីតម្លៃភស្តុតាងជាដើម។

[១២:១១:០៣]

ព្រឹកមិញហ្នឹងខាងមេធាវីការពារក្តីរបស់លោក អៀង សារី និយាយច្បាស់ហើយ គាត់បានលើកឡើងអំពីខាងព្រះរាជអាជ្ញា គឺថាត្រូវឲ្យខាងព្រះរាជអាជ្ញា បង្ហាញពីតម្លៃភស្តុតាង។ អ៊ីចឹងបានន័យថា យើងលែងនិយាយអំពីភាពទទួលយកបានហើយ។ ហើយមេធាវីរបស់លោក អៀង សារី ក៏បានលើកឡើងផងដែរថា អង្គជំនុំជម្រះត្រូវតែធ្វើការវាយតម្លៃថា ក្នុងពេលជាមួយគ្នាតែម្តងគឺថា ភាពទទួលយកបានហើយនិងតម្លៃ ភស្តុតាង ហាក់ដូចជារឿងទាំងអស់នេះដូចគ្នាអ៊ីចឹង។ អ៊ីចឹងខ្ញុំគិតថា អ៊ីចឹងវាការពិភាក្សាលើភាពទទួលយកបានហ្នឹង វាដល់ពេលចប់ហើយឥឡូវនេះ។ អ៊ីចឹង យើងត្រូវឈានចូលទៅនិយាយអំពីប្រធានបទអីផ្សេងទៀតទៅ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ឥឡូវនេះដល់ពេលត្រូវសម្រាកពិសាអាហារថ្ងៃត្រង់ហើយ។ ប៉ុន្តែ មុនសម្រាកអង្គជម្រះសូមចង់បានព័ត៌មានពីភាគី អំពីការប៉ាន់ស្មានពេលវេលារបស់ខ្លួនក្នុងការសួរចម្លើយជនជាប់ចោទ នួន ជា ដោយសម្រាប់អង្គហេតុវគ្គទីមួយ គឺស្តីពីប្រវត្តិកម្ពុជាប្រជាធិបតេយ្យ ហើយនៅក្នុងកិច្ចដំណើរការសវនាការចុងក្រោយគឺ ខាងសហព្រះរាជអាជ្ញាបានបង្ហាញជំហររួចហើយ ហើយថាខ្លួននៅមានពេលត្រូវការពេលវេលាមួយពេល កន្លះថ្ងៃទៀត។ នេះជាការកត់សម្គាល់របស់អង្គជម្រះ ប៉ុន្តែអង្គជម្រះក៏ចង់ដឹងអំពីព័ត៌មាននៅក្នុងការប្រមើលមើលប៉ាន់ស្មានពេលវេលា សម្រាប់សួរដេញដោលចំពោះជនជាប់ចោទ នួន ជា អំពីអង្គហេតុវគ្គមួយ ប្រវត្តិបក្សកុម្មុយនីស្តកម្ពុជាហ្នឹងដែរ ដើម្បីឱ្យអង្គជម្រះមានលទ្ធភាពនៅក្នុងការយកមកគិតគូរពិចារណា កំណត់អំពីកាលវិភាគសម្រាប់ធ្វើសវនាការ ឱ្យប្រព្រឹត្តទៅបានឆាប់រហ័ស និងមានប្រសិទ្ធភាព។ ប៉ុន្តែ អង្គជំនុំជម្រះមិនទាន់ចង់បាននាពេលនេះទេ អាចថាពេលមុនពេលចប់នៅរសៀលនេះ យើងនឹងសង្ឃឹមថា នឹងទទួលបានព័ត៌មានអំពីការប៉ាន់ស្មានពេលវេលារបស់ភាគី។

[១២:១៣:៣៣]

ឥឡូវនេះ ដល់ពេលវេលាសមល្មមនឹងសម្រាកពិសាអាហារថ្ងៃត្រង់ហើយ អង្គជម្រះ--

អញ្ជើញ!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំគិតថា បកប្រែអង់គ្លេសហាក់ដូចជា មានការបកខុស ចំពោះថា នៅសល់កន្លះថ្ងៃនេះ គឺសំដៅទៅខាងសហព្រះរាជអាជ្ញា ដែលគាត់ចង់មានរយៈពេលកន្លះថ្ងៃ ក្នុងការសួរទៅកាន់ជនជាប់ចោទនេះគឺជាកន្លះម៉ោងសម្រាប់សហព្រះរាជអាជ្ញា។ ខ្ញុំគ្រាន់តែសូមបញ្ជាក់ឱ្យបានច្បាស់។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ឥឡូវនេះសម្រាកពិសាអាហារថ្ងៃត្រង់។

អនុរក្សមន្ទីរឃុំឃាំងនាំលោក ខៀវ សំផន ទៅកាន់បន្ទប់សម្រាកនៅខាងក្រោម ហើយនិងបង្គាប់ឱ្យនាំខ្លួនគាត់ត្រឡប់មកកាន់បន្ទប់សវនាការវិញ នៅរសៀលនេះឱ្យបានមុនម៉ោងមួយនឹងសាមសិបនាទី។

*(សវនាការសម្រាកពីម៉ោង ១២:១៥ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣១:៣៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការ ហើយពេលវេលាសវនាការនៅថ្ងៃនេះ នៅរសៀលនេះគឺ មេធាវីការពារក្តីទាំងបីក្រុមមានរយៈពេលមួយម៉ោង ដើម្បីឆ្លើយតបទៅនឹងការជំទាស់នានា ពាក់ព័ន្ធទៅនឹងឯកសារនៅក្នុងឧបសម្ព័ន្ធ A1 ដល់ A5។ ប៉ុន្តែ ដោយកាលពីព្រឹកមិញ មុននឹងសម្រាកពិសាអាហារថ្ងៃត្រង់ អង្គជំនុំជម្រះបានសួរទៅភាគី មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីការពារក្តីទាំងបីក្រុម អំពីការប្រមើលមើលប៉ាន់ស្មាននូវពេលវេលា សម្រាប់សួរសំណួរចំពោះជនជាប់ចោទ នួន ជា ទៅលើអង្គហេតុវគ្គមួយ បរិបទប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា។

[១៣:៣៣:០៨]

ឥឡូវនេះ អង្គជំនុំជម្រះសួរទៅមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីថា តើខាងមេធាវីហ្នឹងត្រូវការពេលវេលាប៉ុន្មានដែរ?

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន ខាងមេធាវីនាំមុខត្រូវការរយៈពេលសរុបចំនួន ៤ម៉ោង។

**ប្រធានអង្គជំនុំ៖**

ចុះលោកខាងមេធាវី នួន ជា តើត្រូវការពេលវេលាប្រហែលប៉ុន្មានដែរ?

**លោក ម៉ៃខល ផេសមិន៖**

លោក លោកស្រីចៅក្រមជាទីគោរព! ខ្ញុំគិតថា យើងមិន-- ប្រហែលជាមិនត្រូវការលើសពីមួយថ្ងៃទេ។ ប្រហែលជាមួយថ្ងៃហ្នឹងច្រើនបំផុត ឬក៏តិចជាងមួយថ្ងៃ។ ប្រសិនបើខ្ញុំយល់មិនខុសនោះទេ គឺយើងខ្ញុំនេះត្រូវបានអនុញ្ញាតឲ្យសួរទៅកាន់កូនក្តីរបស់ខ្ញុំ ចុងក្រោយគេបន្ទាប់ពីមេធាវីដទៃទៀត។ ដូច្នេះហើយប្រសិនជាបើអត់អីចឹងទេ គឺខ្ញុំសូមសួរចុងក្រោយគេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ ចុះមេធាវីការពារលោក អៀង សារី?

**លោក ម៉ៃខល កាណាវាស៖**

សូមគោរពលោក លោកស្រីចៅក្រម។ នៅពេលនេះ គឺយើងមិនទាន់ដឹងថាតើយើងនឹងសួរ

សំណួរបែបណាទៅកាន់លោក នួន ជា នៅឡើយទេ ក៏ប៉ុន្តែប្រសិនបើយើងសម្រេចថា យើងនឹងសួរសំណួរទៅកាន់លោក នួន ជា នោះ ខ្ញុំគិតទស្សន៍ទាយថាយើងប្រហែលជាត្រូវការ៤៥នាទី ទៅមួយម៉ោងតែប៉ុណ្ណោះ។ ប៉ុន្តែនៅពេលនេះយើងមិនទាន់ធ្វើសេចក្តីសម្រេចចិត្តថា តើគួរសួរ ឬមិនសួរលោក នួន ជា នៅឡើយទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។

អ៊ីចឹងមេធាវីការពារក្តីលោក ខៀវ សំផន យ៉ាងម៉េចដែរ?

[១៣:៣៥:២៧]

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ ដោយសារយើងមិនទាន់ដឹងអំពីស្ថានភាពឲ្យអស់ ដោយសារយើងត្រូវ-- ខាងក្រុមយើងត្រូវសួរក្រោយដែរនោះ។ អ៊ីចឹងរយៈពេលនេះ ក៏មិនអាចកំណត់ឲ្យបានច្បាស់លាស់ដែរ ប៉ុន្តែខ្ញុំអាចលើកស្មានៗថា ប្រហែលពីដប់ប្រាំនាទីទៅមួយម៉ោង ឬក៏អាចមិនមានសំណួរក្នុងករណីដែលមិនជាប់ពាក់ព័ន្ធអ្វីនឹងករណីរបស់ខាងមេធាវីការពាររបស់យើងនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញ!

[១៣:៣៦:១១]

**លោក ម៉ៃខល ផេសមិន៖**

ប្រហែលជាចម្លើយរបស់ខ្ញុំហ្នឹង គឺថាប្រហែលជាអាចមានការយល់ច្រឡំ ខ្ញុំនិយាយថា មួយថ្ងៃអំមិញហ្នឹង គឺទាំងព្រឹកទាំងល្ងាច មិនមែនថាកន្លះថ្ងៃនោះទេ។ សូមបញ្ជាក់ឲ្យបានច្បាស់លាស់។

សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ឥឡូវនេះអង្គជំនុំជម្រះសូមផ្តល់វេទិកាទៅមេធាវីការពារក្តីលោក នួន ជា ដើម្បីធ្វើការឆ្លើយតបជាសរុបទៅនឹងការជំទាស់ ឬអំណះអំណាងនានាដែលពាក់ព័ន្ធទៅនឹងឯកសារនៅក្នុងឧបសម្ព័ន្ធ ចាប់ពីឧបសម្ព័ន្ធ A1ដល់ឧបសម្ព័ន្ធ A5។ ហើយមេធាវីមានរយៈពេល២០នាទី ក្នុងការធ្វើការអំណះអំណាងនេះ។

សូមអញ្ជើញ!

[១៣:៣៧:០៩]

**លោក អេនគ្រូ អ៊ីនូហ្សី៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រមជាទីគោរព គឺយើងមិនចំណាយពេលលើសពីប្រាំទៅ ឬលើសពីដប់នាទីនោះឡើយ។ ហើយប្រសិន-- ប្រហែលជាមេធាវី សុន អរុណ គាត់អាចមានការលើកឡើងបន្ថែម។

ខ្ញុំសូមលើកឡើងសាជាថ្មីនូវទឡ្ហីករណ៍ ដែលយើងខ្ញុំបានលើកឡើងក្នុងសប្តាហ៍នេះ។ ខ្ញុំលើកទឡ្ហីករណ៍ចំនួនបីឡើងវិញ គឺដូចដែលយើងខ្ញុំបានលើកឡើងរួចមកហើយ យើងចំណាយពេលហាក់ដូចជាច្រើនពេកពិភាក្សាគ្នាទៅលើទម្ងន់នៃភស្តុតាង និងតម្លៃនៃភស្តុតាង គឺយើងហាក់ដូចជាយើងមិនពិភាក្សាគ្នាឲ្យបានច្រើនទៅលើភាពអាចទទួលយកបាននៃឯកសារសោះ។

[១៣:៣៨:០៣]

នៅក្នុងការពិភាក្សាក្នុងអាទិត្យនេះ គឺយើងនឹងសម្រេចថា តើយើងដោះស្រាយ ចាត់ចែង និងវាយតម្លៃទៅលើភស្តុតាងដោយរបៀបណា នៅពេលដែលយើងទទួលយកភស្តុតាង ឯកសារទាំងអស់នោះ?

យើងខ្ញុំសូមសន្និដ្ឋានថា ដូចដែលយើងបានលើកឡើងកាលពីថ្ងៃចន្ទ គឺយើងត្រូវតែឲ្យគិតពិចារណាអំពីតុល្យភាព ផលប្រយោជន៍រវាងភាគីទាំងអស់នៅក្នុងរឿងក្តីនេះ។ នៅក្នុងច្បាប់កម្ពុជា គឺយើងត្រូវគោរពសិទ្ធិរបស់លោក នួន ជា ក្នុងការតវ៉ាទៅលើភស្តុតាងដែលបានដាក់ជូន។ ដូច្នេះវាជាចំណុចមួយដែលយើងគិតថា ជាការព្រួយបារម្ភដ៏សំខាន់។

[១៣:៣៨:៤៣]

ចំណុចទីពីរ ពាក់ព័ន្ធទៅនឹងទំហំ និងលក្ខណៈនៃឯកសារដែលបានដាក់ជូនមកទល់បច្ចុប្បន្នដោយខាងសហព្រះរាជអាជ្ញា។ យើងខ្ញុំសូមលើកឡើងសេចក្តីសន្និដ្ឋានរបស់លោក ផេសមិន ព្រឹកមិញនេះ។ យើងដឹងហើយថា មានឬ-- យើងដឹងថាមានឯកសារណាខ្លះ ដែលយើងមិនចាំបាច់យកមកដាក់បង្ហាញអំពីបញ្ហាកម្ពុជាប្រជាធិបតេយ្យ ដូចដែលសហព្រះរាជអាជ្ញាបានលើកឡើង។ គឺវាដូចម្តុលអ៊ីចឹងបានន័យថា ម្តុលនោះ គឺយើងមានច្រើន ហើយគាត់បានរៀបចំហើយក៏ដោយ។ ក៏ប៉ុន្តែយើងខ្ញុំសូមលើកឡើងថា នៅក្នុងរឿងក្តីនេះ បើសិនម្តុលវាច្រើនដូច្នេះ វាហាក់ដូចជាការគំរាមកំហែងមកដល់

យើង។ ឧទាហរណ៍ថា ការជម្លៀសប្រជាជន និងការផ្លាស់ទីលំនៅប្រជាជនពីទក្សិណទៅឧត្តរនោះ គឺនៅក្នុងចន្លោះ ៧៥-៧៦ គឺវាអាចពាក់ព័ន្ធ។

[១៣:៣៩:៤១]

នៅក្នុងរឿងក្តីនេះ ដែលថាយើងបំបែកសំណុំរឿង វាមានសំណុំរឿងតិច-- ឯកសារតិចតួចតែប៉ុណ្ណោះដែលពាក់ព័ន្ធនៅក្នុងផ្នែកនេះ។ ដូច្នេះខ្ញុំស្នើសុំឲ្យអង្គជំនុំជម្រះពិចារណាឲ្យបានល្អិតល្អន់ ឲ្យបានម៉ត់ចត់ចំពោះការគំរាមកំហែងបែបនេះមកដល់កូនក្តីរបស់យើងខ្ញុំ។ លោក នួន ជា បានលើកឡើងពិភាក្សាអំពីបញ្ហាជម្លៀសប្រជាជនទីក្រុងភ្នំពេញរួចមកហើយ ហើយក៏គាត់និយាយអំពីកម្មាភិបាលតួនាទីរបស់គាត់ រួមទាំងតួនាទីពាក់ព័ន្ធទៅនឹងការជម្លៀសប្រជាជន។ យើងខ្ញុំសូមលើកឡើងថា លោកសហព្រះរាជអាជ្ញាមិនមានឯកសារអ្វី ដែលត្រូវយកមកបង្ហាញពាក់ព័ន្ធលើសពីប្រធានបទអង្គហេតុពីរដែលយើងបានយកមកពិភាក្សាគ្នានៅក្នុងនេះ ដោយផ្អែកទៅលើច្បាប់អន្តរជាតិនោះឡើយ។

ដូច្នេះ ខ្ញុំលើកឡើងថា ឯកសារច្រើនពេកជាការគំរាមកំហែងមកដល់កូនក្តីរបស់ខ្ញុំ។ ឯកសារដែលមិនមានការពាក់ព័ន្ធទៅនឹងសំណួរសំខាន់ៗ មិនគួរយកមកគិតគូរឡើយ។ ហើយចំពោះបញ្ហាដែលថា វាជាការរាំងស្ទះដំណើរការនីតិវិធីរបស់យើងនេះ គឺយើងគិតថាមិនត្រឹមត្រូវនោះទេ។ ដូច្នេះហើយ ខ្ញុំស្នើសុំអង្គជំនុំជម្រះឲ្យកំណត់ឯកសារទាំងឡាយត្រឹមតែកម្រិតដែលវាពាក់ព័ន្ធ និងដែលមានលក្ខណៈច្បាស់លាស់សម្រាប់យកមកប្រើប្រាស់ក្នុងសវនាការតូចៗនេះតែប៉ុណ្ណោះ។

[១៣:៤១:០៥]

ចំណុចចុងក្រោយ យើងខ្ញុំបានលើកឡើងរួចមកហើយ ជាសាធារណៈផងដែរថា ការជំនុំជម្រះនៅតុលាការខ្មែរក្រហម ដោយមិនមានវត្តមានលោកសម្តេច សីហនុ នោះ គឺវាមិនអាចធ្វើទៅបាននោះទេ ទាល់តែមានវត្តមានរូបគាត់។ ដូចដែលករណី ឆាំង យុ ផងដែរ ដែលគួរតែអញ្ជើញគាត់មកក្នុងសវនាការនេះ។ លោក ឆាំង យុ គឺជាបុរសដែលមានសមត្ថភាពបំផុតក្នុងការមកផ្តល់សក្ខីកម្មពាក់ព័ន្ធទៅនឹងឯកសារ ឌី.ស៊ី.ខេម។

ដូច្នេះ ខ្ញុំសូមស្នើសុំ និងអញ្ជើញឲ្យអង្គជំនុំជម្រះកោះហៅគាត់ ដែល ឆាំង យុ នេះឲ្យមកផ្តល់សក្ខីកម្មពាក់ព័ន្ធទៅនឹងឯកសារ ឌី.ស៊ី.ខេម។ សូមអរគុណ។

**លោក សុន អរុណ៖**

សូមគោរពលោកប្រធានសាជាថ្មី។ ខ្ញុំមានប្រហែលជាដប់នាទីដែរ។ មុននឹងខ្ញុំថ្លែងនូវសេចក្តី

សរុប ខ្ញុំនឹងសូមធ្វើសេចក្ដីបញ្ជាក់សាឡើងវិញពីរចំណុចខ្លីៗ។ ខ្ញុំសូមបញ្ជាក់ថា លោក នួន ជា ស្នើសុំមើលតែច្បាប់ដើមនៃទង់បដិវត្ត និងទង់យុវជនយុវនារីតែប៉ុណ្ណោះសិន មិនបានសុំស្នើសុំទៅតុលាការសុំដាក់ជូនឯកសារទាំងពាន់ៗនោះទេ ដូចសហព្រះរាជអាជ្ញានិងមេធាវីការពារបាននិយាយឡើង មិនមានដូចអ៊ីចឹងទេ។

ទីពីរ ឯចំណែកឯកសារមួយចំនួនដែលខ្ញុំបានរៀបរាប់ពីម្សិលមិញ ទាំងអស់១៧ឯកសារ សុទ្ធតែមិនច្បាស់ ដែលពិបាកអាន ឬអានមិនយល់ តែខ្ញុំសុំឲ្យបញ្ចាំងស្លាយតែពីរជាឧទាហរណ៍តែប៉ុណ្ណោះ។ ទាំងអស់១៧ មាន១៧ ដែលមើលមិនច្បាស់នេះ។

[១៣:៤៣:១៣]

ខ្ញុំសូមបន្ត ក្រុមមេធាវីការពារ នួន ជា យើងខ្ញុំនៅតែរក្សាជំហរឲ្យបង្ហាញឯកសារដើម ដើម្បីពិភាក្សាពីយថាភាពរបស់ឯកសារ។ ការធ្វើបែបនេះ មិនមែនជាការពន្យារពេលសវនាការនោះទេ តែផ្ទុយទៅវិញ គឺដើម្បីស្វែងរកការពិត យុត្តិធម៌ និងមានប្រយោជន៍។

ជាការពិត លោក នួន ជា ចង់បានការកាត់ក្ដីដោយពេលវេលាឆាប់រហ័សបំផុត តែវាត្រូវតែជាការកាត់ក្ដីដោយយុត្តិធម៌ គឺមានន័យថា ភស្តុតាងដែលយកមកប្រើក្នុងតុលាការត្រូវតែមានការដេញដោល អំពីយថាភាព។ យើងមិនត្រូវរំលងទៅលើបញ្ហានេះ ដោយពន្លឿនសវនាការមួយ ដែលបម្រើតែសវនាការមួយ ដើម្បីកាត់ក្ដីកូនក្ដីខ្ញុំនោះទេ។ យុត្តិធម៌គឺដើម្បីគ្រប់ភាគីទាំងអស់ មិនមែនសម្រាប់តែភាគីម្ខាងនោះទេ។

[១៣:៤៤:២៨]

យើងបានស្ដាប់ឮពីជំហររបស់លោក នួន ជា ហើយនៅក្នុងសេចក្ដីថ្លែងបើករបស់លោកកន្លងទៅនេះ ហើយការសម្ភាសន៍របស់លោក ឆាំង យុ ឯនៅឯកសារ D204/4 បានបញ្ជាក់ថា ជំនាញការវៀតណាម បានផ្ដល់មក ឌី.ស៊ី.ខេម នូវឯកសារមួយចំនួន។ នេះបង្ហាញថា ឯកសារទាំងអស់នោះនៅតែជាការសង្ស័យមួយសម្រាប់លោក នួន ជា ដោយសារតែវៀតណាមមានបំណងជួយរៀបចំនិងត្រួតត្រាប្រទេសកម្ពុជាពីមុននិងក្រោយឆ្នាំ១៩៧៩ មកម្ល៉េះ។ ដូចនេះការបំភ្លៃឯកសារវាពិតជាកើតមានឡើង។

ជាថ្មីម្ដងទៀត ដើម្បីបញ្ជាក់ពីបញ្ហានេះ គឺមានតែលោក ឆាំង យុ និងមនុស្សមួយចំនួនទៀតដែលមេធាវីៗការពារយើងខ្ញុំបានស្នើសុំរួចមកហើយ ត្រូវមកទីនេះដោយយកភស្តុតាងជាយថាភូតដែលជា

ឯកសារដើមមកបង្ហាញតុលាការ ជាពិសេសចំពោះលោក នួន ជា នេះជាការមួយដើម្បីឆ្លើយនូវរាល់ចម្ងល់និងការសង្ស័យរបស់ខ្លួនជូនតុលាការ។ ដែលមានបំណងនឹងបំភ្លឺទៅប្រជាជនខ្មែរទូទាំង ទូទៅ និងប្រជាជនបរទេសជាច្រើនឆ្នាំមកហើយនោះ ដូចលោក នួន ជា បានឆ្លើយប្រាប់ទៅអ្នកកាសែតបានសម្ភាសន៍លោករួចមក។ គំនិតរបស់លោក នួន ជា នេះនៅតែមានដដែល។

[១៣:៤៦:២៩]

ក្នុងនាមខ្ញុំសហមេធាវីរបស់ នួន ជា ខ្ញុំសូមតុលាការទាំងមូលធ្វើយ៉ាងណាឲ្យការកាត់ក្តីមេដឹកនាំកម្ពុជាប្រជាធិបតេយ្យប្រកបដោយគតិយុត្តិ យុត្តិធម៌ និងមានប្រយោជន៍ ដោយមេធាវីខ្ញុំបាទស្នើសុំ៖

ទីមួយ សហព្រះរាជអាជ្ញាត្រូវតែសំអាងនូវសក្ខីកម្មទាំងអស់ (សូមទោស) នូវសក្ខីកម្មណាមួយដែលលោក នួន ជា គាត់តម្រូវដើម្បីយកមកតទល់ ប្រកបដោយយថាភាព ដើម្បីឲ្យមានប្រយោជន៍។

ពីរ ស្នើសុំចៅក្រមត្រូវតែធ្វើការពិចារណា និងសម្រេចដោយយុត្តិធម៌អាចទទួលយកបាន ដើម្បីឲ្យមានប្រយោជន៍ដល់ប្រវត្តិសាស្ត្រខ្មែរពីពេលនេះ និងទៅអនាគតសម្រាប់ប្រជាជនខ្មែរជំនាន់ក្រោយប្រកបដោយយុត្តិធម៌ និងគំរូដល់ពិភពលោកផងដែរ។ ហើយច្រានចោលនូវការចោទប្រកាន់ណាមួយដែលគ្មានភស្តុតាងជាលាយលក្ខណ៍អក្សរជាសំណៅដើម ដែលមេធាវីការពារព្រមទាំងជនត្រូវចោទបានស្នើសុំទៅតុលាការ និងព្រះរាជអាជ្ញារួចហើយ។ សូមអរគុណ។

[១៣:៤៧:៤៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ជាបន្តអង្គជំនុំជម្រះផ្តល់វេទិកាទៅមេធាវីការពារក្តីលោក អៀង សារី។

សូមអញ្ជើញ!

[១៣:៤៨:០១]

**លោក ម៉ៃខល កាណាវាស៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព និងលោក លោកស្រីនៅក្នុងនេះរួមទាំងនៅជុំវិញបន្ទប់សវនាការនេះ។ ខ្ញុំសូមចាប់ផ្តើមនៅក្នុងរសៀលនេះ ចាប់ផ្តើមពីចំណុចដែលដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ចប់ការលើកឡើងរបស់ខ្លួន ដែលគាត់ធ្វើការចោទប្រកាន់ថា ជនជាប់ចោទជាអ្នករំលោភបំពានទៅលើកិច្ចដំណើរការនីតិវិធី។ ដូច្នេះ អ្វីដែលយើងកំពុងតែព្យាយាមធ្វើនេះ តើវាជាការមួយដែលជាការមើលមាក់ងាយ និងជាការរំលោភបំពាននីតិវិធីដែរឬទេ? ខ្ញុំនឹងលើកឡើងថា ហេតុ

អ្វីជាយើងមកទីនេះ ហើយហេតុអ្វីយើងមានដំណាក់កាលមកទល់ពេលនេះ។

ដូចដែលសហព្រះរាជអាជ្ញាបានលើកឡើងថា សវនាការគួរតែរៀបចំឡើងនៅពេលណាមួយ។ ការស្នើសុំនេះ គឺនៅមុនពេលដែលយើងបានឈប់សម្រាក។ នៅថ្ងៃទី២៣ ខែធ្នូ សហព្រះរាជអាជ្ញា គាត់បានបញ្ជូនលិខិតថតចម្លងជូនដំណឹងមកកាន់យើង ដែលទាក់ទងទៅនឹងសេចក្ដីសន្និដ្ឋាន ឯកសារដាក់ចំនួន៩២ ទាក់ទងនឹងឯកសារចំនួន៩៧២ ឯកសារ។ ហេតុអ្វីបានជាពួកគាត់រង់ចាំរហូតមកដល់ថ្ងៃមុន *គ្រីស្តស្មាស*ពីរថ្ងៃ?

[១៣:៤៩:២៣]

សហព្រះរាជអាជ្ញា គាត់បានផ្ដល់នូវបញ្ជីលម្អិតអំពីឯកសារដែលក្នុងនោះរៀបរាប់យ៉ាងហោចណាស់ពួកគាត់ជឿជាក់ថា គឺជាតម្រុយបញ្ជាក់ដែលជាការជឿជាក់ពីខាងសហព្រះរាជអាជ្ញាថាដូច្នេះ។ យើងជឿជាក់សិនទៅលើឯកសារនេះ ក៏ប៉ុន្តែអ្វីដែលយើងបានឃើញថ្ងៃ១៧ ខែមករា តាមបញ្ជីនោះគឺសហព្រះរាជអាជ្ញាបានបង្ហាញឯកសារមួយចំនួន ហើយលើកឡើងថា ឯកសារទាំងអស់នោះពាក់ព័ន្ធគ្នាយ៉ាងម៉េច ហើយអាចចាត់ចែងយ៉ាងម៉េចទៅលើឯកសារនោះ?

ខ្ញុំសូមធ្វើការឆ្លើយតបទៅនឹងចំណុចហ្នឹង យើងខ្ញុំថ្លែងអំណរគុណទៅកាន់ខាងសហព្រះរាជអាជ្ញា ដែលគាត់បានចែករំលែកនូវវិធីសាស្ត្ររបស់ខ្លួន ហើយនិងវិធីសាស្ត្រដែលថាតើពួកគាត់ត្រូវចាត់ចែងយ៉ាងម៉េច ដើម្បីពិចារណាទៅលើយថាភាព ភាពអាចទុកចិត្តបាន និងភាពពាក់ព័ន្ធនៃឯកសារ។

[១៣:៥០:២៣]

ការជំទាស់ចម្បងរបស់យើងខ្ញុំ ប្រសិនបើខ្ញុំអាចនិយាយនៅពេលនេះបាន គឺយើងនិយាយដោយជឿជាក់ថាខាងសហព្រះរាជអាជ្ញាចង់ឲ្យទទួលយកគ្រប់ឯកសារទាំងអស់នៅពេលនេះ។ ការទទួលយកឯកសារនេះ រហូតដល់ដំណាក់កាលចុងក្រោយ រហូតដល់អង្គសវនាការអាចមានលទ្ធភាពស្ដាប់ភស្តុតាង។ វាមិនមែនថាឯកសារនោះត្រូវតែបង្ហាញជូនសាក្សីនោះទេ ការសំខាន់ថាតើយើងគួរតែបង្ហាញមូលដ្ឋានយ៉ាងម៉េចទៅលើឯកសារនោះ? ដោយសារឯកសារទាំងអស់នោះ វាមាននៅក្នុងសំណុំរឿងរួចហើយ ឬក៏ដោយសារតែមានការដកចេញពីសំណុំរឿងមកបញ្ចូលនៅក្នុងដីកាបញ្ជូនទៅជំនុំជម្រះ។ ដូច្នេះហើយគឺសហព្រះរាជអាជ្ញាស្នើថាមិនចាំបាច់ឲ្យចៅក្រមធ្វើការពិចារណាទៅលើចំណុចអ្វីផ្សេងនោះទៀតទេ ដោយសារតែឯកសារនេះមានទាំងអស់រួចហើយ។ ក៏ប៉ុន្តែខ្ញុំសូមលើកឡើងថា នៅពេលដែលសហព្រះរាជអាជ្ញានិយាយថាអ្វីដែលគាត់ធ្វើនេះជាការអនុវត្តអន្តរជាតិនោះ។ ខ្ញុំឯកភាពដែល

ថាបទដ្ឋានអន្តរជាតិពាក់ព័ន្ធទៅនឹងការទទួលយកភស្តុតាង។ ជាពិសេស ពាក់ព័ន្ធទៅនឹងការសម្រេច ហើយគេចាត់ចែងយ៉ាងម៉េចទៅលើយថាភាព ភាពជឿជាក់បាន និងភាពពាក់ព័ន្ធ ក៏ប៉ុន្តែនៅពេលដែល យើងនិយាយអំពីការអនុវត្ត គឺខាងសហព្រះរាជអាជ្ញា មិនមែនខាងការពារក្ដីទេ។ លើករឿង *ប្រលឹក* ដែលសហព្រះរាជអាជ្ញាស្នើសុំឱ្យអង្គជំនុំជម្រះមើលរឿងក្ដី ប្រលឹក នោះ។

[១៣:៥១:៥៧]

នៅក្នុងការព្យាយាមធ្វើសវនាការរយៈប្រាំឆ្នាំដើម្បីកាត់ក្ដីរឿងនុំង ខ្ញុំសូមលើកឡើងកំណត់សម្គាល់ របស់ខ្ញុំ ដែលខ្ញុំបានពិនិត្យមើលសេចក្ដីសម្រេចទាំងអស់នោះ។ នៅពេលដែលលោក លោកស្រីចៅក្រម មើលសេចក្ដីសម្រេចនោះ ថាតើគេអនុវត្តយ៉ាងម៉េច? ប៉ុន្តែយើងត្រូវចងចាំថានៅទីនេះ យើងមាននីតិ វិធីខុសពីតុលាការនុំង។ យើងមានការអនុវត្តប្រព័ន្ធច្បាប់បារាំង ហើយយើងមានការធ្វើវិសោធនកម្ម ដើម្បីអនុវត្តឱ្យបាននៅក្នុងអង្គជំនុំជម្រះវិសាមញ្ញរបស់យើង។ ក៏ប៉ុន្តែសហព្រះរាជអាជ្ញាជាអ្នកទាមទារ ថា នុំងជាបទដ្ឋានសម្រាប់យើងអនុវត្ត។ សហព្រះរាជអាជ្ញាជាអ្នកស្នើសុំថា អ្វីដែលយើងត្រូវធ្វើនោះ គឺយើងខ្ញុំគ្រាន់តែផ្ដល់បញ្ជីឯកសារនោះហើយ បន្ទាប់មកឯកសារនោះនឹងចូលជាឯកសារតែម្ដង។ ហើយ ឯកសារទាំងអស់នោះ វានឹងបង្ហាញឱ្យយើងឃើញតែម្ដង ថាតើវាពាក់ព័ន្ធ ឬមិនពាក់ព័ន្ធនៅពេលក្រោយ ឬក៏មិនអាចទុកចិត្តបាន?

[១៣:៥៣:០១]

ខ្ញុំសូមបញ្ជាក់ឱ្យបានច្បាស់លាស់ ការទទួលយកឯកសារមិនចាំបាច់បង្ហាញ ឬក៏មិនចាំបាច់ដាក់ ឯកសារនេះនៅចំពោះមុខសាក្សីនោះទេ ខ្ញុំចង់បញ្ជាក់ឱ្យបានច្បាស់ យើងខ្ញុំមិនបានស្នើសុំថាឯកសារ ទាំងអស់នោះគួរតែទទួលយកនោះទេ។ ហើយយើងត្រូវតែបង្កើតយថាភាពនោះឡើយ ហើយត្រូវតែ ទទួលយក អាចទទួលយកបាននោះត្រូវតែធ្វើឡើងបន្ទាប់ពីយើងដាក់នៅចំពោះសាក្សី។ ការដាក់នៅ ចំពោះសាក្សីដើម្បីបង្ហាញយថាភាព និងភាពអាចទុកចិត្តបាន និងភាពពាក់ព័ន្ធបាននោះ មិនមែនថាយើង តវ៉ាថា យើងត្រូវតែបង្ហាញយថាភាពមុនពេលដែលឯកសារទាំងអស់នោះដាក់នៅចំពោះមុខសាក្សីនោះ ទេ។ ខ្ញុំសង្ឃឹមថា ចំណុចនេះខ្ញុំបញ្ជាក់បានច្បាស់លាស់។

យើងខ្ញុំសូមលើកចំណុចលើកលែងនេះ ចំពោះខាងសហព្រះរាជអាជ្ញា ដែលថាយើងមានសិទ្ធិ ក្នុងការលើកឡើងដូច្នេះ។ ដូចដែលយើងខ្ញុំបានលើកឡើងរួចមកហើយ យោងតាមសេចក្ដីសម្រេចរបស់ អង្គបុរេជំនុំជម្រះនៅក្នុងកថាខណ្ឌ៣៤ នៃសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធទៅនឹងភាព

ទទួលយកបាននៃឯកសារ។ ជាពិសេសការសន្ធតបដិសេធទៅលើកិច្ចរបស់សហចៅក្រមស៊ើបអង្កេត ជាពិសេសពាក់ព័ន្ធទៅនឹងភស្តុតាងឯកសារដែលទទួលបានដោយសារអំពីទារុណកម្ម។ ឯកសារលេខ D30/7/3/5 កថាខណ្ឌ៣៤ ដែលធ្វើឡើងនៅក្នុងខែឧសភា ឆ្នាំ២០១០ អង្គបុរេជំនុំជម្រះសង្កេតឃើញថាវិធាន៨៧ ផ្តល់សិទ្ធិដល់ជនត្រូវចោទនូវលទ្ធភាពក្នុងការជំទាស់ទៅលើភស្តុតាងក្នុងពេលសវនាការ។

[១៣:៥៥:០០]

ដូច្នេះយើងមិនមែនថា យើងមិនយល់ច្បាស់នោះទេ យើងមិនបំពាននីតិវិធី និងច្បាប់នោះឡើយ។ យើងត្រូវបានអង្គជំនុំជម្រះអញ្ជើញឲ្យចូលរួមសវនាការនេះ ដូច្នេះហើយតាមរយៈការបកស្រាយរបស់អង្គបុរេជំនុំជម្រះទៅលើវិធាន យើងមានសិទ្ធិក្នុងតវ៉ាទៅលើភាពទទួលយកបាននៃភស្តុតាងមុនពេលដែលភស្តុតាងទាំងអស់នោះទទួលយកបាន។

[១៣:៥៥:២៩]

យើងមើលរឿងក្តី ប្រលឹក បន្តិចទៅ ហើយដើម្បីឲ្យអង្គសវនាការហ្នឹងមានចិត្ត មានការគិតគូរទៅលើរឿងក្តីនេះ។ ដូច្នេះខ្ញុំនឹងដកស្រង់ចំណុច និងសេចក្តីសម្រេចដែលសំខាន់ៗ យើងឃើញមានសេចក្តីសម្រេចជាង៦០ ដូច្នេះហើយបើសិនខ្ញុំចាំនោះ សេចក្តីសម្រេចនោះ គឺមានដល់១០០ឯណោះ ទាក់ទងនឹងភាពទទួលយកបានន័យភស្តុតាង។ ហេតុអ្វីបានជាការចេញសេចក្តីសម្រេចច្រើនដូច្នោះ? ដោយសារតែដំណើរការនីតិវិធីគេអនុញ្ញាតឲ្យធ្វើដូច្នោះ។ ភាគីដំបូងត្រូវបានអញ្ជើញនៅថ្ងៃទី-- នៅខែមីនា ឲ្យផ្តល់ជាយោបល់ពាក់ព័ន្ធនឹងគោលការណ៍ណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង ស្នើឡើងនៅខែមីនា ឆ្នាំ២០០៦។ ដូច្នេះខែមីនា ឆ្នាំ២០០៦ អង្គជំនុំជម្រះស្នើសុំឲ្យសហព្រះរាជអាជ្ញា និងភាគីធ្វើការលើកឡើងអំពីគោលការណ៍ណែនាំ។ គឺឯកសារ លេខ IT07/24/PT។

គោលការណ៍ណែនាំនេះ គឺអង្គជំនុំជម្រះសាលាដំបូងបង្ហាញជាគោលការណ៍ណែនាំនៅក្នុងរឿងក្តីហ្នឹង។ គោលការណ៍នាំណែនោះ ជាជំនួយទៅដល់ភាគីអំពីរយៈពេលដែលផ្តល់ជូនក្នុងការសួរសំណួរទៅកាន់សាក្សី។ ដូច្នេះវាជាគោលការណ៍ណែនាំពាក់ព័ន្ធទៅនឹងពេលវេលា ការចែកពេលវេលា។ នៅខែមេសា ឆ្នាំ២០០៦ អង្គជំនុំជម្រះសាលាដំបូងចេញសេចក្តីកែប្រែទៅលើគោលការណ៍ណែនាំពាក់ព័ន្ធទៅនឹងកិច្ចដំណើរការនីតិវិធី។ នៅក្នុងគោលការណ៍ណែនាំនោះ គោលការណែនាំដែលបានកែប្រែនោះនៅក្នុងសេចក្តីសម្រេចនោះទស្សនៈទាននៃភាគីដាក់ជូននូវសំណុំរឿង ជូនអង្គសវនាការសាលាដំបូងត្រូវបានភាគីលើកឡើង។ នៅពេលនោះ អង្គជំនុំជម្រះសាលាដំបូងបានអញ្ជើញភាគី ឲ្យដាក់សំណុំឯកសារ

ពាក់ព័ន្ធទៅនឹងផ្នែកដែលជាប់ទាក់ទងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ឧទាហរណ៍បទល្មើសដែលបានកើតឡើង ទីកន្លែង ពេលវេលាដែលភាគីអាចស្នើសុំឯកសារដែលពាក់ព័ន្ធទាំងអស់នោះ។

[១៣:៥៨:០៧]

នៅក្នុងកថាខណ្ឌ១១ នៃសេចក្តីសម្រេចនេះ ខ្ញុំផ្តល់ជាគំនិតទេ ប្រសិនបើសហព្រះរាជអាជ្ញា ឬក៏ភាគីមានបំណងចង់ផ្តល់អង្គជំនុំជម្រះនូវសំណុំឯកសារពាក់ព័ន្ធទៅនឹងភូមិសាស្ត្រ ទីតាំងដែលមាននៅក្នុងដីកាបញ្ជូនជំនុំជម្រះដែលបទល្មើសត្រូវបានចោទប្រកាន់ថាកើតឡើងនោះ គឺអាចធ្វើទៅបាន។ បញ្ជីនៃសំណើឯកសារគួរតែដាក់នៅពេលណាមួយក៏បានដែរ ក្នុងពេលសវនាការ។ ក៏ប៉ុន្តែសំណើសុំនូវបញ្ជីឯកសារនោះ ត្រូវគោរពតាមនីតិវិធីនៃការទទួលយកភស្តុតាង ហេតុដូច្នេះដើម្បីធានាថា សំណុំឯកសាររួមមានឯកសារ និងចំណុចដែលទទួលយកបាននោះ។ គឺរួមទាំងវត្ថុតាង និងសាក្សីរហូតដល់វត្ថុតាងសាក្សីទាំងអស់នោះទទួលយកដោយអង្គជំនុំជម្រះ។ ចំណុចនេះពិតជាសំខាន់ណាស់ ដែលខ្ញុំនឹងចូលទៅដល់ចំណុចនេះនៅពេលក្រោយ។ យើងអរគុណ និងគោរពទៅលើនីតិវិធីដែលគេបានអនុវត្ត ហើយដើម្បីជាគោលបំណងរបស់យើង យើងគួរតែមើលទៅលើនីតិវិធីនេះ។ ទោះបីជាយើងគិតថាវាជាការចំណាយពេលក៏ដោយ។

[១៣:៥៩:៣៣]

នៅខែកក្កដា ឆ្នាំ២០០៦ អង្គជំនុំជម្រះសាលាដំបូងចេញសេចក្តីសម្រេចទទួលយកភស្តុតាង នៅក្នុងសេចក្តីសម្រេចមួយនេះ ទំព័រទីពីរ សាលាដំបូងកំណត់សម្គាល់ឃើញថា ខ្លួនបានទទួលនូវបញ្ជីឯកសារនិងភស្តុតាង។ សំណើនេះដាក់ដោយខាងសហព្រះរាជអាជ្ញានៅថ្ងៃ១៥ ខែមិថុនា ឆ្នាំ២០០៦ ដែលក្នុងនោះសហព្រះរាជអាជ្ញាស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងឱ្យទទួលយកឯកសារមកពីសហគមន៍ អ៊ី.ស៊ី.អឹម.អឹម គឺឯកសារមកពី អ៊ី.ស៊ី.អឹម.អឹម ចូលជាភស្តុតាង។ នេះគឺជាឯកសារដែលសហព្រះរាជអាជ្ញា គាត់ព្យាយាមស្នើសុំឱ្យទទួលយក ដោយផ្អែកទៅលើឯកសារដែលចេញពីស្ថាប័នមួយនេះ គឺ អ៊ី.ស៊ី.អឹម.អឹម។

[១៤:០០:២៧]

នៅក្នុងសេចក្តីសម្រេចរបស់សាលាដំបូងមួយនេះ សាលាដំបូងបានបញ្ជាក់ចំណុចជាច្រើន។ ខ្ញុំមិនលើកគ្រប់ចំណុចនោះទេ ក៏ប៉ុន្តែខ្ញុំសូមឱ្យអង្គជំនុំជម្រះសាលាដំបូងនេះ មើលសេចក្តីសម្រេចមួយនេះ។ ខ្ញុំសូមផ្តល់ជាលេខ ប្រសិនបើវាល្អសម្រាប់លោក លោកស្រីចៅក្រម នៅក្នុងទំព័រទី៦ អង្គជំនុំ

ជម្រះសាលាដំបូងកត់សម្គាល់ឃើញថា ទោះបីជានៅក្នុងរឿងក្តីនេះតុលាការកំពូល កត់សម្គាល់អំពីវិធាន៩០ អេហ្វ ហើយសម្រេចនូវឆន្ទានុសិទ្ធិរបស់សាលាដំបូង ក្នុងការអនុវត្តវិធានក៏ដោយ ទោះបីជាតុលាការកំពូលមើលឃើញអំពីនីត្យានុកូលភាព ដែលមិនត្រូវពន្យារពេលនីតិវិធីនៅក្នុងសវនាការ ហើយត្រូវគោរព និងសម្រេចឲ្យបានក្នុងរយៈពេលមួយសមស្របក៏ដោយ។ ដោយយល់ឃើញថា វត្ថុតាងដែលបានដាក់ជូនដោយសហព្រះរាជអាជ្ញា នៅក្នុងវិធាន៦៥ ដែលក្នុងនោះមានឯកសារវត្ថុតាង៩៤០០ ឯកសារ និងវត្ថុតាង។

[១៤:០១:៥១]

ដោយឃើញថា សហព្រះរាជអាជ្ញាចង់លើកឡើងអំពីឯកសារទាំងអស់នេះ ដោយមិនទាន់មានការពិភាក្សាជជែកវែកញែកនៅចំពោះមុខតុលាការនៅឡើយ។ ដូច្នេះ ខ្ញុំសូមឈប់ត្រង់កន្លែងហ្នឹងសិនដើម្បីឲ្យយើងយល់ថាតើគេព្យាយាមធ្វើអ្វីនៅក្នុងរឿងក្តីនោះ? ដោយមិនទាន់បានពិភាក្សានៅចំពោះមុខអង្គសវនាការនៅឡើយ។ ដូច្នេះបានន័យថា មិនទាន់ដាក់នៅចំពោះមុខសាក្សីនៅឡើយ។

ដោយយល់ឃើញថា ការទទួលយកឯកសាររាប់ពាន់ឯកសារដោយពុំមានការពិភាក្សាលើឯកសារនេះនៅក្នុងតុលាការ អាចធ្វើឲ្យពន្យារនីតិវិធីយ៉ាងច្រើន ដែលវាមិនអាចឲ្យអង្គជំនុំជម្រះទទួលប្រយោជន៍ពីការពន្យល់ពីសាក្សី អំពីបរិបទភាពពាក់ព័ន្ធនឹងតម្លៃនៃភស្តុតាងរបស់វា។ ដោយយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូង ទាមទារឲ្យមានប្រភព-- ពិនិត្យទៅលើប្រភពទាំងបី គឺការពិនិត្យឯកសាររាប់ពាន់ទំព័រដែលការពិនិត្យនេះ អាចចំណាយពេលយ៉ាងច្រើនក្នុងការប្រកាសសាលក្រម។

[១៤:០៣:១៥]

ខ្ញុំសូមរំលងចំណុចមួយ ដោយយល់ឃើញថា មេធាវីការពារក្តីអាចបាត់បង់ប្រយោជន៍ ប្រសិនបើត្រូវបានគេបង្ខំឲ្យប្រើប្រាស់ពេលវេលា ដែលបែងចែកឲ្យក្នុងការដេញដោល និងបង្ហាញឯកសារជាលើកដំបូងនៅក្នុងសវនាការ ជាពិសេសចំពោះឯកសារដែលមេធាវីការពារក្តីតវ៉ាទៅលើ តម្លៃភស្តុតាង និងភាពអាចទុកចិត្តបាន។ ដោយយល់ឃើញថា សហព្រះរាជអាជ្ញា មានភារកិច្ចក្នុងការធ្វើជម្រើសក្នុងកំណត់អត្តសញ្ញាណនូវឯកសារទាំងអស់នោះ ដើម្បីសម្រេចនូវចំណុចដែលមានបញ្ហា ហើយនិងត្រូវបង្ហាញឯកសារទាំងអស់នោះទៅដល់សាក្សី ដើម្បីធ្វើយ៉ាងណាផ្តល់អង្គជំនុំជម្រះនូវព័ត៌មាននៅក្នុងតុលាការអំពីយថាភាព ភាពពាក់ព័ន្ធ និងតម្លៃនៃភស្តុតាងនូវឯកសារទាំងអស់នោះ។

[១៤:០៤:១០]

បន្ទាប់មកនៅក្នុងសេចក្តីនោះ គឺគេលើកឡើងអំពីផលប្រយោជន៍នៃយុត្តិធម៌ ហើយនៅក្នុងនោះ គេលើកឡើងថា ហេតុដូច្នេះហើយសម្រេចថា ឯកសារទាំងអស់នោះអាចដាក់ជូនតាមរយៈសាក្សី ដែលសាក្សីនោះត្រូវតែមកផ្តល់សក្ខីកម្ម។ ដូច្នេះ ចំណុចនេះមានន័យថា ជាជាងព្យាយាមដាក់ឯកសារទាំងអស់នោះ ដែលបង្កើតឡើងដោយភាគី អង្គជំនុំជម្រះសាលាដំបូង មានចេតនា និងមានឆន្ទៈក្នុងការកោះហៅសាក្សីមួយរូប ឬក៏ច្រើនជាងនោះឲ្យមកផ្តល់សក្ខីកម្ម។ ចងភ្ជាប់ទៅនឹងសេចក្តីសម្រេចនោះ-- ភ្ជាប់ជាមួយនឹងសេចក្តីសម្រេចនោះ គឺវាជាឯកសារមួយសំខាន់ សម្រាប់សាលាដំបូងគឺគោលការណ៍ណែនាំស្តីអំពីការទទួលយកភស្តុតាង។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងផ្តល់នូវគោលការណ៍ណែនាំនេះ គឺជារឿងក្តីដែលគេគម្រោងថាធ្វើតែពីរឆ្នាំទេ តែគេធ្វើឡើយរហូតទៅដល់ប្រាំឆ្នាំ។

គោលការណ៍ណែនាំទីប្រាំមួយ នេះគឺជាគោលការណ៍ណែនាំសម្រាប់ខាងសហព្រះរាជអាជ្ញា។ សហព្រះរាជអាជ្ញាមើល និងពិចារណាដែលគោលការណ៍ណែនាំនេះ ចំពោះមេធាវីការពារក្តីផងដែរ។ គោលការណ៍ណែនាំនេះ វាហាក់ដូចជាគោលការណ៍ណែនាំមួយដែលវាមានភាពសមស្រប។ គោលការណ៍ណែនាំទីប្រាំមួយ គឺវាសមស្របទៅនឹងរឿងក្តីរបស់យើង គោរព ដោយពិចារណាទៅលើបទប្បញ្ញត្តិនានា។ សហព្រះរាជអាជ្ញាត្រូវតែធ្វើយ៉ាងណាកោះហៅសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង តាមរយៈកំណត់សម្គាល់ដើម្បីទទួលយកភស្តុតាងដែលត្រូវដាក់នៅចំពោះមុខសាក្សី ហើយសាក្សីនោះត្រូវតែមកផ្តល់សក្ខីកម្ម។

[១៤:០៦:០៥]

មានន័យថា ចំពោះសាក្សីនីមួយៗយើងត្រូវតែរៀបចំឯកសារមួយសំណុំ ដែលត្រូវបង្ហាញជូនសាក្សី។ ដោយសារតែពេលវេលា ប្រហែលជាយើងអាចពិនិត្យមើលតែឯកសារនោះមួយភាគបីតែប៉ុណ្ណោះ។ ឯកសារដទៃទៀត នៅពេលដែលយើងស្នើសុំឲ្យទទួលយកតាមរយៈសំណើនោះ គឺយើងត្រូវតែបង្ហាញអំពីលក្ខណៈវិនិច្ឆ័យ និងលក្ខខណ្ឌរបស់វា ដូចជា៖ យោងទៅលើកថាខណ្ឌដែលពាក់ព័ន្ធទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចំណុចយោងទៅលើសាក្សី និងឯកសារដែលមានសរសេរដូចគ្នានៅក្នុងកថាខណ្ឌបញ្ជូនទៅជំនុំជម្រះ ហេតុផល ហេតុអ្វីបានជាឯកសារនេះត្រូវបង្ហាញជូនសាក្សី? ហេតុអ្វីបានជាឯកសារទាំងអស់នេះ មិនអាចបង្ហាញជូនសាក្សីមួយទៀត?

[១៤:០៦:៥៥]

ដូច្នេះវាមានន័យថា សាក្សី-- ឯកសារនេះត្រូវបង្ហាញសាក្សីមួយ ហើយមិនអាចបង្ហាញទៅ

សាក្សីមួយទៀត ហើយហេតុផលដែលថាហេតុអ្វីបានឯកសារនោះមានសារៈសំខាន់។ ខ្ញុំគួរតែកត់សម្គាល់ជូនអង្គសវនាការថា នៅពេលដែលគេបញ្ចប់រឿងក្ដីសំណើពីខាងសហព្រះរាជអាជ្ញានោះ ឬក៏បញ្ចប់រឿងក្ដីរបស់ខាងមេធាវីការពារក្ដី ដោយសារតែជនជាប់ចោទចំនួនប្រាំមួយ។ សហព្រះរាជអាជ្ញាគាត់បានស្នើសុំឱ្យទទួលយកឯកសាររាប់ពាន់ឯកសារ ដែលគេគិតថា វាពាក់ព័ន្ធ ហើយវាមិនជាប់ទាក់ទងទៅនឹងសាក្សីណាមួយនោះ។

[១៤:០៧:៣០]

ភាគីទាំងសងខាងព្យាយាមបង្ហាញដាក់ជូននូវឯកសាររាប់ពាន់ ទោះបីជាមិនរាប់រយក៏ដោយគឺមានឯកសារនោះ រាប់ពាន់ឯកសារត្រូវបានបដិសេធចោល ដោយទទួលយកតែប៉ុន្មានរយតែប៉ុណ្ណោះ។ ដូច្នេះ នេះគឺជាការអនុវត្តដែលគាត់ស្នើសុំឱ្យមើល គឺគាត់ថាស្នើសុំឱ្យដាក់បញ្ចូលទាំងអស់បន្ទាប់មកពិនិត្យមើលតាមក្រោយ។ នៅពេលដែលយើងដាក់វាទៅ បន្ទាប់មកយើងនឹងស្នើសុំឯកសារទាំងអស់នោះ ដាក់នៅចំពោះមុខសាក្សី។ ឯកសារទាំងអស់នោះ គឺពេលខ្លះយើងមិនអាចដាក់នៅចំពោះមុខសាក្សីផង ដោយផ្អែកត្រឹមតែលើសក្ខីកម្មដែលសហព្រះរាជអាជ្ញាបានលើកឡើងតែប៉ុណ្ណោះ។ ជាការពិតគឺថា យើងអាចសាកសួរតាមរយៈសាក្សីផ្សេងទៀតបាន ប្រសិនណាជាសាក្សីនៅក្នុងផ្នែកជាក់លាក់។

ឧទាហរណ៍ពាក់ព័ន្ធទៅនឹងប្រវត្តិសាវតារនេះ យើងមានឯកសារ៥៥០០ អ៊ីចឹងយើងគឺថា។អង្គជំនុំជម្រះអាចនឹងមានពេលវេលា ឬក៏មិនអាចជ្រើសរើស ហើយបន្ទាប់មកបានឈានទៅដល់ការសម្រេចទទួលយកឯកសារនេះ។

[១៤:០៨:៣៥]

ផលប្រយោជន៍នៃការធ្វើដូចនេះ គឺដោយសារតែមានប្រយោជន៍សម្រាប់ឱ្យអង្គជំនុំជម្រះទទួលបាននូវពីសក្ខីកម្ម ដើម្បីសម្រេចទទួលយកឯកសារ។ គេមិនសម្រេចបញ្ឍប់ត្រឹមតែប៉ុណ្ណោះទេ នៅចុងបញ្ចប់គឺថាអង្គជំនុំជម្រះនៅតែឈានទៅធ្វើការសម្រេច ដើម្បីទទួលយកឯកសារនេះទាំងនេះ។ ដោយ--ដើម្បីឱ្យអង្គជំនុំជម្រះបានស្វែងយល់ពេញលេញអំពីប្រវត្តិសាវតារនេះ។ ហើយពាក់ព័ន្ធទៅនឹងទម្ងន់នៃឯកសារ គឺជារឿងមួយដែលអង្គជំនុំជម្រះត្រូវសម្រេច នៅពេលធ្វើសេចក្ដីសន្និដ្ឋានសម្រេចសេចក្ដីនោះ។ ហើយចំណុចដែលគួរឱ្យចាប់អារម្មណ៍មួយទៀតនេះ គឺនៅថ្ងៃទី១៣ ខែធ្នូ ២០០៦ សេចក្ដីសម្រេចស្ដីអំពីការទទួលយកឯកសារនេះ នូវឯកសារដែលបានដាក់ជូននៅក្នុងអំឡុងពេលសវនាការ។

[១៤:០៩:២៨]

នៅពេលនេះ គឺថាអង្គជំនុំជម្រះសាលាដំបូងបានដាក់ចេញនូវបែបបទមួយ ដូចដែលខ្ញុំបានលើកខាងដើម។ ទីមួយ គឺត្រូវដាក់ឯកសារសាកសួរចំពោះមុខសាក្សី ហើយនៅពេលបញ្ចប់ទៅគឺភាគីមានសិទ្ធិដាក់ឯកសារដែលត្រូវសម្រេចទទួល ដើម្បីជាការកត់ត្រា។ ភាគីបដិបក្ខមានរយៈពេលមួយថ្ងៃដើម្បីធ្វើការជំទាស់ មានឱកាសដើម្បីធ្វើការឆ្លើយតប បន្ទាប់មកទើបចេញសេចក្តីសម្រេចប្រកបដោយហេតុផល ថាហេតុអ្វីបានជាឯកសារនេះត្រូវបានទទួល ឬក៏ត្រូវបានបដិសេធចោលនោះ។ នេះគឺជាការអនុវត្តនៅក្នុងរឿងក្តីនេះ។ ដូចដែលខ្ញុំបានលើកឡើងគឺថា នៅថ្ងៃទី២៤ ខែមេសា ២០០៨ គឺមេធាវីការពារក្តីទទួលបាននូវគោលការណ៍ណែនាំ។ ដូច្នេះ ចៅក្រមអង្គជំនុំជម្រះសាលាដំបូងនៅទីនេះអាចនឹងពិនិត្យមើលចំណុចនេះបាន។

ខ្ញុំចង់លើកឡើងនូវសេចក្តីសម្រេចមួយ សេចក្តីសម្រេចនៅថ្ងៃទី៣ ខែធ្នូ ២០០៩ ដោយមានវេជ្ជបណ្ឌិត វ៉ូឡង់ ប្រលីក បដិសេធមិនទទួលនូវភស្តុតាងមួយចំនួន។ នៅក្នុងសេចក្តីសម្រេចនេះដែលសេចក្តីសម្រេចដែលបានច្រានចោលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង។ អង្គជំនុំជម្រះតុលាការកំពូលបានរកឃើញថា បទដ្ឋានដែលអង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់នៅក្នុងរឿងក្តីក្នុងការទទួលឯកសារនេះ គឺបទដ្ឋាននេះជាបទដ្ឋានមួយដែលមានកម្រិតខ្ពស់ គឺជាបទដ្ឋានមួយទៀតសម្រាប់ខាងផ្នែកអយ្យការ ប៉ុន្តែជាបទដ្ឋានមួយខ្ពស់សម្រាប់មេធាវីការពារក្តី។

[១៤:១១:៣៨]

គឺមិនមានការទទួលយកឯកសារជាស្វ័យប្រវត្តិនោះទេ គឺត្រូវតែមានការជជែកតវ៉ាគ្នា មុននឹងឈានទៅដល់ការសម្រេចទទួលយកឯកសារណាមួយនោះ។ ប៉ុន្តែនៅទីនេះខ្ញុំសូមលើកឡើងថា មិនគួរណាទទួលយក-- មិនត្រូវទទួលយកឯកសារដោយស្វ័យប្រវត្តិនោះទេ។ ខ្ញុំនឹងបង្ហាញជូននូវចំណុចនេះនៅក្នុងរឿងក្តីដែលខ្ញុំបានលើកឡើងនេះ។

មានបញ្ហាច្រើនណាស់សម្រាប់ ប្រលីក។ ការសម្រេចនេះគឺថាមានលក្ខណៈស៊ីសង្វាក់។ ដូច្នេះមានជំហរមួយច្បាស់លាស់។ ដូច្នេះ ខ្ញុំសូមលើកឡើងថា មុនទទួលយកឯកសារដ៏តូចណាមួយក៏ដោយគឺសហព្រះរាជអាជ្ញាត្រូវផ្តល់នូវ បង្ហាញនូវលក្ខណៈវិនិច្ឆ័យ។ យើងខ្ញុំឃើញថា គឺមានលក្ខណៈមានលទ្ធភាពអាចធ្វើដូច្នេះបាន ថាតើសហព្រះរាជអាជ្ញាមានបំណងចង់ភ្ជាប់ឯកសារមួយ ទៅឯកសារមួយដោយរបៀបណា?

ដូច្នេះ យើងខ្ញុំសូមស្នើថា តម្រូវឱ្យសហព្រះរាជអាជ្ញាធ្វើបែបដូច្នេះ នៅពេលដែលដំណើរការ

នីតិវិធីកំពុងតែបន្តទៅមុខដូច្នេះ។ ខ្ញុំមិនយល់ស្របថា អង្គជំនុំជម្រះត្រូវតែទទួលយកគ្រប់ឯកសារទាំងអស់នោះទេ។ ប្រសិនជាអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ដោយសារតែចរិតលក្ខណៈពិសេសនៃតុលាការនេះត្រូវតែទទួលយកឯកសារទាំងអស់នោះទេ គឺត្រូវតែមានការផ្តល់សក្ខីកម្មពីសហព្រះរាជអាជ្ញា។ មិនមែនគ្រាន់តែជាការរៀបរាប់អីចឹងថា នេះគឺជាស្លាកសញ្ញា នេះគឺជាឈ្មោះ នេះគឺជាបាវចនាអីយ៉ាងដូច្នេះទេ។

[១៤:១៣:២២]

ហើយដោយគ្រាន់តែអត្ថាធិប្បាយនោះទេ។ ការធ្វើការអត្ថាធិប្បាយនេះ គឺគ្រាន់តែដើម្បីបង្ហាញឡើងនូវយថាភាព ឬក៏ភាពអាចទទួលយកបាននៃឯកសារនោះទេ គឺគាត់មានសិទ្ធិធ្វើដូច្នេះបាន ក៏ប៉ុន្តែមិនមែនក្នុងដំណាក់កាលនេះទេ។ ខ្ញុំសូមឱ្យដាក់ឯកសារនៅចំពោះមុខសាក្សី។ សាក្សីអាចយល់ស្របឬក៏មិនយល់ស្របទទួលស្គាល់ ឬក៏មិនទទួលស្គាល់ ហើយសឹមបន្តចូលទៅដល់ការសម្រេចទទួលយកឯកសារ។

យើងអាចសម្រេច ការសម្រេចទទួលយកឯកសារនៅដំណាក់កាលនីមួយៗនៃការសួរដេញដោលនេះ។ មានមធ្យោបាយច្រើនណាស់ដែលត្រូវធ្វើផ្សេងៗគ្នា។ ការដែលគ្រាន់តែទទួលយកឯកសារមកទាំងស្រុងតែម្តង គឺមិនមែនជាមធ្យោបាយមួយដែលត្រឹមត្រូវ ដែលត្រូវតែធ្វើនោះទេ គឺត្រូវកម្រិតចំនួនសាក្សីដែលត្រូវកោះហៅ ហើយខ្ញុំជំទាស់តវ៉ាជាមួយសហព្រះរាជអាជ្ញានៅទីនេះ សូមកែតម្រូវខ្ញុំផងបើខ្ញុំច្រឡំគឺថា បើគាត់មិនធ្វើការបង្ហាញនេះ ខ្ញុំក៏មិនមានលទ្ធភាពដើម្បីស្តាប់សាក្សីទាំងអស់ ដើម្បីពិនិត្យទៅលើឯកសារទាំងអស់នោះទេ។

[១៤:១៤:៤០]

ដូច្នេះ ការធ្វើបែបនេះ ពេលចូលទៅដល់បញ្ហាសារព័ត៌មាន។ ឧទាហរណ៍មានអ្នកគេនិយាយថាមានការផ្តល់នូវសេចក្តីថ្លែងការណ៍ណាមួយដូច្នេះ ឬក៏ដកស្រង់សម្តីពីអ្នកណាម្នាក់ទាំងមិនត្រឹមត្រូវ ហើយមិនមានឱកាសសួរតទល់បែបនេះ។ យើងខ្ញុំជឿជាក់ថា នោះប្រាកដជាមានការមន្ទិលសង្ស័យ ហើយអង្គជំនុំជម្រះសម្រេចទទួលយកឯកសារ ប៉ុន្តែភាគីមិនមានឱកាសដើម្បីធ្វើការជំទាស់តវ៉ាទៅលើឯកសារទាំងអស់នេះ។

ខ្ញុំសូមលើកឡើងនូវចំណុចមួយទៀត រឿងក្តីមួយដែលខាងសហមេធាវីតំណាងរដ្ឋប្បវេណីលើកឡើងអំពីរឿងក្តី--

ខ្ញុំសូមត្រឡប់ចូលរឿងក្ដីនេះ ដោយបង្ហាញនូវឯកសារ ខ្ញុំដឹងរឿងនេះ ពីព្រោះខ្ញុំក៏ដឹងអំពីកាលៈទេសៈជុំវិញរឿងក្ដីនេះផងដែរ។ នេះគឺជាឱកាសមួយដែលថា ហេតុអ្វីបានជាសេចក្ដីថ្លែងការណ៍នៅក្នុងសារព័ត៌មាន ការលើកឡើងនៅក្នុងសារព័ត៌មាន មិនអាចជឿទុកចិត្តបាន ហើយដោយគ្រាន់តែមើលទៅលើសេចក្ដីរាយការណ៍ព័ត៌មាននោះ គឺវិធីដែលល្អគឺថាគួរណាមិនទទួលយកឯកសារបែបនេះនោះទេ។

[១៤:១៦:២១]

នៅក្នុងរឿង អាលីឡូវិច បញ្ហាដែលលេចឡើងនោះ គឺអង្គជំនុំជម្រះសាលាដំបូង នៅក្នុងការទទួលសារណាពីសហព្រះរាជអាជ្ញាបានសម្រេចទទួលយកសេចក្ដីថ្លែងការណ៍មួយចំនួន ចម្លើយសារភាពមួយចំនួន ដោយ អាលីឡូវិច។ លោក អាលីឡូវិច មិនបានត្រូវបានគេសួរចម្លើយទេ ប៉ុន្តែគេទៅជាយកសេចក្ដីថ្លែងការណ៍របស់គាត់មកលើកឡើង។ មេធាវីការពារក្ដីជំទាស់តវ៉ា គឺថានៅពេលដែលគាត់ផ្ដល់នូវសេចក្ដីថ្លែងការណ៍មួយចំនួននោះ គឺព្រះរាជអាជ្ញាបានញុះញង់ធ្វើម៉េចឲ្យគាត់បោះបង់សិទ្ធរបស់គាត់ ដោយប្រាប់គាត់ថា ការសហការរបស់គាត់នេះ គឺអាចនាំឲ្យគាត់មានឈានទៅដល់ការដោះលែងខ្លួនជាបណ្ដោះអាសន្នសិន។ នេះមិនមែនអាស្រ័យលើសហ-- ទៅលើព្រះរាជអាជ្ញាដែលសន្យាបែបដូច្នេះទេ។ ប្រហែលដោយការគាត់យល់ច្រឡំ។ ហើយបើ--

[១៤:១៧:៣៩]

នេះជារឿងមួយ ដែលគេបកស្រាយរបៀបនេះឯង។ ហើយនៅក្នុងបញ្ហានេះ គឺតុលាការកំពូលរកឃើញថាសាលាដំបូង ការទទួល ដោយទទួលយកសេចក្ដីថ្លែងការណ៍ហ្នឹងមកដាក់ក្នុងសំណុំ ហើយក៏សម្រេចទៅជាអង្គហេតុមួយ។

យើងកំពុងតែប្រឈមមុខទៅនឹងបញ្ហាប្រព័ន្ធផ្សេងៗគ្នា។ ខ្ញុំសូមបង្ហាញនូវគោលបំណងជូនអង្គជំនុំជម្រះដំបូងថាមិនមានវិធានជាស្វ័យប្រវត្តិណាថា ត្រូវតែទទួលយកភស្តុតាងទាំងអស់នោះទេ ហើយខ្ញុំជឿជាក់ថាសូម្បីតែលោក បៀល។ ខ្ញុំថាលោក បៀលស្មឹត ក៏យល់ស្របជាមួយខ្ញុំក្នុងរឿងនេះដែរ។

រយៈពេលបួនថ្ងៃកន្លងមកនេះ គឺយើងមានការលើកឡើងដដែលៗ បានលើកនិយាយថាដូច្នេះ។ បាទ ខ្ញុំទទួលស្គាល់ថាខ្ញុំលើកឡើងដដែលៗដូច្នោះមែន។ យើងបានលើកឡើងនូវអ្វីដែលបានយើងជឿជាក់ថា តុលាការគួរតែសម្រេចនូវនីតិវិធីណាមួយ ឬក៏យ៉ាងហោចណាស់ក៏ពិចារណាទៅលើនីតិវិធីនេះ។ យើងខ្ញុំជឿជាក់ថា ថ្ងៃនេះជាថ្ងៃមួយសំខាន់ណាស់ក្នុងរយៈពេលបួនថ្ងៃកន្លងមកនេះ។ ខ្ញុំគិតថាខ្ញុំមិនបានរំលោភបំពានទៅលើដំណើរការជំនុំជម្រះក្ដីនេះទេ។

មេធាវីការពារក្តីសូមអរគុណដល់អង្គជំនុំជម្រះសាលាដំបូង ដែលអនុញ្ញាតឱកាស ផ្តល់ឱកាសរបស់យើង មកដល់យើងខ្ញុំដើម្បីបង្ហាញជូនសាធារណជនក្នុងមធ្យោបាយបែបនេះ។សូមអរគុណច្រើន។

[១៤:១៩:១៧]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ ជាបន្ត អង្គជំនុំជម្រះសូមផ្តល់វេទិកាទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន។ សូមអញ្ជើញ!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន សូមគោរពក្រុមប្រឹក្សាជំនុំជម្រះ សូមគោរពអង្គសវនាការទាំងមូល។ ជាបឋមខ្ញុំបាទ សូមធ្វើការកែតម្រូវមួយចំនួនទាក់ទងទៅនឹងការលើកឡើងរបស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិទៅលើថា ខ្ញុំបានតម្រូវឲ្យព្រះរាជអាជ្ញា សហព្រះរាជអាជ្ញាបង្ហាញឯកសារឲ្យលើសពីវិមតិសង្ស័យ។ ហើយចំណុចនេះខ្ញុំបាទសូមមិនធ្វើការបកស្រាយទេ ប៉ុន្តែដូចដែលលោកប្រធានបានជម្រាបកាលពីថ្ងៃមិញថា ដោយខ្ញុំបាននិយាយជាភាសាខ្មែរ អ៊ីចឹងខ្ញុំសូមអញ្ជើញសហព្រះរាជអាជ្ញាពិនិត្យទៅលើប្រតិចារឹកជាភាសាខ្មែរដែលខ្ញុំបានលើកនៅពេលនោះ គឺខ្ញុំនិយាយសំដៅទៅលើតម្រុយដែលអាចឲ្យជឿជាក់បាន។ ដូចគ្នានេះដែរ ក្នុងត្រង់ចំណុចដែលថា ការទទួលយកបាននៃឯកសារពីសំណុំរឿង០០១ យកមកដាក់នៅក្នុងសំណុំរឿង០០២ នេះ ខ្ញុំសូមឲ្យសហព្រះរាជអាជ្ញាមេត្តាពិនិត្យទៅលើប្រតិចារឹកនោះដែរ គឺថា ខ្ញុំមិនជំទាស់ថាមិនឲ្យយកឯកសារនោះមកដាក់បញ្ចូលនៅក្នុងសំណុំរឿង ០០២ ទេ។ ប៉ុន្តែខ្ញុំបានលើកការអះអាងផ្សេងដោយបញ្ជាក់ថា វាទាមទារឲ្យមានការត្រួតពិនិត្យមុននឹងយកជាភស្តុតាង អាចចាត់ទុកថា ជាបានការនោះ។

[១៤:២១:៣១]

តទៅនេះ ខ្ញុំបាទសូមបញ្ជាក់ទៅលើជំហររបស់មេធាវីការពារ ចំពោះសូចនាករនៃភាពជឿជាក់ដែលបានផ្តល់ដោយការិយាល័យសហព្រះរាជអាជ្ញា គឺថាពុំបានគ្រប់គ្រាន់ទេ។ សហព្រះរាជអាជ្ញាបានបង្ហាញថា បើយើងចង់ដឹងពីភាពជឿជាក់ទៅលើឯកសារ សូមឲ្យភាគី ជាពិសេសមេធាវីការពារទៅពិនិត្យមើលឧបសម្ព័ន្ធដែលសហព្រះរាជអាជ្ញាបានលើកឡើងថា មានព័ត៌មានពិស្តារនៅក្នុងនោះហើយ។

ខ្ញុំសូមលើកថា បើសិនជានៅក្នុងឧបសម្ព័ន្ធ ដូចយើងបានពិភាក្សាក្នុងសប្តាហ៍នេះគឺមានប្រាំឧបសម្ព័ន្ធរួចមកហើយនោះ មានព័ត៌មានលម្អិតពិស្តារទាំងស្រុងហើយនោះ។ សហព្រះរាជអាជ្ញា

ប្រហែលជាមិនចាំបាច់បង្ហាញពីសូចនាករនៃភាពជឿជាក់ទៅលើឯកសារទាំងនោះទេ។ ហើយក៏-- ប្រហែលជាយើងមិនចាំបាច់ចំណាយពេលវេលាក្នុងសវនាការមួយសប្ដាហ៍កន្លងមកនេះដែរ។

ដោយឡែក ចំពោះមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបានលើកសំណេរមួយបន្ទាត់របស់ ពីក្នុងសៀវភៅរបស់លោក ខៀវ សំផន អំពីឯកសារដែលប្រមូលបានពីមជ្ឈមណ្ឌលកម្ពុជា ឌី.ស៊ី.ខេម ដែលបង្ហាញថា លោក ខៀវ សំផន បានទទួលស្គាល់នូវឯកសារទាំងនោះ។

[១៤:២៤:២៥]

នៅពេលនេះខ្ញុំបាទសូមជម្រាបជូនក្រុមប្រឹក្សាជំនុំជម្រះនូវអ្វីដែលលោក ខៀវ សំផន បានជម្រាបជូនសហចៅក្រមស៊ើបអង្កេត។ លោកបានជម្រាបថា វាមានរួចមកហើយកាលពីមុននូវការក្លែងក្លាយ។ ចំពោះឯកសារដែលចេញពីមជ្ឈមណ្ឌលឯកសារកម្ពុជានោះ។ ដូច្នេះ ខ្ញុំសូមទទូចមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញាមេត្តាពិនិត្យទៅលើកំណត់ហេតុរបស់លោក ខៀវ សំផន ទាំងស្រុង ព្រមទាំងពិនិត្យទៅលើអត្ថបទផ្សេងៗដែលយើងបានដាក់ជូនផងដែរ។

[១៤:២៥:៤៧]

ខ្ញុំសូមបង្ហាញនូវជំហរឲ្យបានច្បាស់ជូនក្រុមប្រឹក្សាជំនុំជម្រះថា យើងមិនដែលបដិសេធឯកសារទាំងអស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជានោះទេ ប៉ុន្ដែយើងបានស្នើសុំជាញឹកញាប់ដល់ក្រុមប្រឹក្សាជំនុំជម្រះមេត្តាពិនិត្យដោយយកចិត្តទុកដាក់និងជាក់លាក់ ទៅលើឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ ខាងអយ្យការបាន ខាងសហព្រះរាជអាជ្ញាបានស្នើទៅចៅក្រមថា យើងបានលើកសេចក្ដីជំទាស់ថ្មី ដែលចៅក្រមមិនបានអនុញ្ញាតក្នុងពេលមុន។ ដូចថាតាំងពីថ្ងៃអង្គារមក ដូចក្រុមប្រឹក្សាជំនុំជម្រះបានជ្រាបស្រាប់ហើយ យើងខ្ញុំបានត្រឹមតែឆ្លើយតបទៅនឹងតម្រុយនៃភាពជឿជាក់បាន ដែលសហព្រះរាជអាជ្ញាបានផ្ដល់មកក្នុងក្របខ័ណ្ឌនៃឯកសារ E158 ដែលជាឯកសារលោកចៅក្រមបានអនុញ្ញាត ដែលអនុញ្ញាតឲ្យមានការជំទាស់។

[១៤:២៧:៤២]

សហព្រះរាជអាជ្ញាបានធ្វើឡើងតាមប្រភេទឯកសារផ្សេងៗ នៅក្នុងក្របខ័ណ្ឌនៃឯកសារE158 នោះ។ ហើយយើងខ្ញុំក៏ធ្វើចំណាត់ថ្នាក់ឯកសារនោះ តាមនោះដែរ។ ប៉ុន្ដែអ្វីដែលយើងអាចធ្វើបាននោះ គឺយើងធ្វើការពិភាក្សាជាទូទៅលើប្រភេទឯកសារជាមួយនឹងឧទាហរណ៍មួយចំនួន ដែលយើងបានលើកជាទូទៅអំពីការយល់ឃើញរបស់មេធាវីការពារ។ ក៏ប៉ុន្ដែការពិភាក្សាជាលក្ខណៈទូទៅនេះ មិនមែនជា

បំណងប្រាថ្នារបស់មេធាវីការពារយើងទេ ពីព្រោះដូចយើងបានជម្រាបជូនក្រុមប្រឹក្សាជំនុំជម្រះកន្លងមកហើយថា ខាងមេធាវីការពារស្នើសុំឲ្យមានការពិភាក្សាដេញដោលទៅលើឯកសារជាក់លាក់ គឺថាយើងចង់បានពិនិត្យទៅលើឯកសារនីមួយៗ។ ពីព្រោះថាឯកសារនីមួយៗជួយដល់ការស្វែងរកការពិតហើយយើងទាំងអស់ក៏ចង់ដឹងពីការពិតនោះដែរ។

សហព្រះរាជអាជ្ញា និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីចង់ឲ្យក្រុមប្រឹក្សាជំនុំជម្រះជឿថា យើងបានច្រានចោលឯកសារទាំងដុល ឯកសារទាំងអស់។ តែនេះមិនមែនជាជំហររបស់មេធាវីការពារយើងខ្ញុំទេ ប៉ុន្តែអ្វីដែលយើងខ្ញុំច្រានចោលទាំងស្រុងនោះ គឺជាការចេញនូវគោលការណ៍ ដែលថា ឯកសារទាំងឡាយណាដែលមិនមានការជំទាស់ គឺត្រូវទទួលយកដោយគ្មានការផ្ទៀងផ្ទាត់ទៀតឡើយ។ នេះជាចំណុចដែលមេធាវីការពារសូមជំទាស់ទាំងស្រុង ពីព្រោះថាភារកិច្ចរបស់អង្គជំនុំជម្រះ គឺត្រូវពិនិត្យទៅលើឯកសារនីមួយៗ ដែលភាគីដាក់បង្ហាញនៅចំពោះមុខខ្លួន ទោះជាមានការជំទាស់ ឬគ្មានការជំទាស់ក៏ដោយ។

[១៤:៣១:៣៧]

ខ្ញុំបាទសូមលើកពាក្យពេចន៍ ដែលមានចេញដោយចៅក្រមផ្សេង នៃតុលាការ អាយ.ស៊ី.ធី.វ៉ាយ នៅក្នុងលក្ខណៈនៃសំណុំរឿងធំធេង ដូចស្ថានភាពនៃសំណុំរឿងយើងនេះ។ គឺក្នុងករណីព្រះរាជអាជ្ញាទល់នឹង មីលេន ម៉ាទិចៗ សរសេរ “M-I-L-A-N M-A-R-T-I-C” ដែលជាសេចក្តីសម្រេចអនុម័តទៅលើគោលការណ៍ណែនាំ ស្តីពីបទដ្ឋានសម្រាប់គ្រប់គ្រងការទទួលយកភស្តុតាង ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៦ ត្រង់វាក្យខណ្ឌ១១-- កថាខណ្ឌ១១។

ខ្ញុំសូមអនុញ្ញាតអានជាភាសាអង់គ្លេសពីព្រោះវាជាសំណេរដើម។ សូមដកស្រង់ (អានជាភាសាអង់គ្លេស)៖ អង្គជំនុំជម្រះសាលាដំបូង ដោយអនុលោមទៅតាមលក្ខន្តិកៈនៃអង្គជំនុំជម្រះនេះ គោលការណ៍ណែនាំ និងការធានា។ នីតិវិធី ក៏ដូចជាសិទ្ធិសារវ័ន្តរបស់ជនជាប់ជាប់។ អង្គជំនុំជម្រះសាលាដំបូងពិចារណាឃើញថា បញ្ហានៃការទទួលយកនូវភស្តុតាងមិនមែនកើតឡើង តាមរយៈតែការលើកឡើងពីការជំទាស់ដោយភាគីតែម្ខាងនោះទេ។ ដើម្បីយកមកធ្វើជាភស្តុតាងដែលត្រូវដាក់ដោយភាគីម្ខាងទៀតនោះ។ អង្គជំនុំជម្រះសាលាដំបូង មានឆន្ទានុសិទ្ធិ មានសិទ្ធិ និងកាតព្វកិច្ចក្នុងការធានាថា មានតែភស្តុតាងដែលមានគុណវុឌ្ឍិ អាចទទួលយកមកធ្វើជាភស្តុតាង ដោយអនុលោមទៅតាមវិធាននេះ។ បិទសម្រង់វិញ (ចប់ការអានជាភាសាអង់គ្លេស)។

[១៤:៣៤:២៦]

ដូច្នេះ តាមខ្លឹមសារនេះវាជាការងាររបស់អង្គជំនុំជម្រះ ដែលត្រូវពិនិត្យលើឯកសារនីមួយៗ ជាការជំទាស់ដែលភាគីធ្វើឡើង គឺមានបំណងជួយដល់អង្គជំនុំជម្រះក្នុងការបំពេញការងាររបស់ខ្លួន។ ការពិភាក្សាជាទូទៅ ទៅលើឯកសារដែលយើងឃើញថា គរដូចភ្នំនេះ មិនអាចជួយដល់អង្គជំនុំជម្រះបានច្រើនឡើយ ដូចយើងបានឃើញស្រាប់ហើយ តម្រុយនៃភាពជឿជាក់បាន ដែលសហព្រះរាជអាជ្ញាបានផ្តល់មកនេះមិនគ្រប់គ្រាន់ទាំងបរិមាណ និងគុណភាព។

[១៤:៣៥:២៥]

ដើម្បីជួយដល់អង្គជំនុំជម្រះក្នុងការពិនិត្យឯកសារ សហព្រះរាជអាជ្ញាត្រូវជ្រើសរើសមធ្យោបាយណាមួយថា តើត្រូវបន្តសុំឲ្យបង្ហាញជូនអង្គជំនុំជម្រះ នូវឯកសាររាប់ពាន់ដដែលៗនេះ និងផ្តល់តម្រុយឲ្យបានច្រើនជាងនេះ គឺតម្រុយដែលល្អប្រសើរជាងនេះ សម្រាប់ឯកសារនីមួយៗ ឬក៏កាត់បន្ថយចំនួនឯកសារចេញពីបញ្ជី? ចំណុចនេះ ខ្ញុំបានស្តាប់ការរៀបរាប់របស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីថា ឯកសារដែលបានដាក់ជូនតុលាការ មិនមែនសុទ្ធតែបានការទាំងអស់នោះទេ ហើយក៏មិនមែនថា មិនបានការទាំងអស់ដែរ។ ដូច្នេះ នេះវាជាខ្លឹមសារមួយដែលអាចបង្ហាញឲ្យឃើញថា ឯកសារដែលដាក់ដោយសហព្រះរាជអាជ្ញា អាចមានឯកសារមួយចំនួនណានោះ យកជាការមិនបានដោយសារខ្វះភាពជឿជាក់នៃឯកសារនេះ។

[១៤:៣៧:១២]

បើដូច្នេះមែន បើយើងទាំងអស់គ្នានាំគ្នាពិភាក្សាទៅលើឯកសារ ដែលពុំមានគុណសម្បត្តិសម្រាប់បង្ហាញការពិត វាធ្វើឲ្យយើងខាតពេល។ អ៊ីចឹងការកាត់បន្ថយនូវឯកសារដែលមិនចាំបាច់ ដែលមិនពាក់ព័ន្ធជាដើមនេះ វាជាប្រយោជន៍មួយសម្រាប់ឲ្យយើងបានចំណេញពេលវេលា។ ប៉ុន្តែ ខ្ញុំបានឮសហព្រះរាជអាជ្ញាថា ហាក់ដូចជាស្នើសុំឲ្យបន្ទាបលក្ខខណ្ឌ ដែលតម្រូវឲ្យទទួលយកឯកសារនោះទៅវិញ ដោយសារថាឯកសារមានចំនួនច្រើន ដែលត្រូវពិនិត្យនោះ។ បើសិនជាយើងពិនិត្យឯកសារដែលមានចំនួនច្រើនក្នុងលក្ខខណ្ឌមួយខ្ពស់ ធ្វើឲ្យការពិនិត្យឯកសារនោះយូរ។ អ៊ីចឹងការស្នើសុំឲ្យបន្ទាបនូវកម្រិតនៃការទទួលយកបាននូវឯកសារ វាមិនអាចធ្វើបានទេ ពីព្រោះកម្រិតនោះវាត្រូវបានកំណត់ជាអប្បបរមារួចទៅហើយ។ ខ្ញុំឧទាហរណ៍ក្នុងករណីដោយឡែកមួយក្នុងការបង្ហាញភស្តុតាង ដែលយើងនិយាយអំពីការបង្ហាញឲ្យលើសពីវិមតិសង្ស័យដូចគ្នានេះដែរ វាជាកម្រិតមួយដែលបានកំណត់រួចហើយ

យើងមិនអាចថាដោយសារឯកសារច្រើន ឬដោយសារមានជនជាប់ចោទច្រើន អ៊ីចឹងមិនបាច់បង្ហាញភស្តុតាងឲ្យលើសពីវិមតិសង្ស័យនោះទេ។

[១៤:៣៩:២២]

ដូចគ្នាហ្នឹងដែរគឺថា ភាពចាំបាច់នៃការបង្ហាញចំពោះឯកសារទាំងឡាយ ដែលជាប់ពាក់ព័ន្ធ ឬដែលធ្វើឲ្យជឿជាក់ថា ជាឯកសារមានប្រយោជន៍សម្រាប់ស្វែងរកការពិតនោះ វាជាកម្រិតមួយដែលសហព្រះរាជអាជ្ញាគួរតែបង្ហាញ ដើម្បីជូនអង្គសវនាការដេញដោលទៅលើឯកសារទាំងនោះ។

អ៊ីចឹងត្រឡប់មកវិញ បើសិនជាសហព្រះរាជអាជ្ញាយល់ថា ឯកសារមានច្រើនពេក គឺមិនត្រូវដាក់ឯកសារដែលពុំមានប្រយោជន៍ចូលនៅក្នុងសំណុំរឿងនេះទេ។ ម្យ៉ាងទៀត ការជឿជាក់របស់តុលាការក៏អាស្រ័យទៅលើឯកសារទាំងអស់នោះដែរ។ ចំពោះសេចក្តីសន្និដ្ឋានលើការពិភាក្សាជាលក្ខណៈទូទៅលើឧបសម្ព័ន្ធទាំងប្រាំ ដំបូងនេះ។ ឯកសាររបស់សហព្រះរាជអាជ្ញា ក្នុងចំណោមឧបសម្ព័ន្ធទាំងអស់មានចំនួន២១ គឺថាវាមានការងារច្រើនណាស់ គឺជាការងារគរដូចភ្នំរបស់អង្គជំនុំជម្រះ ក្នុងការផ្ទៀងផ្ទាត់ភាពទទួលយកបាននៃឯកសារនីមួយៗ ដែលមានឯកសារចំនួន១១១៤-- (សុំទោស) ១១៣៤ ក្នុងចំណោមឯកសារសរុបចំនួន ៤៧៦៨ឯកសារ។

[១៤:៤១:៥២]

ជាចុងក្រោយ ខ្ញុំសូមលើកនូវជំហរនៃការបដិសេធរបស់យើងខ្ញុំថា យើងមិនបដិសេធចំពោះឯកសារទាំងដុល ឯកសារទាំងអស់នោះទេ។ ក៏ប៉ុន្តែយើងបដិសេធចំពោះគោលការណ៍ ដែលថាឯកសារទាំងឡាយដែលមិនមានការជំទាស់ គឺត្រូវទទួលយកដោយគ្មានការផ្ទៀតផ្ទាត់ផ្សេងទៀត។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទសូមអរគុណលោកមេធាវី។

ឥឡូវនេះ កិច្ចដំណើរការពិភាក្សាដេញដោលនៅលើឯកសារហ្នឹងឃើញថា បានដល់ទីបញ្ចប់មុនពេលវេលាដែលបានគ្រោងទុក។ ហើយមុននឹងផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ អង្គជំនុំជម្រះសូមជ្រាបជូនដំណឹងដល់ភាគីនៃរឿងក្តីឲ្យបានជ្រាបថា អំពីកាលវិភាគ និងការកំណត់ពេលវេលាសម្រាប់ដំណើរពិភាក្សាដេញដោលលើសាក្សីចំនួនពីររូប ដែលអង្គជំនុំជម្រះគ្រោងធ្វើនៅក្នុងសប្តាហ៍ក្រោយចាប់ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១២ អង្គជំនុំជម្រះបានចាត់តាំងមន្ត្រីច្បាប់ជាន់ខ្ពស់ឲ្យធ្វើការរៀបចំនូវអ៊ីមែល ជូនដំណឹងទៅភាគី។

ដូច្នេះ កិច្ចការនេះមន្ត្រីច្បាប់ជាន់ខ្ពស់បានរៀបចំនឹងបញ្ជូនរួចហើយ។ ដូច្នេះដើម្បីបានជ្រាបច្បាស់សូមភាគីពិនិត្យមើលអ៊ីមែលរបស់ខ្លួន ដើម្បីបានទទួលព័ត៌មានអំពីកាលវិភាគនៃកិច្ចដំណើរការសវនាការសម្រាប់សប្តាហ៍ក្រោយ។

សូមអញ្ជើញ!

[១៤:៤៤:០៦]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំចង់លើកបន្តទៅលើសំណើដែលយើងបានធ្វើកាលពីសប្តាហ៍មុនក្រោយពីកំណត់សម្គាល់លើកឡើងដោយនាយករដ្ឋមន្ត្រីជាសាធារណៈអំពីកូនក្តីរបស់ខ្ញុំ។ គាត់ហៅកូនក្តីរបស់ខ្ញុំថា ជាឃាតក ហើយគាត់លើកឡើងថា សេចក្តីប្រកាសរបស់គាត់នេះគឺជាការលើកឡើងដែលថាវាជាការថ្កោលទោស។ យើងគិតថា យើងសូមធ្វើការថ្កោលទោសចំពោះសេចក្តីប្រកាសរបស់នាយករដ្ឋមន្ត្រីនេះ។ ហើយយើងក៏មិនដឹងថា នៅពេលណាដែលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះយើងធ្វើការសម្រេចទៅលើកូនក្តីរបស់ខ្ញុំ យើងខ្ញុំនៅឡើយទេ។ ដូច្នេះ យើងមិនទាន់ដឹងនៅឡើយ នោះឡើយ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៤៦:៣៥]

**ប្រធានអង្គជំនុំ៖**

ឥឡូវជ្រាបឲ្យច្បាស់លាស់ថាអង្គជំនុំជម្រះបានកត់សម្គាល់នូវមតិយោបល់របស់មេធាវីរួចហើយទាំងលើកមុន ហើយទំនងជាមេធាវីបានលើកឡើងនូវបញ្ហាអ្វីក៏ដោយ អង្គជំនុំជម្រះសង្កេតឃើញថាមេធាវី នួន ជា មេធាវីអន្តរជាតិ នួន ជា ហាក់ដូចជាព្យាយាមក្នុងការនិយាយបញ្ហាដដែលៗប៉ុណ្ណោះ ហើយបញ្ហានេះ គឺអង្គជំនុំជម្រះមិនធ្វើអត្ថាធិប្បាយអ្វីចំពោះការលើកឡើងរបស់មេធាវីការពារក្តី នួន ជា នេះទេ។ ហើយយើងក៏មិនអនុញ្ញាតឲ្យលើកបញ្ហានេះតទៅទៀតរបៀបនេះដែរ។

[១៤:៤៧:១៤]

ឥឡូវនេះដល់ពេលសមល្មមនឹងឈប់សម្រាកសម្រាប់ថ្ងៃនេះហើយ ដោយសារកិច្ចប្រឹងប្រែងក្នុងការដំណើរការសវនាការបានលឿនបានមុនពេលកំណត់។ ហេតុដូច្នេះអង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី២៣ ខែមករា ឆ្នាំ២០១២ ដោយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ដូច្នេះ ភាគី និងសាធារណជនជ្រាប។

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំជនជាប់ចោទទាំងបីរូបត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ ហើយបង្គាប់ឲ្យនាំជនជាប់ចោទទាំងបីនាក់មកកាន់បន្ទប់សវនាការនេះនៅព្រឹកថ្ងៃចន្ទ ទី២៣ ខែមករា ឆ្នាំ២០១២ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក៕

*(ចៅក្រមចាកចេញពីបន្ទប់សវនាការ)*

*(សវនាការផ្អាកនៅម៉ោង១៤:៤៨នាទី)*